# មិត្តនគរបាល

POLICE FRIENDSHIP MAGAZINE

ទស្សនាវដ្ដី

លេខ ៥៤ ឆ្នាំទី ១២ - ២០១៣




www.interior.gov.kh

## រាជរដ្ឋាភិបាល បង្កើតខណ្ឌថ្មីចំនួន៣ ៖ ខណ្ឌជ្រោយចង្វារ ខណ្ឌច្បារអំពៅ និង ខណ្ឌព្រែកព្នៅ

(ពេលនេះទូទាំងរាជធានីមានខណ្ឌសរុបចំនួន១២)

# មាតិកា CONTENT 2013




- សារជូនពរឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី.............................០១
- លិខិតជូនពរឆ្នាំថ្មី ឆ្នាំសកល ២០១៤.............................................០២
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញបើកសម្ពោធ.............០៣
- សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ស្តីពីវិមជ្ឈការ...........................០៤
- ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី.........................................០៦
- ២០១៤ ជំរុញការទប់ស្កាត់កាត់បន្ថយបទល្មើស...................................០៧
- នាយកដ្ឋានអន្តោប្រវេសន៍ចុះត្រួតពិនិត្យពង្រឹង.................................០៨
- ២០១៣ គ្រោះថ្នាក់ចរាចរណ៍កើតឡើង...............................................០៩
- បទបញ្ជាស្តីពីការបើកបៀរក្សរ៍.........................................................១០
- ជំរុញបើកវគ្គបំប៉នគ្រូបង្គោលស្តីពីការប្រយុទ្ធនឹង...............................១៨
- នគរបាលអន្តរជាតិកម្ពុជាធ្វើជាម្ចាស់ផ្ទះ...........................................២០
- សារាចរលេខ ០៦ របស់រាជរដ្ឋាភិបាល ..............................................២១
- ប្រតិទិនឆ្នាំថ្មី ឆ្នាំ២០១៤ .................................................................២២
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញសម្ពោធដាក់ឱ្យ.........២៤
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អនុញ្ញាតឱ្យ ..........................២៥
- ឯកឧត្តម មៀច សុផាន់ណា អនុរដ្ឋលេខាធិការ...................................២៨
- ពិធីប្រគល់-ទទួលសម្ភារៈ BLO គម្រោង PATROL .............................២៩
- សិក្ខាសាលាស្តីពីការពិនិត្យ ពិភាក្សា កែសម្រួល..... .........................៣០
- សុខភាព ៖ បួសថ្លើមមានសញ្ញាអ្វីខ្លះ ?............... .........................៣២
- បញ្ជីឈ្មោះ ស.ម.ន........................................... .........................៣៨
- កំណាព្យ "ប្រាំពីរមករា"...................................................................៤១
- កំណាព្យ "អ្នកមានប្រយោជន៍ដល់បរិស្ថាន"......................................៤២
- អគ្គស្នងការដ្ឋាននគរបាលជាតិកែសម្រួល..........................................៤៤
- វេទិការដ្ឋាភិបាលលើកទី ១០ និងសមាគម..........................................៤៦
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ៖ "ប្រជាជន និង......................៤៧



## គណៈកម្មការនិពន្ធ

**នាយកគ្រប់គ្រង**
ឧត្តមសេនីយ៍ឯក ម៉ៅ ម៉ុនណារិន

**នាយកការផ្សាយ**
ឧត្តមសេនីយ៍ទោ កុសល តិរម្យ

**និពន្ធនាយក**
ឧត្តមសេនីយ៍ត្រី សៀង សុវត្ថិ

**និពន្ធនាយករង**
វរសេនីយ៍ឯក ស្វាយ សុទ្ធី
វរសេនីយ៍ទោ សំ យ៉ន

**លេខានិពន្ធ**
អនុសេនីយ៍ឯក ស្រី ស៊ឹមលន់

**យកព័ត៌មាន និពន្ធ និងថតរូប**
វរសេនីយ៍ទោ ស៊ឿ ចាន់ណារ៉ា
អនុសេនីយ៍ឯក ស្រី សុទ្ធា
អនុសេនីយ៍ឯក ថ៉ាន សុផាប
អនុសេនីយ៍ឯក ញឹម ហឿន
អនុសេនីយ៍ឯក ប្រាក់ តុលា
អនុសេនីយ៍ឯក ឌិន ម៉ូលីដា
អនុសេនីយ៍ឯក ចាប ភ័ស្ត
អនុសេនីយ៍ឯក រិទ្ធ ដាណា
អនុសេនីយ៍ទោ សុន សៀង
អនុសេនីយ៍ត្រី ឡុង ពុទ្ធារិទ្ធិ

**អ្នកបកប្រែ**
វរសេនីយ៍ទោ ជុំ អ៊ូរស្មី

**បច្ចេកទេសកុំព្យូទ័រ**
វរសេនីយ៍ត្រី ប៉ុក រដ្ឋា
វរសេនីយ៍ត្រី ប្រាជ្ញ បញ្ញា


## លេខទូរស័ព្ទទាន់ហេតុការណ៍

| នគរបាលប្រចាំបញ្ជា | |
|---|---|
| -អន្តរាគមន៍ទូទៅទូទាំងប្រទេស | 117 / 118 |
| -វរសេនាធំអន្តរាគមន៍អគ្គិភ័យរាជធានីភ្នំពេញ | 666<br>012 786 693<br>012 997 296 |
| -ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន | 023 720 555 |
| **វថយន្តសង្គ្រោះបន្ទាន់** | |
| -មន្ទីរពេទ្យកាល់ម៉ែត្រ | 119<br>023 723 840<br>023 724 891 |
| -មន្ទីរពេទ្យមិត្តភាពកម្ពុជា-រុស្ស៊ី | 023 217 764 |
| -មន្ទីរពេទ្យព្រះកុសមៈ (ព្រះសង្ឃ) | 023 882 947 |


ទស្សនាវដ្ដី នគរបាល
-ការិយាល័យនិពន្ធ : 012 946 099 / 012 545 999
095 838 909 / 023 726 317
023 727 518
Fax : 023 726 184
- E-mail : mag.metpolice@yahoo.com
- Website : www.interior.gov.kh
អាជ្ញាប័ណ្ណក្រសួងព័ត៌មានលេខ ១៣៧ ព.ម.ប្រក

# សូមគោរពជូនពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ

ជូនចំពោះ

## ឯកឧត្តម ស ខេង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



## ក្នុងឱកាសខួបកំណើត គម្រប់៦២ឆ្នាំ ឈានចូល៦៣ឆ្នាំ

សូមឯកឧត្តមទទួលបាននូវសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងពលំខ្លាំងក្លា
ប្រាជ្ញាឈ្លាសវៃ ដើម្បីរួមចំណែកដឹកនាំកសាងនិងអភិវឌ្ឍមាតុភូមិកម្ពុជា
ឱ្យកាន់តែរីកចម្រើនរុងរឿងឆ្ពោះទៅរកសុខសន្តិភាព សុភមង្គលដ៏យូរអង្វែងតរៀងទៅ ។

សូមគោរពជូនពរពី

គណៈកម្មការនិពន្ធទស្សនាវដ្ដី នគរបាល

នាយកគ្រប់គ្រង

ឧត្តមសេនីយ៍ឯក ម៉ៅ ប៊ុនណារិន

# លិខិតជូនពរ 2014 ឆ្នាំថ្មី ឆ្នាំសាកល

**-វីរយុទ្ធជន វីរយុទ្ធនារីនៃកងកម្លាំងនគរបាលជាតិទាំងអស់ជាទីស្រលាញ់រាប់អាន !**
**-ប្រិយមិត្តអ្នកអានជាទីមេត្រី !**

ឆ្នាំសាកលថ្មី ២០១៤ បានឈានចូលមកដល់ជាមួយនឹងវិសាលភាពដ៏ធំធេងនៃសមិទ្ធផលថ្មីៗលើគ្រប់វិស័យ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលធ្វើឱ្យសង្គមជាតិទាំងមូល និងប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបាននូវមោទនភាពជាតិដ៏ខ្ពង់ខ្ពស់។

ដោយឡែកវីរយុទ្ធជន-វីរយុទ្ធនារីនៃកងកម្លាំងនគរបាលជាតិយើងទាំងមូលក៏កំពុងបង្ហាញនូវស្នាមញញឹមប្រកបដោយមោទនភាពដ៏ខ្ពង់ខ្ពស់បំផុតជាមួយនឹងស្នាដៃសំខាន់ៗចំនួន៤ ដែលយើងទាំងអស់គ្នាសម្រេចបានក្នុងឆ្នាំ២០១៣កន្លងមកនេះ គឺ **១**-ការធានារក្សាបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយដែលជួយបង្កបរិយាកាសសេរី យុត្តិធម៌ អព្យាក្រឹត្យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សាក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ **២**-ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវចរន្តមហាបាតុកម្មរបស់គណបក្សប្រឆាំង ដែលប៉ុនប៉ងញុះញង់ប្រជាពលរដ្ឋឱ្យចូលរួមធ្វើមហាបាតុកម្មក្នុងគោលបំណងបំផ្លាញលទ្ធផលបោះឆ្នោតមួយប្រកបដោយលក្ខណៈសេរី យុត្តិធម៌ និងត្រឹមត្រូវ ដែលមានការគាំទ្រពីសំណាក់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ។ **៣**-ការធានារ៉ាប់រងដោយផ្ទាល់នូវភារកិច្ចដ៏ឧត្តុង្គឧត្តមនៅតំបន់គ្មានកងទ័ពជុំវិញប្រាសាទព្រះវិហារ ព្រមទាំងការបង្កនូវបរិយាកាស សាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយភាគីថៃនៅតាមបណ្តោយព្រំដែននិយាយរួម និងនិយាយដោយឡែកនៅតំបន់ជុំវិញប្រាសាទព្រះវិហារ បន្ទាប់ពីការបកស្រាយសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣។ **៤**-ជោគជ័យនៃការអនុវត្តន៍គោលនយោបាយ **"ភូមិ-ឃុំមានសុវត្ថិភាព"** ដែលនេះជាគោលនយោបាយមួយមានភាពស័ក្តិសិទ្ធបំផុតក្នុងការផ្តល់នូវភាពសុខដុមរមនានិងភាពកក់ក្តៅជូនដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់មូលដ្ឋានទូទាំងប្រទេស។

ផ្អែកលើមេរៀនពិសោធន៍ល្អៗក្នុងឆ្នាំចាស់កន្លងមកនោះ នៅក្នុងឆ្នាំថ្មី២០១៤នេះ ទាមទារឱ្យកងកម្លាំងនគរបាលយើងគ្រប់មុខជំនាញលើកកម្ពស់ស្មារតីទទួលខុសត្រូវចំពោះភារកិច្ចរៀងៗខ្លួនបន្ថែមទៀត ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីចូលរួមទាំងអស់គ្នាជំរុញការអនុវត្តន៍ឱ្យបានជោគជ័យនូវ **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដែលជារបៀបវារៈគោលនយោបាយសង្គមកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ឆ្លៀតក្នុងឱកាសដ៏សោមនស្សរីករាយទទួលអំណរសាទរឆ្នាំសាកលថ្មី ២០១៤នេះ គណៈកម្មការនិពន្ធ **ទស្សនាវដ្តីមិត្តនគរបាល** សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថ្វាយនិងគោរពជូនចំពោះសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ព្រមទាំងជូនចំពោះប្រិយមិត្តអ្នកអានគ្រប់រូប ដែលបាននិងកំពុងផ្តល់ការគាំទ្រចំពោះទស្សនាវដ្តីមិត្តនគរបាល។ ទន្ទឹមនេះសូមបួងសួងឱ្យឆ្នាំថ្មី ឆ្នាំសាកល ២០១៤ ជួយប្រសិទ្ធពរជ័យសិរីមង្គលគ្រប់ប្រការថ្វាយនិងគោរពជូនចំពោះសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ព្រមទាំងប្រិយមិត្តអ្នកអានទាំងអស់ទទួលបាននូវសុខភាពល្អបរិបូរណ៍និងមានសុភមង្គលគ្រប់ក្រុមគ្រួសារកុំបីអាក់ខានឡើយ ។



ជ.គណៈកម្មការនិពន្ធទស្សនាវដ្តី មិត្តនគរបាល
នាយកគ្រប់គ្រង

ឧត្តមសេនីយ៍ឯក ម៉ៅ ច័ន្ទណារិន

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញបើក សម្ពោធ មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ជាតិ អង្គការ SOS ភូមិកុមារភ្នំពេញ

ពិធីសម្ពោធមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ជាតិអង្គការ SOS ភូមិកុមារកម្ពុជា បានប្រព្រឹត្តឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី



ក្រសួងមហាផ្ទៃ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ ដែលមានទីតាំងស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ។

តាមប្រវត្តិសង្ខេបនៃការបង្កើត SOS របស់លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ហ៊ឺរ ម៉ែន័រ** ជាជនជាតិអូទ្រីស បានឱ្យដឹងថា : លោក **ហ៊ឺរ ម៉ែន័រ** បានប្រសូត្រនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩១៩ នៅភូមិអាល់បឺស្ថិន ក្នុងតំបន់វ៉ារ៉ាប៊ឺក ប្រទេសអូទ្រីស។ លោក **ម៉ែន័រ** កើតក្នុងត្រកូលកសិករដែលមានកូនច្រើន និងរស់នៅក្នុងតំបន់ស្រុកស្រែចម្ការ។ ម្តាយរបស់គាត់បានស្លាប់នៅពេលគាត់នៅជាកុមារនៅឡើយ។ ពេលនោះ បងស្រីច្បងរបស់គាត់ដែលមានអាយុទើបតែ១៦ឆ្នាំ ឈ្មោះ **អែលសា** ជាអ្នកទទួលភារកិច្ចថែរក្សារូបគាត់ ព្រមទាំងបងប្អូនប្រុសស្រីរបស់គាត់ជាច្រើនទៀត។ លោក **ហ៊ឺរ ម៉ែន័រ** បានធំចម្រើនវ័យដោយសារការថែរក្សារបស់បងស្រីគាត់។ ឆ្លងកាត់ការអនុវត្តន៍របស់បងស្រី បទពិសោធន៍នេះបានប្រែក្លាយជាគំនិតមួយដែលគាត់បានយកមកទុកក្នុងចិត្ត ហើយបានប្រើប្រាស់ក្នុងការបង្កើត SOS ដោយបានយកគំរូរបស់បងស្រីមកអនុវត្ត សម្រាប់អ្នកម្តាយ



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញបើកស្លាកសម្ពោធដាក់ឱ្យប្រើប្រាស់មជ្ឈមណ្ឌល SOS

អាជីពនៅ SOS ភូមិកុមារនេះឡើង។

គួរបញ្ជាក់ដែរថា : បច្ចុប្បន្នអង្គការ SOS មានមជ្ឈមណ្ឌលភូមិកុមារ SOS ៥ កន្លែង គឺនៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង រតនគិរី និងចុងក្រោយភូមិកុមារ SOS នៅខេត្តក្រចេះ គ្រោងសម្ពោធនៅខែមករា ដើមឆ្នាំ២០១៤នេះ។ បន្ទាប់ពីនេះ អង្គការ SOS គ្រោងសាងសង់បន្តនៅខេត្តកំពត និងខេត្តព្រៃវែងបន្ថែមទៀត។

អញ្ជើញមានប្រសាសន៍ក្នុងពិធីនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានបញ្ជាក់ថា : អង្គការ SOS បច្ចុប្បន្នបាននិងកំពុងធ្វើសកម្មភាពសំខាន់ចំនួន២ធំៗរួមមាន : **ទី១**-ធ្វើសកម្មភាពសុខុមាលភាពកុមារដោយបង្កើតជាភូមិកុមារសម្រាប់កុមារកំព្រាគ្មានគ្រួសារ គ្មានផ្ទះសម្បែង កុមារអនាថាគ្មានទីពឹង និង **ទី២**-ធ្វើសកម្មភាពសុខុមាលភាពនិងវិស័យអប់រំ។ ឯកឧត្តមមានប្រសាសន៍បន្តទៀតថា : កន្លងមក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់ដីទំហំ៣,៦ ហិកតាសម្រាប់សាងសង់ភូមិកុមារ សាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៅខេត្តសៀមរាប និងបានផ្តល់ថវិកាមួយចំនួនសម្រាប់ទិញដីកសាងភូមិកុមារនេះទៀតនៅខេត្តបាត់ដំបង។ ដោយឡែកនៅក្នុងរាជធានីភ្នំពេញនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក៏បានផ្តល់ដីទំហំប្រមាណ១២.៦១០ម៉ែត្រការ៉េ ជូនអង្គការ SOS ផងដែរ ៕ *សុទ្ធា*

# សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ស្តីពីវិមជ្ឈការ និងភាពជាអ្នកដឹកនាំ ដើម្បីឆ្លើយតបនឹង តម្រូវការមូលដ្ឋាននិងការប្រែប្រួលនៅក្នុងសង្គម


ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលា


ឯកឧត្តម ពេជ្រ ប៊ុនធិន

កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ នៅសណ្ឋាគារអ៊ិនធើខនធីណិនថល មានរៀបចំសិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ស្តីពីវិមជ្ឈការនិងភាពជាអ្នកដឹកនាំដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋាន និងការប្រែប្រួលក្នុងសង្គមក្រោមអធិបតីភាពឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

នៅក្នុងសុន្ទរកថាស្វាគមន៍របស់ឯកឧត្តម **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានឱ្យដឹងថា : ប្រធានបទ **"វិមជ្ឈការនិងភាពជាអ្នកដឹកនាំដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន និងការប្រែប្រួលនៅក្នុងសង្គម"** ដែលលើកឡើងនៅក្នុងសិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់នាពេលនេះ គឺជាប្រធានបទដែលឆ្លុះបញ្ចាំងសមស្របបំផុតទៅនឹងបរិបទនៃអភិបាលកិច្ចបច្ចុប្បន្ន ដែលទាមទារឱ្យអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់ ទោះជានៅក្នុងវិស័យសាធារណៈក្តី ឬក្នុងវិស័យឯកជនក្តីត្រូវចេះស្វែងយល់អំពីភាពបត់បែននៃសភាពការណ៍នៅក្នុងសង្គម ចេះស្វែងយល់អំពីតម្រូវការរបស់អតិថិជនដែលមានការប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ និងចេះព្យាករណ៍ទុកអំពីស្ថានការណ៍នាពេលអនាគត ដើម្បីអាចអភិវឌ្ឍខ្លួននៅក្នុងសង្គមប្រកួតប្រជែងនេះប្រកបដោយជោគជ័យបាន។

សុន្ទរកថាបានបន្តទៀតថា : រាជរដ្ឋាភិបាលកម្ពុជាបានស្វែងយល់យ៉ាងច្បាស់អំពីបញ្ហានេះ។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្លាប់មានប្រសាសន៍បញ្ជាក់រួចហើយថា : **"កម្ពុជាមិនមានជម្រើសណាក្រៅពីការកែទម្រង់ឡើយ យើងកែទម្រង់ដើម្បីរស់"**។ ប្រសាសន៍នេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីតម្រូវការចាំបាច់នៃការកែប្រែនូវទម្លាប់ចាស់ឈោងចាប់ទម្លាប់ថ្មី ដែលសមស្របដើម្បីអាចឆ្លើយតបបានទៅនឹងការប្រែប្រួលនៅក្នុងសង្គម។ ការបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិគឺជាវិញ្ញាសារលំបាក និងស្មុគស្មាញបំផុតសម្រាប់ថ្នាក់ដឹកនាំនៅគ្រប់ប្រទេស និងគ្រប់និន្នាការនយោបាយ។ ប៉ុន្តែទោះជាលំបាកយ៉ាងណាក្តី វិញ្ញាសារ




ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញជាអធិបតីក្នុងពិធី

នេះគឺជាកាតព្វកិច្ចរបស់រដ្ឋាភិបាលនៃប្រទេសនីមួយៗ ដែលត្រូវយកចិត្តទុកដាក់ពិចារណាដោះស្រាយឱ្យបានល្អប្រសើរជាអតិបរមាជូនដល់ប្រជាពលរដ្ឋនៃប្រទេសរបស់ខ្លួន។ រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះបញ្ហានេះតាមរយៈការដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានាជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ការបម្រើសេវានានាជូនប្រជាពលរដ្ឋ។ និយាយរួមកំណែទម្រង់រដ្ឋបាល គឺសំដៅលើការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ដោយមានប្រសិទ្ធភាពមួយ សម្រាប់ដាក់ឱ្យអនុវត្តនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ នេះជាបេសកកម្មដ៏ចម្បង និងមានសារៈសំខាន់បំផុត សម្រាប់ក្រសួងមុខងារសាធារណៈ។

តាមរយៈសេចក្តីសន្និដ្ឋានស្តីពីកិច្ចអភិវឌ្ឍមូលដ្ឋាន និងអភិបាលកិច្ចមូលដ្ឋាននៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាបានបញ្ជាក់ថា : ជារួមទោះបីស្ថាប័នវិមជ្ឈការនៅកម្ពុជាពុំទាន់បានរឹងមាំ និងមានវិសាលភាពធំទូលាយយ៉ាងណាក្តី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាបានដំណើរការលើវិថីដ៏ត្រឹមត្រូវដោយសន្សឹមៗ ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ស្របតាមយុទ្ធសាស្ត្ររបស់កម្ពុជា **គឺធ្វើយ៉ាងណាចាក់គ្រឹះឱ្យបានរឹងមាំសម្រាប់បញ្ជ្រាបការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ បន្ទាប់**

តទៅទំព័រ ៤០



លោកសាស្ត្រាចារ្យ អាគីអូ កាមីកូ



ឯកឧត្តម ហ៊ីរ៉ូស៊ី អ៊ុយហ្សាគី



លោកសាស្ត្រាចារ្យ វ៉ូធីសាន ថាន់ឆៃ



លោកបណ្ឌិត អាឡិចប៉ៃលឡូ ប្រឺឡង់គេស្ត



សមាជិក -សមាជិកាចូលរួមក្នុងពិធី

# ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពី សេវាសុខភាពនិងកម្មវិធីអប់រំស្តារនីតិសម្បទាក្នុងពន្ធនាគារ រវាងអគ្គនាយកដ្ឋាន ពន្ធនាគារ និង អង្គការ ការីតាស កម្ពុជា




ឯកឧត្តម នុត សាអាន អញ្ជើញជាអធិបតី
ក្នុងពិធីចុះហត្ថលេខារវាងអគ្គនាយកដ្ឋានពន្ធនាគារនិងអង្គការការីតាស

ព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅសាលប្រជុំអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ មានរៀបចំពិធីចុះហត្ថលេខាលើកិច្ច



ឯកឧត្តម ឧត្តមសេនីយ៍ឯក គុយ ប៊ុនសន

ព្រមព្រៀងរវាងអគ្គនាយកដ្ឋានពន្ធនាគារ និងអង្គការការីតាសកម្ពុជា ស្តីពីសេវាសុខភាព និងកម្មវិធីអប់រំស្តារនីតិសម្បទា ក្នុងពន្ធនាគាររវាងឯកឧត្តម ឧត្តមសេនីយ៍ឯក **គុយ ប៊ុនសន** អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងលោក **គីម រតនា** ប្រធានអង្គការការីតាសកម្ពុជាក្រោមអធិបតីភាពឯកឧត្តម **នុត សាអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។

គោលបំណងសំខាន់ក្នុងពិធីចុះហត្ថលេខានេះ គឺដើម្បីបន្តអនុវត្តគម្រោងគាំទ្រសេវាសុខភាព និងកម្មវិធីអប់រំស្តារនីតិសម្បទា ជាពិសេសជំងឺរបេង អេដស៍ និងរបេង-អេដស៍ក្នុងពន្ធនាគាររយៈពេល៣ឆ្នាំ(២០១៣-២០១៥) ដែលមានទឹកប្រាក់ចំនួន៣៨៤.៨០៤ដុល្លារសហរដ្ឋអាមេរិក។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **គុយ ប៊ុនសន** បានបញ្ជាក់ថា ៖ ក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ



លោក គីម រតនា

តទៅទំព័រ ៣៦





សមាជិក-សមាជិកាចូលរួមក្នុងពិធី

# 2014 ជំរុញការងារទប់ស្កាត់ កាត់បន្ថយ បទល្មើសឱ្យថយចុះពី 10 ទៅ 20 ភាគរយ

នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ នៅសាលប្រជុំនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ មានពិធីប្រជុំបូកសរុបលទ្ធផលការងារបង្ការ



ឯកឧត្តម ឧត្តមសេនីយ៍ឯក កង សុខន និងឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ក់ ជីតូ អញ្ជើញជាអធិបតីក្នុងពិធី

ទប់ស្កាត់ និងបង្ក្រាបបទល្មើសរយៈពេល ១១ខែ ឆ្នាំ២០១៣ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម ឧត្តមសេនីយ៍ឯក **កង សុខន** អគ្គស្នងការរងនគរបាលជាតិ និងឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ក់ ជីតូ** ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌។

យោងតាមរបាយការណ៍របស់លោកឧត្តមសេនីយ៍ទោ **អ៊ិន បូរ៉ា** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌបានបញ្ជាក់ឱ្យដឹងថា ៖ បទល្មើសរួមកើតមានចំនួន២.៥៧២ករណី ប្រៀបធៀបនឹងឆ្នាំ២០១២ មានចំនួន ២.៤៩៣ករណី កើន៧៩លើក ស្មើនឹង ៣,១៦ភាគរយ។ ក្នុងនោះ បទល្មើសឧក្រិដ្ឋមានចំនួន៧៤១ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន៧៦៨ករណី ថយចុះ២៧លើក ស្មើនឹង៣,៥១%។ ដោយឡែកនៅបណ្តារាជធានី-ខេត្ត ដែលមានបទល្មើសឧក្រិដ្ឋកើនឡើងមានចំនួន៩ ក្នុងនោះរួមមាន ៖ រាជធានីភ្នំពេញមាន២០៤ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន១៣៦បទល្មើស កើន ៦៨បទល្មើស ស្មើនឹង៥០% ខេត្តតាកែវមានចំនួន៣៣ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន៣២បទល្មើស កើន១បទល្មើស ស្មើនឹង៣,១២% ខេត្តកំពង់ចាមមាន៧៥



លោកឧត្តមសេនីយ៍ទោ អ៊ិន បូរ៉ា

ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន៧២ករណី កើន៣ ស្មើនឹង៤១៦ ខេត្តព្រៃវែង មានចំនួន៤៥ករណី ធៀបនឹងឆ្នាំ២០១២

តទៅទំព័រ ១៥





សមាជិកចូលរួមក្នុងពិធី

# នាយកដ្ឋានអន្តោប្រវេសន៍ចុះត្រួតពិនិត្យពង្រឹងសមត្ថភាពការងារនៅប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ

អនុវត្តតាមបទបញ្ជាណែនាំរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងការចង្អុលណែនាំផ្ទាល់របស់ឯកឧត្តម ឧត្តមសេនីយ៍ឯក **ពិន ពិសិដ្ឋ** ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ថ្មីៗកន្លងទៅនេះ ក្រុមការងារនាយកដ្ឋានអន្តោប្រវេសន៍ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី **ព្រហ្ម វិមល** លោកឧត្តមសេនីយ៍ត្រី **សៀង យ៉ុងវ៉ាត់** និងលោកឧត្តមសេនីយ៍ត្រី **តាន់ សុខវិជ្ជា** អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍បានចុះធ្វើការត្រួតពិនិត្យពង្រឹងវិន័យការងារនៅប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ការចុះត្រួតពិនិត្យនៅតាមបណ្តាប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិនេះ គឺដើម្បីបង្កើនប្រសិទ្ធ-ភាពការងារដឹកនាំគ្រប់គ្រងពង្រឹងវិន័យ ការអនុវត្តន៍តួនាទីភារកិច្ចជំនាញ និង ការងារបំពេញបែបបទលិខិតស្នាមរដ្ឋបាលរបស់មន្ត្រីជំនាញនៅប៉ុស្តិ៍ច្រកទ្វារព្រំដែន។

បន្ទាប់ពីបានស្តាប់របាយការណ៍ក៏ដូចជាការលើកឡើងរបស់លោកនាយប៉ុស្តិ៍ច្រកទ្វារព្រំដែនស្តីពីសភាពការណ៍សន្តិសុខនៅតាមតំបន់ព្រំដែនរួចមក លោកឧត្តមសេនីយ៍ត្រី **ព្រហ្ម វិមល** ក៏បានឡើងមានមតិគូសបញ្ជាក់ពីគោលបំណងនៃការចុះមកត្រួតពិនិត្យការងារនាពេលនេះ គឺដើម្បីជំរុញប្រសិទ្ធភាពការងារ និងត្រួតពិនិត្យមើលការបំពេញបែបបទលិខិតស្នាមរបស់មន្ត្រីជំនាញសម្រាប់ភ្ញៀវធ្វើដំណើរឆ្លងកាត់ និងការរៀបចំសណ្តាប់ធ្នាប់នៅប៉ុស្តិ៍ច្រកទ្វារព្រំដែន។ លោកឧត្តមសេនីយ៍ត្រី បានបញ្ជាក់បន្ថែមទៀតថា : បច្ចុប្បន្នប្រទេសកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍន៍រីកចម្រើនលើគ្រប់វិស័យ ហើយភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងអ្នកវិនិយោគទុនជាច្រើនបានចូលមកធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជា ដែលកត្តាទាំងនេះតឺទាមទារឱ្យមន្ត្រីនគរបាលអន្តោប្រវេសន៍ទាំងអស់ត្រូវមានសមត្ថភាពគ្រប់គ្រាន់ និងចូលរួមឱ្យបានសកម្មក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈដូចជាការបំពេញបែបបទផ្សេងៗ ការត្រួតពិនិត្យលិខិតស្នាមរាល់ការចេញ-ចូលប្រទេសរបស់ភ្ញៀវ និងការកំណត់មុខសញ្ញាល្មើសច្បាប់ចេញ-ចូលឆ្លងកាត់តាមតំបន់ច្រកទ្វារព្រំដែនផងដែរ។



សកម្មភាពប្រជុំលើកកម្ពស់សមត្ថភាពការងាររបស់មន្ត្រីជំនាញ





សកម្មភាពថ្នាក់ដឹកនាំនាយកដ្ឋានអន្តោប្រវេសន៍ចុះពិនិត្យសកម្មភាពការងារមន្ត្រីជំនាញនៅតាមច្រកទ្វារព្រំដែន

លោកឧត្តមសេនីយ៍ត្រីក៏បានសំណូមពរដល់មន្ត្រីនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនទាំងអស់ត្រូវចូលរួមសហការឱ្យបានល្អជាមួយអាជ្ញាធរមូលដ្ឋាននិងចូលរួមអនុវត្តឱ្យបានជោគជ័យនូវការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងត្រូវបង្កើនចំណេះដឹងទូទៅបន្ថែមទៀត ពិសេសជំនាញភាសាបរទេស និងជំនាញព័ត៌មានវិទ្យា (ផ្នែកកុំព្យូទ័រ) ដើម្បីងាយស្រួលក្នុងការអនុវត្តការងារជំនាញរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។ *សុទ្ធី*

# 2013 គ្រោះថ្នាក់ចរាចរណ៍កើតឡើង 403 លើក កើន 78 លើក ស្មើ 24%

## ក្នុងនោះមូលហេតុស្រវឹងមាន 48 ករណី

យោងរបាយការណ៍របស់នាយកដ្ឋានសណ្ដាប់ធ្នាប់ក្រសួងមហាផ្ទៃបានឱ្យដឹងថា : គិតចាប់ពីថ្ងៃទី១១ វិច្ឆិកា ដល់១០ ធ្នូ ឆ្នាំ២០១៣ (រយៈ ពេល១ខែ) គ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេសកើតឡើងចំនួន៤០៣លើក មនុស្សរងគ្រោះចំនួន៨៨២នាក់  ក្នុងនោះស្លាប់មនុស្ស ១៨៥នាក់ របួសធ្ងន់៤១៨នាក់ របួសស្រាល ២៧៩នាក់ ។ ខូចខាតយានយន្តមានម៉ូតូ៣៩៩ គ្រឿង រថយន្តធុនតូច១៥៣គ្រឿង រថយន្តធុនធំ៦៥គ្រឿង និងយានយន្តផ្សេង៧៤៣គ្រឿង ប៉ះពាល់អ្នកថ្មើរជើង៤៩នាក់ មិនពាក់មួកសុវត្ថិភាពពេលមានគ្រោះថ្នាក់២៧៨នាក់ ។

បើប្រៀបធៀបទៅនឹងខែវិច្ឆិកា ២០១៣ កន្លងទៅនេះ ឃើញថាចំនួនគ្រោះថ្នាក់មានការកើនឡើងចំនួន៧៨លើក ស្មើ២៤% ចំនួនអ្នកស្លាប់កើន៦២នាក់ ស្មើ៥០% ចំនួនអ្នក



របួសធ្ងន់កើន១០៩នាក់ ស្មើ៣៥% ចំនួនអ្នករបួសស្រាលកើន៨៨នាក់ ស្មើ៤៦% ។ ខូចខាតម៉ូតូកើន៦១គ្រឿង ស្មើ១៨% រថយន្តធុនតូចកើន១៨គ្រឿង ស្មើ១៣% រថយន្តធុនធំកើន ១៦គ្រឿង ស្មើ៣៣% និងយានយន្តផ្សេងៗ កើន១៥គ្រឿង ស្មើ៥៤% ប៉ះពាល់អ្នកថ្មើរជើងកើន៩នាក់ ស្មើ២៣% មិនពាក់មួកសុវត្ថិភាពពេលគ្រោះថ្នាក់កើន៨៣នាក់ ស្មើ៤៣% ។

ចំពោះមូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍ គឺបណ្ដាលមកពីល្មើសល្បឿន១៦៨ករណី មិនគោរពសិទ្ធិអាទិភាព៥១ករណី មិនប្រកាន់ស្ដាំ ២៩ករណី ប្រជែងគ្រោះថ្នាក់៤០ករណី បត់ឆ្វេង-ស្ដាំប្រហែស២៨ករណី ស្រវឹង៤៨ករណី បញ្ហាសុខភាព៧ករណី ករណីផ្សេងៗ៨ករណី ។



សកម្មភាពគ្រោះថ្នាក់ចរាចរណ៍ដែលបានកើតឡើងនាពេលកន្លងមក

គួរកត់សម្គាល់ថា ក្នុងរយៈពេលពេញ១ខែនេះ នៅទូទាំងប្រទេស បណ្ដាខេត្ត ដែលមានកំណើនអត្រាគ្រោះថ្នាក់ចរាចរណ៍ខ្ពស់ជាងគេ គឺរាជធានីភ្នំពេញ ខេត្តតាកែវ និងខេត្តកណ្ដាល ។

-**រាជធានីភ្នំពេញ** : គ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន៧១លើក មនុស្សរងគ្រោះចំនួន៩០នាក់ ក្នុងនោះស្លាប់មនុស្សចំនួន១៤នាក់ របួសធ្ងន់ចំនួន៦១នាក់ របួសស្រាលចំនួន ១៥នាក់ ។

-**ខេត្តកណ្ដាល** : គ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន៣១លើក មនុស្សរងគ្រោះចំនួន៩២នាក់ ក្នុងនោះស្លាប់មនុស្សចំនួន២៦នាក់ របួសធ្ងន់ចំនួន៣៥នាក់ របួសស្រាលចំនួន ៣១នាក់ ។

-**ខេត្តតាកែវ** : គ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន២៨លើក មនុស្សរងគ្រោះចំនួន៦៣នាក់ ក្នុងនោះស្លាប់មនុស្សចំនួន៩នាក់ របួសធ្ងន់ចំនួន៣២នាក់ របួសស្រាលចំនួន ២២នាក់ ។l *ណារ៉ា* .

22/5/23, 10:12 AM

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ០០៤ ៦៦៨

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានភស្តុភារ & ហិរញ្ញវត្ថុ
នាយកដ្ឋានថវិកា
ចូល
លេខ ០៣៣៧
ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨
ម៉ោង ៨

# បទបញ្ជា

## ស្តីពី

## ការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ

ស្ថិតក្នុងគោលបំណងដើម្បីជម្រុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឈានទៅសម្រេចឲ្យបាននូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយ ធានាបានគណនេយ្យភាព សមធម៌ យុត្តិធម៌ក្នុងការបើកផ្តល់ទាំងប្រាក់បៀវត្ស និងសម្ភារៈ បរិក្ខារជូនដល់កងកម្លាំងនគរបាលជាតិ និងមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ឲ្យបានល្អប្រសើរ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខដឹកនាំ ។

ចំពោះមុខនេះ ក្រសួងមហាផ្ទៃ ធ្វើការណែនាំដល់ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ បណ្ឌិត្យសភានគរបាលកម្ពុជា អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយកដ្ឋានពន្ធនាគារ ក្រុមប្រឹក្សានីតិកម្ម នាយកដ្ឋានសវនកម្មផ្ទៃក្នុង អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងគ្រប់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដូចតទៅ ៖

១- ត្រូវណែនាំដល់មន្ត្រីបំពេញភារកិច្ចពាក់ព័ន្ធការងារគណនេយ្យ និងបេឡាករដែលមានភារកិច្ចបើកប្រាក់បៀវត្សជូនដល់មន្ត្រីក្នុងអង្គភាពនីមួយៗឲ្យខិតខំយកចិត្តទុកដាក់រួសរាន់អនុវត្តបានទាន់ពេលវេលា និងគ្រប់ចំនួន ។

ត្រូវជៀសវាងដាច់ខាតនូវការកាត់យកភាគណាមួយនៃបៀវត្ស ទោះបីជា **តិច ឬ ច្រើន** ដើម្បីយកទៅបម្រើក្នុងបុព្វហេតុណាក៏ដោយ រាប់ទាំងការជួយសង្គម អំពើមនុស្សធម៌ ការអភិវឌ្ឍអង្គភាព ។ល។

២- ចំពោះមន្ត្រីនគរបាលជាតិ អនុញ្ញាតឲ្យបង់វិភាគទានជាប្រចាំខែសម្រាប់សមាគមមិត្តនគរបាលស្របទៅតាមលក្ខន្តិកៈដែលសម្រេចដោយមហាសន្និបាតរបស់សមាគមមិត្តនគរបាល ។

ចំពោះមន្ត្រីរាជការស៊ីវិល អនុញ្ញាតឲ្យបង់វិភាគទានជាប្រចាំខែតាមលក្ខន្តិកៈដែលសម្រេចដោយសមាគមមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ ។

៣- ប្រគល់ភារកិច្ចជូនអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីសហការណ៍ធ្វើការតាមដានជាប្រចាំដល់គ្រប់នាយកដ្ឋានអង្គភាព គ្រប់សាលារាជធានី-ខេត្ត គ្រប់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ក្រោមឱវាទក្រសួងមហាផ្ទៃលើការអនុវត្តបទបញ្ជានេះ។



https://online.fliphtml5.com/vhqfg/gmza/
Page 12 of 53

ក្នុងករណីមានប្រធានអង្គភាព ឬ មន្ត្រីជំនាញពាក់ព័ន្ធ បានប្រព្រឹត្តល្មើសផ្ទុយពីបទបញ្ជាខាងលើ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ ដើម្បីសុំគោលការណ៍អនុវត្តវិន័យរដ្ឋបាល ។ ក្នុងករណីការប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

ទទួលបានបទបញ្ជានេះ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋាន-អង្គភាពទាំងអស់ចំណុះក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ស្នងការនគរបាលរាជធានី-ខេត្ត ត្រូវអនុវត្តតាមបទបញ្ជានេះដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

*កន្លែងទទួល ៖*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
  *"ដើម្បីជូនជ្រាប"*
- *ឯកសារ-កាលប្បវត្តិ*

តមកពីទំព័រ ២១

**សារាចរលេខ០៦ របស់រាជរដ្ឋាភិបាល...**

ក្នុងការរក្សាផលប្រយោជន៍នៃការឡើងថ្នាក់ឋានន្តរស័ក្តិជូនមន្ត្រីរាជការដែលកន្លងមក ការដំឡើងថ្នាក់តាមវេនជ្រើសរើស និងតាមវេនអតីតភាពដល់មន្ត្រីរាជការមានភាពយឺតយ៉ាវ ឬខកខានដែលធ្វើឱ្យមន្ត្រីរាជការខាតបង់ផលប្រយោជន៍នៃការទទួលបានប្រាក់បៀវត្សរ៍មូលដ្ឋានតាមអតីតភាពរបស់ខ្លួន។ ក្នុងនោះ សារាចរលេខ ០៦ ខាងលើក៏បានកំណត់ផងដែរ អំពីលក្ខខណ្ឌមួយចំនួនក្នុងការធ្វើនិយ័តកម្មថ្នាក់ឋានន្តរស័ក្តិដល់មន្ត្រីរាជការអនុវត្តដូចខាងក្រោម ៖



ឯកឧត្តម សក់ សេដ្ឋា អញ្ជើញជាអធិបតីក្នុងពិធី

១. ចំពោះមន្ត្រីរាជការដែលត្រូវបានអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមទៅបំពេញការងារជាអ្នកតំណាងរាស្ត្រ សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សាជំនួយការ សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគិតរយៈពេល២ឆ្នាំសម្រាប់ផ្តល់ជូនមួយថ្នាក់។

២.មន្ត្រីរាជការស៊ីវិលកំពុងបម្រើការងារត្រូវគិតរយៈពេល៣ឆ្នាំនឹងត្រូវបានផ្តល់ជូន១ថ្នាក់។ ដោយឡែកចំនួនឆ្នាំដែលនៅសល់ពីការគណនាខាងលើនេះរយៈពេល២ឆ្នាំនឹងត្រូវផ្តល់ជូន១ថ្នាក់ បើរយៈពេលតិចជាង២ឆ្នាំត្រូវគិតទៅក្នុងអតីតភាពសម្រាប់ការដំឡើងថ្នាក់តាមវេនប្រចាំឆ្នាំខាងមុខ។



ទិដ្ឋភាពរួមក្នុងពិធី

ចំណែកលិខិតលេខ ៣៩៣៨ មស.ត្ររ របស់ក្រសួងមុខងារសាធារណៈជានីតិវិធីក្នុងការដំឡើងថ្នាក់ និងការធ្វើនិយ័តកម្មថ្នាក់ឋានន្តរស័ក្តិតាមអតីតភាពការងារជូនមន្ត្រីរាជការរបស់ក្រសួងស្ថាប័ននីមួយៗ គឺត្រូវបំពេញបែបបទនិងរាយនាមមន្ត្រីរាជការស៊ីវិលដែលបានស្នើសុំធ្វើនិយ័តកម្មថ្នាក់ឋានន្តរស័ក្តិឱ្យបានច្បាស់លាស់គ្រប់ចំនួនតាមការកំណត់ និងតាមរយៈការរៀបចំជាបញ្ជីរួម ដែលមានគំរូស្រាប់ដើម្បីមានព័ត៌មានគ្រប់គ្រាន់ពីស្ថានភាពក្របខណ្ឌឋានន្តរស័ក្តិរបស់មន្ត្រីរាជការ។ ហើយអង្គភាពចំណុះក្រសួងមហាផ្ទៃ រាជធានី-ខេត្តនីមួយៗត្រូវបញ្ចប់ដំណើរការធ្វើនិយ័តកម្មថ្នាក់ឋានន្តរស័ក្តិ និងការដំឡើងថ្នាក់ឆ្នាំ២០១៤ ឱ្យបានរួចរាល់យ៉ាងយូរដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៣ ដើម្បីងាយស្រួលដល់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានអាចមានពេលវេលាគ្រប់គ្រាន់សម្រាប់បញ្ជូនសំណុំលិខិតខាងលើទៅក្រសួងមុខងារសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤។



លោក លឹម សុខគូ

ក្នុងកិច្ចប្រជុំខាងលើនោះដែរ អង្គប្រជុំទាំងមូលក៏បានអានប្រកាសនិងលិខិតបង្គាប់ការរបស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតគណៈកម្មការចំណាត់ថ្នាក់ក្រសួងមហាផ្ទៃ និងក្រុមការងារនិយ័តកម្មថ្នាក់ឋានន្តរស័ក្តិ អំពីតួនាទី ភារកិច្ច និងសមាសភាពរបស់មន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផងដែរ ដើម្បីជំរុញការងារខាងលើឱ្យមានភាពរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ៕ *ភ័ស្ត*

22/5/23, 10:12 AM

**តមកពីទំព័រ ៤៦**

**វេទិការដ្ឋាភិបាលលើកទី១០ និងសមាគម...**

-ប្រព័ន្ធយុត្តិធម៌

-ប្រជាធិបតេយ្យ

-កម្មសិទ្ធិដីធ្លីស្របច្បាប់របស់ប្រជាពលរដ្ឋ។

អញ្ជើញមានប្រសាសន៍ក្នុងកម្មវិធីនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានបញ្ជាក់ថា : វេទិកានេះបានផ្តល់ឱកាសឱ្យបណ្តាប្រតិភូតំណាងរដ្ឋាភិបាលចូលរួម និងសមត្ថកិច្ចជំនាញចែករំលែកព័ត៌មាន ស្វែងយល់ដកស្រង់បទពិសោធន៍ផ្លាស់ប្តូរយោបល់ និងវិធីសាស្ត្រអនុវត្តនានាពីគ្នាទៅវិញទៅមក ដើម្បីជាប្រយោជន៍ដល់ការគ្រប់គ្រងការចុះបញ្ជីប្រជាជន និងអត្តសញ្ញាណផ្សេងៗប្រកបដោយប្រសិទ្ធភាពខ្ពស់។ បន្ថែមពីនេះវាក៏ជាពេលវេលាដ៏ល្អ ដើម្បីរឹតចំណងមេត្រីភាពឱ្យកាន់តែមានភាពស្និទ្ធស្នាលរវាងគ្នានិងគ្នាមួយកម្រិតថែមទៀត។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី មានប្រសាសន៍សង្កត់ធ្ងន់ថា : ស្របពេលនឹងការឈានជិតមកដល់នូវការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននាពេលខាងមុខនេះ ការចុះបញ្ជីប្រជាជននិងគ្រប់គ្រងអត្តសញ្ញាណផ្សេងៗឱ្យបានត្រឹមត្រូវច្បាស់លាស់ពិតជា **ផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រងលំហូរប្រជាជន ការធ្វើចរាចរ និងមធ្យោបាយដឹកជញ្ជូនទំនិញគ្រប់ប្រភេទ**។ តែទន្ទឹមនេះ យើងក៏មិនមើលរំលងនូវបញ្ហាប្រឈមដែលអាចគំរាមកំហែងដល់វិស័យសន្តិសុខទាំងក្នុងប្រទេស ក្នុងតំបន់ និងសកលលោកទាំងមូល រួមមានជាអាទិ៍ : **ការធ្វើអន្តោប្រវេសន៍ ការជួញដូរមនុស្សខុសច្បាប់ អំពើភេរវកម្ម ការជួញដូរគ្រឿងញៀន និងការដឹកជញ្ជូនទំនិញគេចពន្ធជាដើម ។ល។** បញ្ហាទាំងអស់នេះគឺជាហានិភ័យ ដែលអាចជះឥទ្ធិពលជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ដំណើរការសេដ្ឋកិច្ចសន្តិសុខ ស្ថេរភាពនៅក្នុងតំបន់និងសកលលោកទាំងមូល។ បច្ចុប្បន្ននេះ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងមហាផ្ទៃបានកំណត់យ៉ាងច្បាស់លាស់នូវទិសដៅ និងវិធានការអនុវត្តរបស់ខ្លួនក្នុងការគ្រប់គ្រងការចុះបញ្ជី និងធ្វើអត្តសញ្ញាណផ្សេងៗជូនប្រជាពលរដ្ឋប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។ ហើយកន្លងទៅថ្មីៗនេះប្រទេសកម្ពុជាបាននិងកំពុងវិវត្តខ្លួនពីការប្រើប្រាស់អត្តសញ្ញាណប័ណ្ណធម្មតាជំនាន់ទី៣ ទៅជាអត្តសញ្ញាណប័ណ្ណអេឡិចត្រូនិកជំនាន់ទី៤ ដែលអនុលោមតាមបទដ្ឋានអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ អៃ ឃេ អូ (**International Civil Aviation Orgarization**) អំពីគុណភាព និងប្រព័ន្ធសន្តិសុខអត្តសញ្ញាណប័ណ្ណអេឡិចត្រូនិក។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានមានប្រសាសន៍សង្កត់ធ្ងន់ទៀតថា : ប្រទេសកម្ពុជា ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍមួយចំនួនទៀតពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីរៀបចំប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីប្រជាជន និងអត្តសញ្ញាណនេះឱ្យមានលក្ខណៈសម្បត្តិ និងបទដ្ឋានសមស្របតាមស្តង់ដារអន្តរជាតិទាំងស្រុងនៅឡើយទេ ដោយសារកង្វះខាតនូវធនធានមនុស្ស មធ្យោបាយ និងបច្ចេកទេស។ ក្នុងន័យនេះដែរ ដើម្បីជំរុញឱ្យដំណើរការនៃការប្រើប្រាស់អត្តសញ្ញាណអេឡិចត្រូនិកប្រកបដោយគុណភាពខ្ពស់ និងប្រសិទ្ធភាពខ្ពស់ស្របតាមស្តង់ដារបច្ចេកវិទ្យាត្រឹមត្រូវ ខ្ញុំសង្ឃឹមថាប្រទេសជាមិត្ត និងសមាគមស្មាតកាតដែលមានជំនាញ និងបទពិសោធន៍ច្បាស់លាស់អាចធ្វើការចែករំលែកនូវអ្វីដែលជាតម្រូវការជាក់ស្តែងដល់គ្នាទៅវិញទៅមក ដើម្បីដោះស្រាយនូវរាល់បញ្ហាប្រឈមនានាដែលធ្លាប់ជួបប្រទះនាពេលកន្លងមក ៕ *លីដា*



**តមកពីទំព័រ ១៥**

**២០១៤ ជំរុញការងារទប់ស្កាត់ កាត់បន្ថយ...**

ភោគ **ព្រោះវត្ថុតាងមួយចំនួនត្រូវជនល្មើសយកទៅទុកនៅកន្លែងទាំងនោះ។**

ចំណែកបញ្ហាចុងក្រោយគឺការកសាងសំណុំរឿងរបស់មន្ត្រីនគរបាលព្រហ្មទណ្ឌនៅមានកម្រិតហេតុដូចនេះហើយ ទើបធ្វើឱ្យបទល្មើសខ្លះមានចន្លោះប្រហោងក្នុងកា រ កសាងសំណុំរឿងបញ្ជូនទៅតុលាការ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ក់ ជីតូ** ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ បានបញ្ជាក់ផងដែរថា ៖ មន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវតែពង្រឹង និងអភិវឌ្ឍន៍ខ្លួនឱ្យកាន់តែមានសមត្ថភាពល្អប្រសើរតាមកាលៈទេសៈនីមួយៗ តាមរយៈការសិក្សារៀនសូត្រ ស្វែងយល់ពីជំនាញរបស់ខ្លួនឱ្យបានច្បាស់លាស់តាមច្បាប់កំណត់ ពោលគឺក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដទៃទៀតដែលពាក់ព័ន្ធ ដើម្បីជំរុញឱ្យដំណើរការកសាងសំណុំរឿងមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងទទួលជោគជ័យនៅដំណាក់កាលតុលាការ។

ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក **អាន សុខន** បានបញ្ជាក់ថា ៖ ដោយសារតែបទល្មើសកើនឡើងដូចនេះ ចាំបាច់ការិយាល័យទាំងអស់ត្រូវតែពិនិត្យមើលអំពីតួនាទី និង ភារកិច្ចរបស់ខ្លួនឱ្យបានហ្មត់ចត់ ថាតើការងារមួយណាជាអាទិភាព ដែលត្រូវធ្វើមុនទៅតាមជំនាញរបស់ខ្លួនឱ្យបានល្អប្រសើរ។ បានន័យថា ៖ ទោះមានភារកិច្ចជាប់រវល់នឹងការការពារបាតុកម្មក៏ដោយ ក៏មន្ត្រីនគរបាលព្រហ្មទណ្ឌទាំងអស់ចាំបាច់ត្រូវពិនិត្យ និងយកចិត្តទុកដាក់ចំពោះការងារជំនាញប្រចាំថ្ងៃរបស់ខ្លួនជាចម្បងផងដែរ។ ដោយឡែកចំពោះការពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាលក្នុងការកសាងសំណុំរឿងទៅតុលាការឱ្យមានប្រសិទ្ធភាពនោះ ឯកឧត្តម ឧត្តមសេនីយ៍ឯក **អាន សុខន** គាំទ្រឱ្យមានវគ្គបណ្តុះបណ្តាលលើជំនាញរបស់ខ្លួននៅពេលណាមួយដែលសមស្រប ៕ *ពុទ្ធារិទ្ធិ*

https://online.fliphtml5.com/vhqfg/gmza/

តមកពីទំព័រ ១៧

### ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង : "...

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានមានប្រសាសន៍បញ្ជាក់ទៀតថា : ទោះបីជាយ៉ាងនេះក្តី ខ្ញុំសូមគូសបញ្ជាក់ឡើងវិញសាជាថ្មីថាគណបក្សប្រជាជនកម្ពុជារក្សាជំហរនយោបាយយ៉ាងខ្ជាប់ខ្ជួននូវសុច្ឆន្ទៈដ៏ពិតប្រាកដ និងស្មោះសរក្នុងការជួបចរចាគ្រប់កម្រិតជាមួយគណបក្សសង្គ្រោះជាតិសំដៅដោះស្រាយបញ្ហាដែលមិនទាន់បានស្រុះស្រួលជាមួយគ្នា **ដើម្បីគណបក្សយើងទាំងពីររួមគ្នាបម្រើផលប្រយោជន៍ ដ៏ឧត្តុង្គឧត្តមរបស់ប្រជាជាតិ និងប្រជាជនកម្ពុជា**។ ទន្ទឹមនេះផ្អែកតាមសេចក្តីប្រកាសរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខាងនយោបាយយ៉ាងមុតមាំ ដើម្បីជំរុញ **ដំណើរការកែទម្រង់ការបោះឆ្នោតដោយចាប់ផ្តើមពីការរៀបចំសិក្ខាសាលាជាតិនាចុងខែធ្នូ ឆ្នាំ២០១៣ ឬក្នុងអំឡុងខែមករា ឆ្នាំ២០១៤ ខាងមុខនេះ**។ សិក្ខាសាលាជាតិនេះនឹងធ្វើការប្រមូលផ្តុំនូវធាតុចូល ដែលជាអនុសាសន៍ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដែលពាក់ព័ន្ធនឹងការកែទម្រង់ការបោះឆ្នោតនៅកម្ពុជា។ អាស្រ័យហេតុនេះខ្ញុំសូមអំពាវនាវដល់គណបក្សនយោបាយអង្គការសង្គមស៊ីវិលអង្គការជាតិអន្តរជាតិ និងអ្នកពាក់ព័ន្ធនានាមេត្តាត្រៀមលក្ខណៈចូលរួមនិងចូលរួមក្នុងសិក្ខាសាលាជាតិនេះប្រកបដោយលក្ខណៈស្ថាបនា ដើម្បីយើងស្វះស្វែងរកការពិភាក្សាការឯកភាពស្រុះស្រួលគ្នាក្នុងការកែទម្រង់ការបោះឆ្នោតនៅកម្ពុជាជាបន្តទៀត។ **ខ្ញុំសូមគូសបញ្ជាក់ជូនថាប្រជាពលរដ្ឋ និងពេលវេលាកំពុងរង់ចាំយើង**។ ហេតុនេះយើងជាអ្នកទទួលបានការគាំទ្រពីប្រជាពលរដ្ឋត្រូវប្រើប្រាស់ឱកាស និងពេលវេលារបស់យើង ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋឱ្យបានល្អបំផុត ៕ *សុខគីម*



តមកពីទំព័រ ២៥

### ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អនុញ្ញាត...

ប្រជាជនកម្ពុជាជាមួយនឹងគណបក្សសង្គ្រោះជាតិ ដែលទទួលបរាជ័យនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានធ្វើការកត់សម្គាល់ថា ៖ **បញ្ហាគឺមិនមែនផ្តើមចេញពីគណបក្សប្រជាជនកម្ពុជានោះទេគឺបណ្តាលមកពីបញ្ហាផ្ទៃក្នុងរបស់គណបក្សសង្គ្រោះជាតិដែលមិនឯកភាពគ្នា**។ លើសពីនេះទៅទៀត ការរៀបចំបោះឆ្នោតនៅកម្ពុជាកន្លងមកនេះ ត្រូវបានសហគមន៍អន្តជាតិវាយតម្លៃថា ៖ មានលក្ខណៈសន្តិភាព សេរី និងមិនមានអំពើហិង្សា។ **ដូចនេះអ្វីៗដែលគណបក្សប្រឆាំងបានលើកឡើងគឺផ្ទុយពីការពិតទាំងស្រុង**។

មានប្រសាសន៍ឆ្លើយតបវិញ លោកជំទាវ **អេនណា ម៉ាយហាលហ្គាដ** បានជម្រាបជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រីជ្រាបថា ៖ បេសកកម្មការងាររបស់លោកជំទាវនៅព្រះរាជាណាចក្រកម្ពុជាគឺមិនត្រឹមតែពង្រឹងទំនាក់ទំនងគោលនយោបាយការទូតរវាងប្រទេសទាំងពីរប៉ុណ្ណោះទេ នៅក្នុងបេសកកម្មនេះ លោកជំទាវមានផែនការពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកពាណិជ្ជកម្មទ្វេភាគីបន្ថែមទៀតផង។ បញ្ហានេះ កន្លងមក លោកជំទាវក៏បានជួបពិភាក្សាជាមួយនឹងក្រុមហ៊ុនធំៗរបស់ស៊ុយអែត អំពីស្ថានភាពក្នុងការពង្រឹងភាពជាដៃគូជំនួញនៅក្នុងព្រះរាជាណាចក្រកម្ពុជារួចហើយ។

លោកជំទាវ **អេនណា ម៉ាយហាលហ្គាដ** បានបញ្ជាក់បន្ថែមទៀតថា ៖ រាជរដ្ឋាភិបាលនៃប្រទេសស៊ុយអែតបានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា ទៅលើវិស័យអភិបាលកិច្ចល្អ ការកែទម្រង់វិស័យបរិស្ថាន វិស័យអប់រំ ហើយនិងវិស័យជំនួញថែមទៀត។ មិនតែប៉ុណ្ណោះ ប្រទេសស៊ុយអែតក៏បានចូលរួមយ៉ាងសកម្មនៅក្នុងសាលាក្តីខ្មែរក្រហមផងដែរ។

ពាក់ព័ន្ធនឹងស្ថានភាពនយោបាយនៅកម្ពុជា លោកជំទាវ **អេនណា ម៉ាយហាលហ្គាដ** បានមានប្រសាសន៍បញ្ជាក់ថា ៖ លោកជំទាវបានធ្វើការតាមដានយ៉ាងហ្មត់ចត់អំពីស្ថានភាពនយោបាយនៅកម្ពុជាហើយ លោកជំទាវបានធ្វើការវាយតម្លៃខ្ពស់ចំពោះការដឹកនាំដ៏ល្អប្រសើរ និង ឈ្លាសវៃរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសក្នុងអំឡុងពេលដែលគណបក្សសង្គ្រោះជាតិធ្វើមហាបាតុកម្មនាពេលកន្លងមក គឺបានឆ្លុះបញ្ចាំងឱ្យឃើញថារាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់ និង ព្យាយាមដោះស្រាយដោយសន្តិវិធី។ ដោយឡែកពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងនគរបាលស៊ុយអែតនិងនគរបាលកម្ពុជា លោកជំទាវកំពុងមានផែនការដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងនគរបាលទាំងពីរឲ្យកាន់តែជិតស្និទ្ធថែមទៀត ។

គួរបញ្ជាក់ដែរថា ៖ ពាក់ព័ន្ធនឹងការងារពង្រឹងកិច្ចសហប្រតិបត្តិការរវាងនគរបាលនៃព្រះរាជាណាចក្រកម្ពុជានិងនគរបាលនៃប្រទេសស៊ុយអែតនេះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានសម្តែងនូវការស្វាគមន៍គាំទ្រចំពោះគម្រោងផែនការនេះ ហើយឯកឧត្តមក៏បានស្នើឱ្យមានការជួបប្រជុំរវាងមន្ត្រីជំនាញបច្ចេកទេសនគរបាលទាំងពីរដើម្បីឈានទៅដល់ការចុះកិច្ចព្រមព្រៀងជាមួយគ្នានៅពេលខាងមុខ ៕ *ពុទ្ធារិទ្ធិ*

តមកពីទំព័រ ០៧

**២០១៤ ជំរុញការងារទប់ស្កាត់ កាត់បន្ថយ...**

មានចំនួន៤០ករណី កើន៥ ស្មើនឹង១២,៥០ ភាគរយ ខេត្តព្រះវិហារមានចំនួន២៥ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន២០ករណី កើន៥ ស្មើនឹង២៥% ខេត្តកំពតមានចំនួន ៣៤ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន ២៦ករណី កើន៨ ស្មើនឹង៣០,៧៦% ខេត្តបន្ទាយមានជ័យមាន១៦ករណី ធៀបនឹងឆ្នាំ២០១២ មាន១៥ករណី កើន១ ស្មើនឹង ៦,៦៦% ខេត្តកំពង់ធំមាន២៨ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន២៧ករណី កើន១ ស្មើនឹង៣,៥៧% និងខេត្តប៉ៃលិនមានចំនួន ១៣ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន ១២ករណី កើន១ ស្មើនឹង៨,៣៣ភាគរយ។ ចំណែកបទល្មើសមជ្ឈឹមកើតឡើងរួមចំនួន ១.៨៥៣ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន១.៧២៥ករណី កើន១២៨ ស្មើនឹង ៧,៤២ភាគរយ។

គួរកត់សម្គាល់ថា ៖ បទល្មើសជារួមនៅបណ្តាខេត្តភាគច្រើនមានតួលេខថយចុះ ដោយឡែកនៅរាជធានីភ្នំពេញមានតួលេខបទល្មើសកើនឡើងគួរកត់សម្គាល់ ក្នុងនោះ បទល្មើសមជ្ឈឹមសរុបចំនួន៨១០ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន៤៣២ករណី កើន ៣៧៨ករណី ស្មើនឹង៨៧,៥០%។ បទល្មើសឧក្រិដ្ឋកើតមាន២០៤ករណី ធៀបនឹងឆ្នាំ ២០១២ មានចំនួន១៣៦ករណី កើន៦៨ ស្មើនឹង៥០% បទល្មើសមជ្ឈឹមកើតមានចំនួន ៦០៦ករណី ធៀបនឹងឆ្នាំ២០១២ មានចំនួន ២៩៦ករណីកើន៣១០ស្មើនឹង១០៤,៧២ ភាគរយ។ ចំពោះលទ្ធផលបង្ក្រាបជារួមមានចំនួន១.៦០៧ករណី ឃាត់ខ្លួនបាន ២.២៤០នាក់។

ដោយឡែក ចំពោះទិសដៅសំខាន់ៗសម្រាប់អនុវត្តក្នុងឆ្នាំ២០១៤មានជាអាទិ៍ ៖

១.បន្តអនុវត្តផែនការរបស់ក្រសួងមហាផ្ទៃស្តីពីការចាត់តាំងគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ដោយពង្រឹងនគរបាលប៉ុស្តិ៍រដ្ឋបាល កម្លាំងជំនាញថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី-ខេត្តធ្វើជាស្នូលឱ្យយន្តការនេះ។

២.សហការជាមួយគម្រោង **CCJAP** តាមដានប្រព័ន្ធទិន្នន័យបទល្មើសកត់ត្រាក្នុងកុំព្យូទ័រនៅតាមរាជធានី-ខេត្តទូទាំងប្រទេស ដើម្បីទាញចេញនូវការវិភាគវាយតម្លៃស្ថានភាពបទល្មើសប្រចាំខែនីមួយៗ និងផ្តើមស្នើគោលការណ៍ដាក់ចេញវិធានការបង្ការ និងបង្ក្រាបជាក់ស្តែងតាមភូមិសាស្ត្ររាជធានី-ខេត្តនីមួយៗ។ ក្នុងនោះគួរប្រមូលផ្តុំឱ្យបាននូវទិន្នន័យមុខសញ្ញាបង្ក្រាបចាប់ឃាត់ខ្លួនបានផងដែរ។

៣.បច្ចុប្បន្នភាពនូវរាល់មុខសញ្ញាដែល



**ទិដ្ឋភាពរួមក្នុងពិធី**

បានចុះបញ្ជីគ្រប់គ្រងនៅតាមរាជធានី-ខេត្ត សំដៅធ្វើឱ្យការងារតាមដានឃ្លាំមើលសកម្មភាពមុខសញ្ញាទាំងនេះផ្តល់ជាតម្រុយដល់ការស៊ើបអង្កេត ពិសេសបទល្មើសឧក្រិដ្ឋដែលមានដូចជា មុខសញ្ញាពិរុទ្ធជន ទណ្ឌិតដែលដោះលែងពីពន្ធនាគារ មុខសញ្ញាមានដីកាបង្គាប់ឱ្យចាប់ខ្លួន មុខសញ្ញាសេសសល់ក្នុងករណី និងមុខសញ្ញាកំពុងតស៊ូក្នុងករណី មុខសញ្ញាព្រហ្មទណ្ឌជាមូលដ្ឋាន និងមុខសញ្ញាក្រុមជនទំនើង។ល។និង។ល។

៤.ជំរុញដឹកនាំត្រួតពិនិត្យបង្កើនការងារទប់ស្កាត់ កាត់បន្ថយបទល្មើសក្នុងទូទាំងប្រទេសឱ្យមានការថយចុះពី១០ភាគរយ ទៅ២០ភាគរយ។

៥.ជំរុញដឹកនាំរាជធានី-ខេត្ត បន្តការស្រាវជ្រាវបង្ក្រាបមុខសញ្ញាមានដីកាបង្គាប់ឱ្យចាប់ខ្លួនមុខសញ្ញាសេសសល់ក្នុងករណីពិសេសបទឧក្រិដ្ឋពង្រឹងកិច្ចសហប្រតិបត្តិការបង្ក្រាបរាល់បទល្មើសដែលនឹងកើតមានក្នុងឆ្នាំ២០១៤ខាងមុខនេះ។

លោកឧត្តមសេនីយ៍ទោ **អ៊ិន ម៉ូរ៉ា** បានបញ្ជាក់ថា ៖ មូលហេតុដែលធ្វើឱ្យបទល្មើសកើនឡើងគឺ ៖

**បញ្ហាទី១**- បណ្តាលមកពីមុខសញ្ញាចាស់ដែលបានដោះលែងពីពន្ធនាគារគឺមិនបានទៅមូលដ្ឋានដើមរបស់ពួកគេនោះទេគឺពួកគេមានការចល័តទៅតាមបណ្តាខេត្តនៅតាមព្រំដែន និងនៅរាជធានីភ្នំពេញ។

**បញ្ហាទី២**-គឺបណ្តាលមកពីកម្លាំងនគរបាលយើងមួយចំនួនធំមានភារកិច្ចជាប់រវល់ជាមួយនឹងការបោះឆ្នោតថ្នាក់ជាតិនិងការពារការធ្វើបាតុកម្មរបស់គណបក្សប្រឆាំង ក៏ដូចជាកម្មកររោងចក្រ ហើយឆ្លៀតឱកាសនោះធ្វើឱ្យជនល្មើសឆ្លៀតបង្កើនសកម្មភាពរបស់វាផងដែរ។

**បញ្ហាទី៣**- បណ្តាលមកពីការលំហូរចូលនៃគ្រឿងញៀនតាមច្រកព្រំដែន ហើយជាពិសេសគឺពាក់ព័ន្ធទៅនឹងមុខរបរពិសេសពោលគឺកន្លែងដាក់បញ្ចាំ ឬកន្លែងទទួលប្រតិ

តទៅទំព័រ ១៣

តមកពីទំព័រ ៣៣

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង : "...**

និងសសើរថា "**ជារឝ្ចិយៈនៅដំណាក់កាលប្រជាធិបតេយ្យ**" ហើយការបោះឆ្នោតក្រោយៗមកទៀតនៅឆ្នាំ ២០០២, ២០០៣, ២០០៧, ២០០៨, ២០១២ ត្រូវបានវាយតម្លៃថា "**ល្អប្រសើរជាងការបោះឆ្នោតមុន**"។ សម្រាប់ដំណើរការរៀបចំការ



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង



ឯកឧត្តម អ៊ុំ សូស៊ី

បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដែលទើបតែបញ្ចប់ថ្មីៗនេះ ក៏ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអនុវត្ត ដោយអនុលោមទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រតិទិនការងារសម្រាប់ការបោះឆ្នោត។ ជាទូទៅការបោះឆ្នោតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ ក៏ត្រូវបានសាធារណមតិជាតិ និងអន្តរជាតិភាគច្រើនវាយតម្លៃថាបានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិភាព គ្មានអំពើហិង្សា ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ហើយដំណើរការដោះស្រាយបណ្តឹង និងត្រួតពិនិត្យលើរបាយការណ៍អំពីភាពមិនប្រក្រតីពាក់ព័ន្ធនឹងការបោះឆ្នោតក៏បានធ្វើឡើងប្រកបដោយតម្លាភាពត្រឹមត្រូវ និងយុត្តិធម៌។

ឯកឧត្តម **អ៊ុំ សូស៊ី** បានមានប្រសាសន៍បញ្ជាក់ទៀតថា : ចេញពីចំណុចខ្លាំង និងចំណុចខ្សោយ ដែលយើងទទួលបានខ្ញុំសូមដាក់ចេញនូវអនុសាសន៍មួយចំនួនដូចខាងក្រោម :

-ត្រូវពិនិត្យកែសម្រួលបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ពិសេសនីតិវិធីក្នុងការសម្អាតបញ្ជីបោះឆ្នោត ការកែតម្រូវឈ្មោះ និង ទិន្នន័យរបស់អ្នកបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោតឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់ត្រូវពង្រឹងលើកទឹកចិត្តដល់ក្រុមប្រឹក្សា និងស្មៀនឃុំ-សង្កាត់ក្នុងការអនុវត្តភារកិច្ចពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ដែល គ.ជ.ប បានធ្វើប្រតិភូកម្មអំណាចឱ្យ ពិសេសក្នុងការសម្អាតបញ្ជីបោះឆ្នោត ការកែតម្រូវឈ្មោះ និងទិន្នន័យរបស់អ្នកបោះឆ្នោត និងការពិនិត្យផ្ទៀងផ្ទាត់ឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមុនពេល គ.ជ.ប ផ្តល់សុពលភាពជាផ្លូវការដើម្បីកសាងបញ្ជីបោះឆ្នោតមួយ ដែលធានាបានទាំងបរិមាណគុណភាព និង មានបច្ចុប្បន្នភាព។



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង និងឯកឧត្តម អ៊ុំ សូស៊ី អញ្ជើញជាអធិបតីក្នុងអង្គពិធី

-មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវលើកកម្ពស់សមត្ថភាពយល់ដឹងបន្ថែមទៀតអំពីបទបញ្ជា និងនីតិវិធី ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោតនិងលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយ គ.ជ.ប ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព និងបញ្ចៀសបាននូវការចោទប្រកាន់ផ្សេងៗ។

-ត្រូវជំរុញការអប់រំប្រជាពលរដ្ឋ និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតឱ្យបានកាន់តែទូលំទូលាយដោយយកចិត្តទុកដាក់លើការផលិត និងការកែលម្អសម្ភារៈអប់រំអ្នកបោះឆ្នោត និងបង្កើនកិច្ចសហការល្អជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិក្នុងការងារអប់រំអ្នកបោះឆ្នោត។

-ត្រូវបន្តពង្រឹងទំនាក់ទំនងល្អជាមួយនឹងគ្រប់ស្ថាប័នពាក់ព័ន្ធក្នុងគោលបំណងស្នើសុំឱ្យមានកិច្ចសហការ និងការគាំទ្រក្នុងដំណើរការអនុវត្តន៍សិទ្ធអំណាចភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.ប។

-សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីជម្រុញការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិ

ខ្មែរដើម្បីចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត។

-ត្រូវបន្តពង្រឹងទំនាក់ទំនង និងកិច្ចសហការល្អ ក្នុងភាពជាដៃគូជាមួយអាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការរៀបចំការបោះឆ្នោត។

-ត្រូវជំរុញនិងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មពីគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកយកព័ត៌មានជាតិ-អន្តរជាតិក្នុងដំណើរការរៀបចំបោះឆ្នោត។

អញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានមានប្រសាសន៍បញ្ជាក់ថា : តាមបទពិសោធន៍ជាអន្តរជាតិមិនមានការបោះឆ្នោតណាមួយដែលប្រព្រឹត្តទៅបានល្អឥត ្ខ ះនោះឡើយ។ មានន័យថាគ្រប់ការបោះឆ្នោតនៅតាមប្រទេសនានាតែងតែជួបប្រទះការខ្វះខាតមួយចំនួនផ្នែកបច្ចេកទេស។ កង្វះខាតផ្នែកបច្ចេកទេស និងភាពមិនប្រក្រតីធ្ងន់ធ្ងរនៃការបោះឆ្នោតមានស្ថានភាពមិនដូចគ្នាឡើយ។ ឧទាហរណ៍ : ការចុះឈ្មោះបោះឆ្នោតដោយដៃជាមួយប្រព័ន្ធតម្រូវឱ្យអ្នកចុះឈ្មោះបោះឆ្នោតទៅបំពេញបែបបទចុះឈ្មោះដោយខ្លួនឯងផ្ទាល់ រមែងតែងតែមានការខ្វះខាតខ្លះៗដូចជាឈ្មោះស្ទួនការសរសេរទិន្នន័យអ្នកបោះឆ្នោតមិនបានត្រឹមត្រូវ ។ល។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** មានប្រសាសន៍បញ្ជាក់ទៀតថា : កន្លងមកមានការលើកឡើងថារដ្ឋសភា និងរាជរដ្ឋាភិបាល ដែលកើតចេញពីការបោះឆ្នោតជាសភា និងរាជរដ្ឋាភិបាលមិនស្របច្បាប់ជាសភាឯកបក្ស ។ល។ ករណីនេះ ខ្ញុំសូមគូសបញ្ជាក់ជូនថា ព្រះករុណា ព្រះមហាក្សត្រទ្រង់បានត្រាស់បង្គាប់កោះអញ្ជើញតំណាងរាស្ត្រជាប់ឆ្នោតទាំង១២៣រូប ដើម្បីចូលរួមបើកសម័យប្រជុំដំបូងនៃរដ្ឋសភា។ ប៉ុន្តែតំណាងរាស្ត្រជាប់ឆ្នោតមកពីគណបក្សសង្គ្រោះជាតិបានធ្វើពហិការមិនចូលរួម។ ផ្អែកតាមរដ្ឋធម្មនុញ្ញនិងយោងតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។ រដ្ឋសភាបានបន្តកិច្ចប្រជុំក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋ-សភា ដើម្បីប្រកាសសុពលភាពឈ្មោះអ្នកតំណាងរាស្ត្រជាប់ឆ្នោតទាំង១២៣រូប បិទផ្សាយក្នុងរដ្ឋសភា និងធ្វើការផ្សព្វផ្សាយជាសាធារណ។ សមាជិករដ្ឋសភាចំនួន៦៨រូបមកពីគណបក្សប្រជាជនកម្ពុជាបានចូលស្បថកាន់មុខតំណែង។ ចំពោះសមាជិករដ្ឋសភាចំនួន ៥៥រូប មកពីគណបក្សសង្គ្រោះជាតិបានធ្វើពហិការមិនទាន់បានស្បថដើម្បីកាន់មុខតំណែងនៅឡើយ។ ដោយយោងតាមការកែប្រែប្រព័ន្ធពី ២/៣ (ពីរភាគបី) មកជា៥០ភាគរយបូក១ ក្នុងការអនុម័តលើការរៀបចំក្បាលម៉ាស៊ីនរដ្ឋសភា និងសមាសភាពគណៈរដ្ឋមន្ត្រី រដ្ឋសភាមានសំឡេងគ្រប់គ្រាន់ ដើម្បីដំណើរការការងាររបស់ខ្លួនក្នុងការរៀបចំក្បាលម៉ាស៊ីនរដ្ឋ-សភា និងការបោះឆ្នោតទុកចិត្តសមាសភាពគណៈរដ្ឋមន្ត្រីតាមការផ្ទួរផ្តងពីនាយករដ្ឋមន្ត្រីដែលតែងតាំងដោយព្រះករុណាព្រះមហាក្សត្រស្របតាមការកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា សំដៅធានាប្រក្រតីភាពនិងនិរន្តរភាពនៃស្ថាប័នជាតិ។

ដូច្នេះរដ្ឋសភា និងរាជរដ្ឋាភិបាលបានបង្កើតឡើងស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន។ រដ្ឋសភាមានតំណាងរាស្ត្រជាប់ឆ្នោតមកពីគណបក្សចំនួនពីរ ដែលកើតចេញពីឆន្ទៈប្រជាពលរដ្ឋជាម្ចាស់ឆ្នោតគឺគណបក្សប្រជាជនកម្ពុជាទទួលបាន៦៨អាសនៈ រីឯគណបក្សសង្គ្រោះជាតិទទួលបាន៥៥អាសនៈ។ ប៉ុន្តែតំណាងរាស្ត្រជាប់ឆ្នោត៥៥រូបមកពីគណបក្សសង្គ្រោះជាតិមិនព្រមស្បថចូលកាន់មុខតំណែង ហើយបន្តធ្វើការទាមទារតវ៉ាចោទប្រកាន់ដើម្បីបម្រើគោលបំណងនយោបាយរបស់ខ្លួន ដែលជាសកម្មភាពផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានមានប្រសាសន៍សង្កត់ធ្ងន់ថា : ក្នុងពេលគណបក្សប្រជាជនកម្ពុជាបាននិងកំពុងស្វះស្វែងរកមធ្យោបាយតាមគ្រប់រូបភាព ក្នុងការជួបចរចាជាមួយគណបក្សសង្គ្រោះជាតិ ដើម្បីដោះស្រាយចំណុច ដែលមិនទាន់ស្រុះស្រួលជាមួយគ្នាគណបក្សសង្គ្រោះជាតិបានដាក់លក្ខខណ្ឌដោយស្នើសុំឱ្យសមាជិក គ.ជ.ប ទាំងអស់លាលែងពីមុខតំណែងដើម្បីបើកផ្លូវសម្រាប់ធ្វើការកែទម្រង់ការបោះឆ្នោតនាពេលខាងមុខ។ សំណើនេះគឺជាការបន្ថែមបញ្ហាឱ្យកាន់តែស្មុគស្មាញសាំញ៉ាំថែមទៀត ក្នុងការជួបចរចារវាងគណបក្សទាំងពីរ។ ខ្ញុំយល់ថាគណបក្សសង្គ្រោះជាតិប្រាកដជាយល់ច្បាស់ថាស្ថាប័ននិងសមាសភាពនៃស្ថាប័ន គ.ជ.ប ត្រូវបានធានាការពារដោយច្បាប់វាក្យខ័ណ្ឌទី៣ មាត្រា១៥ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថាការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិក គ.ជ.ប ជាសមត្ថកិច្ចរបស់រដ្ឋសភា។ ម្យ៉ាងទៀតការប្រើប្រាស់គោលបំណងនយោបាយដើម្បីដាក់សម្ពាធឱ្យមន្ត្រីនៃស្ថាប័នណាមួយលាឈប់ពីមុខតំណែងទាំងមិនមានកំហុស មិនត្រឹមតែជាសកម្មភាពខុសច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែសកម្មភាពនេះ គឺជាទង្វើប្រាសចាកពីមនសិការនិងតម្លៃនៃសីល-ធមិក្នុងសង្គម ព្រមទាំងបង្កើតឱ្យមានទម្លាប់មិនល្អក្នុងសង្គមប្រជាធិបតេយ្យ និងនីតិរដ្ឋថែមទៀត។

តទៅទំព័រ ១៤

# ជំរុញបើកវគ្គបំប៉នគ្រូបង្គោលស្តីពីការប្រយុទ្ធនឹង ជំងឺគ្រុនចាញ

# ដើម្បីឈានទៅលុបបំបាត់ជំងឺនេះនាឆ្នាំ2015

កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ នៅសណ្ឋាគារភ្នំពេញមានរៀបចំពិធីបើកវគ្គការអប់រំបំប៉នបន្ថែមប្រយុទ្ធនឹងជំងឺ



លោកឧត្តមសេនីយ៍ទោ ផា ណារ៉េត ប្រធាននាយកដ្ឋានសុខាភិបាល អញ្ជើញជាអធិបតីក្នុងពិធី

គ្រុនចាញ់ជូនដល់គ្រូបង្គោលក្នុងជួរកងកម្លាំងនគរបាលជាតិ ក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ចាន់ ចំនួថា** នាយករងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ លោក **ជេប វេន ហ៊ឺរឌេន (JAAP VAN HIERDEN)** នាយកអង្គការ **UNOPS** ប្រចាំនៅកម្ពុជា និងលោកឧត្តមសេនីយ៍ទោវេជ្ជបណ្ឌិត **ផា ណារ៉េត** ប្រធាននាយកដ្ឋានសុខាភិបាល ក្រសួងមហាផ្ទៃ។

លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ចាន់ ចំនួថា** បានបញ្ជាក់ជូនវគ្គបំប៉នជ្រាបថា : ១-ជំងឺគ្រុនចាញ់ ពិតជាកើតឡើងដោយសារមេរោគគ្រុនចាញ់ដែលចំលងដោយមូសដែកគោលញីខាំ។ ហេតុនេះមធ្យោបាយការពារគឺប្រើប្រាស់មុងជ្រលក់ថ្នាំឱ្យបានត្រឹមត្រូវគឺមានន័យថាត្រូវចូលសំរាន្តក្នុងមុងជ្រលក់ថ្នាំរាល់ពេលយប់កុំឱ្យមូសដែកគោលញីខាំ។ ២-ចំពោះអ្នកដែលរស់នៅក្នុងតំបន់គ្រុនចាញ់ ឬទើបនឹងត្រឡប់មកពីរកស៊ីនៅតំបន់គ្រុនចាញ់ បើមានសញ្ញាសង្ស័យជំងឺគ្រុនចាញ់ ពិសេសមានក្តៅខ្លួនប្រញាប់ស្វែងរកអ្នកណាដែលអាចធ្វើរោគវិនិច្ឆ័យនិងព្យាបាលឱ្យទាន់ពេលវេលា។ នៅគ្រប់ភូមិ ដែលប្រឈមនឹងជំងឺគ្រុនចាញ់ខ្ពស់សុទ្ធតែមានភ្នាក់ងារស្ម័គ្រចិត្តប្រយុទ្ធនឹងជំងឺគ្រុនចាញ់តាមភូមិ ព្រោះគេជាសមាជិកសហគមន៍ ដែលអាចជួសឈាមមើលបើឃើញថាមានមេរោគគ្រុនចាញ់គេមានឱសថសម្រាប់ព្យាបាលភ្លាម ហើយបើករណីឈឺធ្ងន់ ឬបើជាកុមារជាស្ត្រីមានផ្ទៃពោះ គេនឹងបញ្ជូនទៅមន្ទីរពេទ្យបានទាន់ពេលវេលា។ ៣-បើមានការពិនិត្យឈាមឃើញថាមានមេរោគគ្រុនចាញ់ត្រូវលេបថ្នាំឱ្យបានបីថ្ងៃ ដើម្បីប្រាកដថាពិតជាបានជាសះស្បើយពេញបរិបូរណ៍ពិតប្រាកដមែន។

ដោយឡែកកាលពីថ្ងៃទី១០ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ នៅស្នងការដ្ឋាននគរបាលខេត្តខេត្តសៀមរាប ប៉ៃលិន ពោធិ៍សាត់ ឧត្តរមានជ័យ ព្រះវិហារ កោះកុង និងខេត្តស្ទឹងត្រែង ក៏មានរៀបចំពិធីបើកវគ្គអប់រំសុខភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់ដល់អ្នកស្ម័គ្រចិត្តក្នុងជួរកងកម្លាំងនគរបាលផងដែរ។

លោកស្រីឧត្តមសេនីយ៍ត្រីវេជ្ជបណ្ឌិត **ប៊ុណ្ណ សំខាន់** អនុប្រធាននាយកដ្ឋានសុខាភិបាល ក្រសួងមហាផ្ទៃ បានបញ្ជាក់ឱ្យដឹងថា : ជារួមក្រុមការងារយើងទាំងអស់គ្នាបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការអប់រំសុខភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់នេះជូនបងប្អូនទាំងអស់ដែលរស់នៅក្នុងតំបន់គ្រុនចាញ់ឱ្យគាត់បានយល់ដឹងច្បាស់គ្រប់ៗគ្នា និងចេះការពារខ្លួនគ្រប់ៗគ្នា ដើម្បីកាត់បន្ថយអត្រាឈឺនិងអត្រាស្លាប់ដោយជំងឺគ្រុនចាញ់នេះឱ្យបានជាស្ថាពរនៅឆ្នាំ២០១៥ ស្របតាមទិសដៅ



សមាជិក -សមាជិកាចូលរួមក្នុងពិធី

ថ្នាក់ជាតិ។ ហើយនៅក្នុងឆ្នាំ២០១៤ខាងមុខនេះ យើងនឹងចុះធ្វើការបើកវគ្គបំប៉នបន្ថែម និងចុះអភិបាលកិច្ចដល់អ្នកស្ម័គ្រចិត្តតាមបណ្តាវរសេនាតូចនគរបាលការពារព្រំដែន និងអធិការដ្ឋាននគរបាលស្រុកក្នុងតំបន់ជំងឺគ្រុនចាញ់ទាំង ១១ខេត្តបន្តទៀត ៕ *បញ្ញា*

តមកពីទំព័រ ៤៤

**អគ្គស្នងការដ្ឋាននគរបាលជាតិកែសម្រួល...**

ដែលអានដោយឯកឧត្តម ឧត្តមសេនីយ៍ឯក ***ហ៊ូ សាគុណា*** ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែនបានបញ្ជាក់ថា : ត្រូវបានកែសម្រួលសមាសភាពគណៈបញ្ជាការស្រាលនគរបាលជាតិប្រចាំភូមិភាគទី៥ ដោយមានឯកឧត្តម



ឯកឧត្តម ឧត្តមសេនីយ៍ឯក ដាំ វុទ្ធី អគ្គស្នងការរងនគរបាលជាតិ

ឧត្តមសេនីយ៍ឯក ***ប្រាក់ ភារណារ៉ា*** ជាប្រធាន និងមានអនុប្រធានចំនួន១២រូប ព្រមទាំងមានសមាជិកចំនួន១៣ រូបទៀត ដើម្បីគ្រប់គ្រងបញ្ជាដឹកនាំគណៈបញ្ជាការស្រាលនគបាលជាតិប្រចាំភូមិភាគទី៥ និងវរសេនាតូចនគរបាលព្រំដែនគោកក្នុងទិសភូមិភាគទី៥ ដោយសហការជាមួយគណៈបញ្ជាការឯកភាពសមរភូមិមុខ ទិសយោធភូមិភាគទី៥ ក្នុងការការពារអធិបតេយ្យភាព បូរណភាពទឹកដី ធានារក្សាបានសន្តិសុខសណ្តាប់ធ្នាប់តាមបណ្តោយខ្សែបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រ ដែលខ្លួនទទួលខុសត្រូវ។



សមាជិកចូលរួមក្នុងពិធី

មានមតិក្នុងពេលនោះ ឯក ឧត្តម ឧត្តមសេនីយ៍ឯក ***ដាំ វុទ្ធី*** បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលតែងតែគិតគូរអំពីសុខទុក្ខ ក៏ដូចជាការលំបាកផ្សេងៗរបស់បងប្អូនទាំងអស់ ព្រមទាំងផ្តល់នូវការកោតសរសើរអំពីគំរូវីរភាពតស៊ូលះបង់យ៉ាងអង់អាចក្លាហាន ដើម្បីការពារបូរណភាពទឹកដីយ៉ាងរឹងមាំ និងការពារ សន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋរស់នៅតាម តំបន់ព្រំដែនប្រកបដោយសុវត្ថិភាព ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **ដាំ វុទ្ធី** បានគូសបញ្ជាក់ថា : ការកែសម្រួលសមាសភាពក្នុងជួរថ្នាក់ដឹកនាំរបស់គណៈបញ្ជាការស្រាលនគរបាលជាតិប្រចាំភូមិភាគទី៥ នាពេលនេះ គឺជាដំណើរការធម្មតារបស់អង្គភាពមួយធ្វើឡើង ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការដឹកនាំឲ្យកាន់តែប្រសើរឡើង។ ឯកឧត្តមក៏បានក្រើនរំលឹកដល់ថ្នាក់ដឹកនាំគណៈបញ្ជាការស្រាលនគរបាលជាតិប្រចាំភូមិភាគទី៥ ត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងដឹកនាំបញ្ជាកងកម្លាំងនគរបាលព្រំដែន ឱ្យខិតខំស្រាវជ្រាវបង្ការទប់ស្កាត់បង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់ ពិសេសប្រជាពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ និងនាំទំនិញគេចពន្ធ ឬ ទំនិញដែលច្បាប់ហាមឃាត់ ដោយសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដែលឈរជើងនៅតាមតំបន់ព្រំដែនឲ្យបានជិតស្និទ្ធ ជាពិសេសគឺសហការជាមួយកងយោធពលខេមរភូមិន្ទ។ ទន្ទឹមនេះត្រូវមានផែនការហ្វឹកហ្វឺនរយៈពេលខ្លីនៅនឹងកន្លែងអំពីយុទ្ធវិធី ច្បាប់ មុខជំនាញ និងនីតិវិធីប្រតិបត្តិការ ក៏ដូចជាការបង្កើនសមត្ថភាពចំណេះដឹងទូទៅ ភាសា និងត្រូវមានរបបរាយការណ៍ ត្រួតពិនិត្យការងារឲ្យបានទៀងទាត់ពេលវេលា ៕ រដ្ឋា

# នគរបាលអន្តរជាតិកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី១៣ នៃក្រុមអ្នកជំនាញនគរបាលអន្តរជាតិអាស៊ី-ប៉ាស៊ីហ្វិកស្តីពីឧក្រិដ្ឋកម្មមានអង្គការចាត់តាំង

កាលពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅសណ្ឋាគារសាន់វេ នាយកដ្ឋាននគរបាលអន្តរជាតិនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃបាន រៀបចំកិច្ចប្រជុំលើកទី១៣ នៃក្រុមអ្នកជំនាញនគរបាលអន្តរជាតិអាស៊ី-ប៉ាស៊ីហ្វិកស្តីពីឧក្រិដ្ឋកម្មមានអង្គការចាត់តាំងដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ និងឯកឧត្តម ឧត្តម-សេនីយ៍ឯក **កែវ វណ្ណថន** ប្រធាននាយកដ្ឋាននគរបាលអន្តរជាតិ ព្រមទាំងមានការចូលរួមពីគណៈប្រតិភូចំនួន៤០រូបមកពី១៤ប្រទេសជាសមាជិកនិងអគ្គលេខាធិការដ្ឋាននគរបាលអន្តរជាតិ។

ក្នុងរយៈពេលនៃកិច្ចប្រជុំខាងលើ គណៈប្រតិភូទាំងអស់បានធ្វើការផ្លាស់ប្តូរបទពិសោធន៍ជូនគ្នាទៅវិញទៅមកអំពីស្ថានភាពឧក្រិដ្ឋកម្ម ដែលមានអង្គការចាត់តាំង និងវិធានការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមរយៈការធ្វើបទបង្ហាញ និង ជជែកពិភាក្សាយ៉ាងផុលផុស។ ដោយឡែកប្រទេសកម្ពុជាក្នុងនាមជាម្ចាស់ផ្ទះ និងជាសហប្រធាននៃកិច្ចប្រជុំទាំងមូលបានធ្វើការបង្ហាញ និង ចែករំលែកបទពិសោធន៍លើការបង្ក្រាបបទឧក្រិដ្ឋមានអង្គការចាត់តាំងនៅកម្ពុជា ដែលករណីមួយចំនួនមានការពាក់ព័ន្ធទៅនឹងការបង្ក្រាបការរត់ពន្ធគ្រឿងញៀនធំៗ ដែលធ្វើឲ្យគណៈប្រតិភូទាំងអស់មានចំណាប់អារម្មណ៍ និង បានរៀន




ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល អញ្ជើញជាអធិបតីក្នុងពិធី



ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល

តទៅទំព័រ ៣៧




សមាជិក -សមាជិកាចូលរួមក្នុងពិធី

# សារាចរលេខ ០៦ របស់រាជរដ្ឋាភិបាល ជួយសង្គ្រោះ មន្ត្រីរាជការស៊ីវិល ដែលខកខានពីការ ដំឡើង ថ្នាក់ឋានន្តរស័ក្តិ ឱ្យមានសង្ឃឹមឡើងវិញ



ឯកឧត្តម សក់ សេដ្ឋា



ឯកឧត្តម សក់ សេដ្ឋា អញ្ជើញជាអធិបតីក្នុងពិធី

នាព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ នៅសាលប្រជុំក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយសារាចរលេខ ០៦សរ របស់រាជរដ្ឋាភិបាល **ស្តីពីនិយ័តកម្មថ្នាក់ឋានន្តរស័ក្តិ** តាមអតីតភាពការងារ និងការដំឡើងថ្នាក់សម្រាប់ឆ្នាំ២០១៤ ជូនមន្ត្រីរាជការស៊ីវិល ក្រោមអធិបតីភាពឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។

តាមរយៈការធ្វើបទបង្ហាញរបស់លោក **លឹម សុខត្ន** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ឱ្យដឹងថា ៖ គោលបំណងនៃកិច្ចប្រជុំនាពេលនេះគឺដើម្បីឱ្យអង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ និងរាជធានី-ខេត្តអាចមានមូលដ្ឋាននិងជំរុញការអនុវត្តន៍ការងារដែលពាក់ព័ន្ធនឹងស្មារតីសាររាចរលេខ ០៦សរ របស់រាជរដ្ឋាភិបាលកម្ពុជា និងលិខិតលេខ ១៩៣៨ មស.ត្ររ របស់ក្រសួងមុខងារសាធារណៈ

តទៅទំព័រ ១២





សមាជិក -សមាជិកាចូលរួមក្នុងពិធី



# ប្រតិទិន 2014

## មករា ( បុស្ស-មាឃ ) — January 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | | | ១កើត ខែបុស្ស 1 | ២កើត 2 | ៣កើត 3 | ៤កើត 4 |
| ៥កើត 5 | ៦កើត 6 | ៧កើត 7 | ៨កើត ថ្ងៃសីល 8 | ៩កើត 9 | ១០កើត 10 | ១១កើត 11 |
| ១២កើត 12 | ១៣កើត 13 | ១៤កើត ថ្ងៃកោរ 14 | ១៥កើត ថ្ងៃសីល 15 | ១រោច 16 | ២រោច 17 | ៣រោច 18 |
| ៤រោច 19 | ៥រោច 20 | ៦រោច 21 | ៧រោច 22 | ៨រោច ថ្ងៃសីល 23 | ៩រោច 24 | ១០រោច 25 |
| ១១រោច 26 | ១២រោច 27 | ១៣រោច 28 | ១៤រោច ថ្ងៃកោរ 29 | ១៥រោច ថ្ងៃសីល 30 | ១កើត ខែមាឃ 31 | |

## កុម្ភៈ ( មាឃ ) — February 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | | | | | | ២កើត ខែមាឃ 1 |
| ៣កើត 2 | ៤កើត 3 | ៥កើត 4 | ៦កើត 5 | ៧កើត 6 | ៨កើត ថ្ងៃសីល 7 | ៩កើត 8 |
| ១០កើត 9 | ១១កើត 10 | ១២កើត 11 | ១៣កើត 12 | ១៤កើត ថ្ងៃកោរ 13 | ១៥កើត ថ្ងៃសីល 14 | ១រោច 15 |
| ២រោច 16 | ៣រោច 17 | ៤រោច 18 | ៥រោច 19 | ៦រោច 20 | ៧រោច 21 | ៨រោច ថ្ងៃសីល 22 |
| ៩រោច 23 | ១០រោច 24 | ១១រោច 25 | ១២រោច 26 | ១៣រោច ថ្ងៃកោរ 27 | ១៤រោច ថ្ងៃសីល 28 | |

## មីនា ( ផល្គុន-ចេត្រ ) — March 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| ១៥រោច ថ្ងៃសីល 30 | ១កើត ខែចេត្រ 31 | | | | | ១កើត ខែផល្គុន 1 |
| ២កើត 2 | ៣កើត 3 | ៤កើត 4 | ៥កើត 5 | ៦កើត 6 | ៧កើត 7 | ៨កើត ថ្ងៃសីល 8 |
| ៩កើត 9 | ១០កើត 10 | ១១កើត 11 | ១២កើត 12 | ១៣កើត 13 | ១៤កើត ថ្ងៃកោរ 14 | ១៥កើត ថ្ងៃសីល 15 |
| ១រោច 16 | ២រោច 17 | ៣រោច 18 | ៤រោច 19 | ៥រោច 20 | ៦រោច 21 | ៧រោច 22 |
| ៨រោច ថ្ងៃសីល 23 | ៩រោច 24 | ១០រោច 25 | ១១រោច 26 | ១២រោច 27 | ១៣រោច 28 | ១៤រោច ថ្ងៃកោរ 29 |

## មេសា ( ចេត្រ-ពិសាខ ) — April 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | | ២កើត ខែចេត្រ 1 | ៣កើត 2 | ៤កើត 3 | ៥កើត 4 | ៦កើត 5 |
| ៧កើត 6 | ៨កើត ថ្ងៃសីល 7 | ៩កើត 8 | ១០កើត 9 | ១១កើត 10 | ១២កើត 11 | ១៣កើត 12 |
| ១៤កើត ថ្ងៃកោរ 13 | ១៥កើត ថ្ងៃសីល 14 | ១រោច 15 | ២រោច 16 | ៣រោច 17 | ៤រោច 18 | ៥រោច 19 |
| ៦រោច 20 | ៧រោច 21 | ៨រោច ថ្ងៃសីល 22 | ៩រោច 23 | ១០រោច 24 | ១១រោច 25 | ១២រោច 26 |
| ១៣រោច ថ្ងៃកោរ 27 | ១៤រោច ថ្ងៃសីល 28 | ១កើត ខែពិសាខ 29 | ២កើត 30 | | | |

## ឧសភា ( ពិសាខ-ជេស្ឋ ) — May 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | | | | ៣កើត ខែពិសាខ 1 | ៤កើត 2 | ៥កើត 3 |
| ៦កើត 4 | ៧កើត 5 | ៨កើត ថ្ងៃសីល 6 | ៩កើត 7 | ១០កើត 8 | ១១កើត 9 | ១២កើត 10 |
| ១៣កើត 11 | ១៤កើត ថ្ងៃកោរ 12 | ១៥កើត ថ្ងៃសីល 13 | ១រោច 14 | ២រោច 15 | ៣រោច 16 | ៤រោច 17 |
| ៥រោច 18 | ៦រោច 19 | ៧រោច 20 | ៨រោច ថ្ងៃសីល 21 | ៩រោច 22 | ១០រោច 23 | ១១រោច 24 |
| ១២រោច 25 | ១៣រោច 26 | ១៤រោច ថ្ងៃកោរ 27 | ១៥រោច ថ្ងៃសីល 28 | ១កើត ខែជេស្ឋ 29 | ២កើត 30 | ៣កើត 31 |

## មិថុនា (ជេស្ឋ - អាសាឍ) — June 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| ៤កើត ខែជេស្ឋ 1 | ៥កើត 2 | ៦កើត 3 | ៧កើត 4 | ៨កើត ថ្ងៃសីល 5 | ៩កើត 6 | ១០កើត 7 |
| ១១កើត 8 | ១២កើត 9 | ១៣កើត 10 | ១៤កើត ថ្ងៃកោរ 11 | ១៥កើត ថ្ងៃសីល 12 | ១រោច 13 | ២រោច 14 |
| ៣រោច 15 | ៤រោច 16 | ៥រោច 17 | ៦រោច 18 | ៧រោច 19 | ៨រោច ថ្ងៃសីល 20 | ៩រោច 21 |
| ១០រោច 22 | ១១រោច 23 | ១២រោច 24 | ១៣រោច ថ្ងៃកោរ 25 | ១៤រោច ថ្ងៃសីល 26 | ១កើត ខែអាសាឍ 27 | ២កើត 28 |
| ៣កើត 29 | ៤កើត 30 | | | | | |

### ចាត្រូវតលើផ្ទៃមេឃ

នៅក្នុងឆ្នាំ២០១៤នេះមានសូរ្យគ្រាសចំនួន៤ដង ដែលសូរ្យគ្រាសមាន២ដង និងច័ន្ទគ្រាស២ដងតាមកាលបរិច្ឆេទដូចខាងក្រោម :

**១-នៅថ្ងៃអង្គារ ១៥កើត ខែចេត្រ ឆ្នាំមមី ឆស័ក ចុល្លសករាជ១៣៧៦ ត្រូវនឹងថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៤** មានច័ន្ទគ្រាសជាសារពើគ្រាសចាប់ផ្ដើមពី**ម៉ោង១២:៥៨នាទី ដល់ម៉ោង១៦:៣៤នាទី** ។ មើលឃើញជាសារពើគ្រាស **ចាប់ពីម៉ោង១៤:០៦នាទី ដល់ម៉ោង១៥:២៦នាទី** នៅអូស្ត្រាលី ប៉ាស៊ីហ្វិក អាមេរិកាស ។ កម្ពុជាមើលមិនឃើញទេ ។

**២-នៅថ្ងៃអង្គារ ១កើត ខែពិសាខ ឆ្នាំមមី ឆស័ក ចុល្លសករាជ១៣៧៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤** មានសូរ្យគ្រាសជារូបចិញ្ចៀន មើលឃើញនៅតណ្ហា អូស្ត្រាលី អង់តាក់ទិក និងអាហ្វ្រិកកណ្ដាល ។ **ចាប់ផ្ដើមពីម៉ោង១០:៥៣នាទី ដល់ម៉ោង១៥:១៥នាទី ជារូបចិញ្ចៀនពីម៉ោង១២:៥៩នាទី ដល់ម៉ោង១៣:០៩នាទី** ។ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជាយើងមើលមិនឃើញទេ ។

# ឆ្នាំមមី ឆស័ក

## ព.ស២៥៥៨-គ.ស២០១៤

## ម.ស១៩៣៦-ចុ.ស១៣៧៦



### កក្កដា (អាសាឍ- ស្រាពណ៍) July 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | | ៥កើត ខែអាសាឍ 1 | ៦កើត 2 | ៧កើត 3 | ៨កើត ថ្ងៃសីល 4 | ៩កើត 5 |
| ១០កើត 6 | ១១កើត 7 | ១២កើត 8 | ១៣កើត 9 | ១៤កើត ថ្ងៃកោរ 10 | ១៥កើត ថ្ងៃសីល 11 | ១រោច 12 |
| ២រោច 13 | ៣រោច 14 | ៤រោច 15 | ៥រោច 16 | ៦រោច 17 | ៧រោច 18 | ៨រោច ថ្ងៃសីល 19 |
| ៩រោច 20 | ១០រោច 21 | ១១រោច 22 | ១២រោច 23 | ១៣រោច 24 | ១៤រោច ថ្ងៃកោរ 25 | ១៥រោច ថ្ងៃសីល 26 |
| ១កើត ខែស្រាពណ៍ 27 | ២កើត 28 | ៣កើត 29 | ៤កើត 30 | ៥កើត 31 | | |

### សីហា (ស្រាពណ៍-ភទ្របទ) August 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| ៧កើត 31 | | | | | ៦កើត ខែស្រាពណ៍ 1 | ៧កើត 2 |
| ៨កើត ថ្ងៃសីល 3 | ៩កើត 4 | ១០កើត 5 | ១១កើត 6 | ១២កើត 7 | ១៣កើត 8 | ១៤កើត ថ្ងៃកោរ 9 |
| ១៥កើត ថ្ងៃសីល 10 | ១រោច 11 | ២រោច 12 | ៣រោច 13 | ៤រោច 14 | ៥រោច 15 | ៦រោច 16 |
| ៧រោច 17 | ៨រោច ថ្ងៃសីល 18 | ៩រោច 19 | ១០រោច 20 | ១១រោច 21 | ១២រោច 22 | ១៣រោច ថ្ងៃកោរ 23 |
| ១៤រោច ថ្ងៃសីល 24 | ១កើត ខែភទ្របទ 25 | ២កើត 26 | ៣កើត 27 | ៤កើត 28 | ៥កើត 29 | ៦កើត 30 |

### កញ្ញា (ភទ្របទ - អស្សុជ) September 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | ៨កើត ខែភទ្របទ 1 | ៩កើត 2 | ១០កើត 3 | ១១កើត 4 | ១២កើត 5 | ១៣កើត 6 |
| ១៤កើត ថ្ងៃកោរ 7 | ១៥កើត ថ្ងៃសីល 8 | ១រោច បិណ្ឌ១ 9 | ២រោច 10 | ៣រោច 11 | ៤រោច 12 | ៥រោច 13 |
| ៦រោច 14 | ៧រោច 15 | ៨រោច ថ្ងៃសីល 16 | ៩រោច 17 | ១០រោច 18 | ១១រោច 19 | ១២រោច 20 |
| ១៣រោច 21 | ១៤រោច ថ្ងៃកោរ 22 | ១៥រោច ថ្ងៃសីល 23 | ១កើត ខែអស្សុជ 24 | ២កើត 25 | ៣កើត 26 | ៤កើត 27 |
| ៥កើត 28 | ៦កើត 29 | ៧កើត 30 | | | | |

### តុលា (អស្សុជ - កត្តិក) October 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | | | ៨កើត ខែអស្សុជ 1 | ៩កើត 2 | ១០កើត 3 | ១១កើត 4 |
| ១២កើត 5 | ១៣កើត 6 | ១៤កើត ថ្ងៃកោរ 7 | ១៥កើត ថ្ងៃសីល 8 | ១រោច 9 | ២រោច 10 | ៣រោច 11 |
| ៤រោច 12 | ៥រោច 13 | ៦រោច 14 | ៧រោច 15 | ៨រោច ថ្ងៃសីល 16 | ៩រោច 17 | ១០រោច 18 |
| ១១រោច 19 | ១២រោច 20 | ១៣រោច ថ្ងៃកោរ 21 | ១៤រោច ថ្ងៃសីល 22 | ១កើត ខែកត្តិក 23 | ២កើត 24 | ៣កើត 25 |
| ៤កើត 26 | ៥កើត 27 | ៦កើត 28 | ៧កើត 29 | ៨កើត ថ្ងៃសីល 30 | ៩កើត 31 | |

### វិច្ឆិកា (កត្តិក-មិគសិរ) November 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| ៩កើត 30 | | | | | | ១០កើត ខែកត្តិក 1 |
| ១១កើត 2 | ១២កើត 3 | ១៣កើត 4 | ១៤កើត ថ្ងៃកោរ 5 | ១៥កើត ថ្ងៃសីល 6 | ១រោច 7 | ២រោច 8 |
| ៣រោច 9 | ៤រោច 10 | ៥រោច 11 | ៦រោច 12 | ៧រោច 13 | ៨រោច ថ្ងៃសីល 14 | ៩រោច 15 |
| ១០រោច 16 | ១១រោច 17 | ១២រោច 18 | ១៣រោច 19 | ១៤រោច ថ្ងៃកោរ 20 | ១៥រោច ថ្ងៃសីល 21 | ១កើត ខែមិគសិរ 22 |
| ២កើត 23 | ៣កើត 24 | ៤កើត 25 | ៥កើត 26 | ៦កើត 27 | ៧កើត 28 | ៨កើត ថ្ងៃសីល 29 |

### ធ្នូ (មិគសិរ-បុស្ស) December 2014

| អាទិត្យ Sun | ច័ន្ទ Mon | អង្គារ Tue | ពុធ Wen | ព្រហស្បតិ៍ Thu | សុក្រ Fri | សៅរ៍ Sat |
|---|---|---|---|---|---|---|
| | ១០កើត ខែមិគសិរ 1 | ១១កើត 2 | ១២កើត 3 | ១៣កើត 4 | ១៤កើត ថ្ងៃកោរ 5 | ១៥កើត ថ្ងៃសីល 6 |
| ១រោច 7 | ២រោច 8 | ៣រោច 9 | ៤រោច 10 | ៥រោច 11 | ៦រោច 12 | ៧រោច 13 |
| ៨រោច ថ្ងៃសីល 14 | ៩រោច 15 | ១០រោច 16 | ១១រោច 17 | ១២រោច 18 | ១៣រោច ថ្ងៃកោរ 19 | ១៤រោច ថ្ងៃសីល 20 |
| ១កើត ខែបុស្ស 21 | ២កើត 22 | ៣កើត 23 | ៤កើត 24 | ៥កើត 25 | ៦កើត 26 | ៧កើត 27 |
| ៨កើត ថ្ងៃសីល 28 | ៩កើត 29 | ១០កើត 30 | ១១កើត 31 | | | |

៣-នៅថ្ងៃពុធ ១៥កើត ខែអស្សុជ ឆ្នាំមមី ឆស័ក ចុល្លសករាជ១៣៧៦ ត្រូវនឹងថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៤ មានច័ន្ទគ្រាស មើលឃើញនៅអាស៊ី អូស្ត្រាលី ប៉ាស៊ីហ្វិក អាមេរិកាស ចាប់ផ្តើមនៅម៉ោង១៦:១៤នាទី បញ្ចប់នៅម៉ោង១៩:៣៥នាទី ផ្តើមជាសារពើគ្រាសពីម៉ោង១៧:២៤នាទី ដល់ម៉ោង១៨:២៥នាទី ។ នៅរាជធានីភ្នំពេញមើលឃើញជាសារពើគ្រាស ចាប់ពីខែរះម៉ោង១៧:៣៨នាទី រហូតដល់ម៉ោង១៨:២៥នាទី រាហ៊ូចាប់ផ្តើមថយចេញពីមណ្ឌលព្រះច័ន្ទ ហើយបញ្ចប់គ្រាសនៅម៉ោង១៩:៣៥នាទី ។

៤-នៅថ្ងៃព្រហស្បតិ៍ ១កើត ខែកត្តិក ឆ្នាំមមី ឆស័ក ចុល្លសករាជ១៣៧៦ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ មានសូរ្យគ្រាសជាអឌ្ឍគ្រាសចាប់ផ្តើមពីម៉ោង២:៣៨នាទី ដល់ម៉ោង៦:៥២នាទី ។ មើលឃើញនៅមហាសមុទ្រប៉ាស៊ីហ្វិក និងអាមេរិកខាងជើង ។ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជាយើង មើលមិនឃើញទេ ។

***ទំនាយថ្ងៃបុណ្យអុំទូកនៅទេធិកាអុំទូក***

*ឆ្នាំ២០១៣ ថ្ងៃបុណ្យអុំទូក ថ្ងៃទី៥ ខែវិច្ឆិកា ជាថ្ងៃទី១ ពេលល្ងាចមានខ្យល់ និងភ្លៀងខ្លាំង ។ ថ្ងៃទី៦ ខែវិច្ឆិកា ជាថ្ងៃទី២ មេឃស្រទុំមានពពកច្រើន ធាតុអាកាសត្រជាក់មានខ្យល់បក់ខ្លាំងៗ ។ ថ្ងៃទី៧ ខែវិច្ឆិកា ជាថ្ងៃទី៣ ធាតុអាកាសធម្មតាមេឃស្រឡះល្អ មិនមានខ្យល់ភ្លៀងឡើយ ។*

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញ សម្ពោធដាក់ឱ្យប្រើប្រាស់ មជ្ឈមណ្ឌលបណ្តុះ និង ចែកចាយដំឡូងមី និងទទួលសម្ភារៈគ្រឿងយន្តកសិកម្ម

ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលបណ្តុះ និងចែកចាយពូជដំឡូងមី ខេត្តបាត់ដំបង និងពិធីប្រគល់-ទទួលអំណោយ




ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង និងឯកឧត្តម យូជី គូម៉ាម៉ារុ អញ្ជើញជាអធិបតីក្នុងពិធី

សម្ភារៈគ្រឿងយន្តកសិកម្មរបស់ក្រុមហ៊ុន **ជី អិល ហ្វាយនែន** ជូនដល់សកលវិទ្យាល័យបាត់ដំបងបានប្រារព្ធធ្វើកាលពីព្រឹកថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **យូជី គូម៉ាម៉ារុ** ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

តាមរបាយការណ៍របស់ឯកឧត្តម **ទូច វិសាលសុខ** សកលវិទ្យាធិការនៃសកលវិទ្យាល័យបាត់ដំបងបានបញ្ជាក់ឱ្យដឹងថា : គម្រោងគូសាណូណិរបស់ស្ថានទូតជប៉ុនឧបត្ថម្ភដល់ការបង្កើតមជ្ឈមណ្ឌលបណ្តុះ និងចែកចាយពូជដំឡូងមីខេត្តបាត់ដំបង ដោយសាងសង់ផ្ទះសំណាញ់ការពារសត្វល្អិតចំនួន២ ទំហំ៦០០ និង៣០០ម៉ែត្រក្រឡា នៅក្នុងបរិវេណកសិដ្ឋានរបស់សកលវិទ្យាល័យនិងបំពាក់សម្ភារៈចាំបាច់ដល់មន្ទីរពិសោធន៍ជាលិកាវប្បកម្មគឺទូសម្រាប់ជាលិកាមួយគ្រឿង និងម៉ាស៊ីនសម្លាប់មេរោគចំនួន២គ្រឿង អស់ទឹកប្រាក់សរុបប្រមាណជិត



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញពិនិត្យមជ្ឈមណ្ឌលបណ្តុះនិងចែកចាយដំឡូងមី

១២ម៉ឺនដុល្លារអាមេរិក។ ទន្ទឹមនោះដែរ ក្រុមហ៊ុន **ជីអិល ហ្វាយនែន** បានឧបត្ថម្ភដល់ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រឿងយន្តកសិកម្មដល់សកលវិទ្យាល័យបាត់ដំបង ដោយផ្តល់អំណោយជាគ្រឿងយន្តកសិកម្មចំនួន៣គ្រឿង រួមមានត្រាក់ទ័រធុនមធ្យមមួយគ្រឿង ម៉ាស៊ីនច្រូតស្វ័យប្រវត្តិមួយគ្រឿង និងគោយន្ត១គ្រឿង **អស់ថវិកាសរុបចំនួន៤៥.១៥០ដុល្លារអាមេរិក**។

ក្នុងចំណាប់អារម្មណ៍របស់លោក **ភាត ស៊ូហ៊ីរ៉ូស៊ីណូហារ៉ា** អនុប្រធានអង្គការ **ស៊ី អាយ អ៊ី អែស អែហ្វ** និងលោក **គ្រីស្តូហ្វី ហ្វ ស៊ីនីតធី** នាយកប្រតិបត្តិរបស់ក្រុមហ៊ុន **ជី អិល ហ្វាយនែន** បានបញ្ជាក់ថា : ខេត្តបាត់ដំបងគឺជាជង្រុកស្រូវរបស់ប្រទេសកម្ពុជា ដូចនេះសកលវិទ្យាល័យបាត់ដំបងក៏នឹងក្លាយជាសកលវិទ្យាល័យឈានមុខគេក្នុងវិស័យកសិកម្មនេះផងដែរ។ ដំឡូងមីគឺជាដំណាំកសិឧស្សាហកម្មមានប្រយោជន៍ មើមរបស់វាអាចកែច្នៃជាផលិតផលផ្សេងៗ ជាពិសេសផលិតផលជីវ-ឥន្ធនៈអេតាណុល ម្យ៉ាងវិញទៀតម៉ាស៊ីនកសិកម្មមានតួនាទីដ៏ទំនើបដែលជាអំណោយរបស់ក្រុមហ៊ុន **ជី អិល ហ្វាយនែន** មានសារៈប្រយោជន៍សម្រាប់ផ្តល់ឱ្យសិស្ស-និស្សិត និង

តទៅទំព័រ ៣៥

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អនុញ្ញាតឲ្យ ឯកអគ្គរាជទូតស៊ុយអែត ចូលជួបសម្តែងការគួរសម និង ពិភាក្សាការងារ

រសៀលថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីស្តីការក្រសួងមហាផ្ទៃ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ **អេនណា ម៉ាយហាលហ្គាដ** ( Anna Maj Hultgard ) ឯកអគ្គរាជទូតប្រទេសស៊ុយអែតប្រចាំព្រះរាជាណាចក្រកម្ពុជា។

មានប្រសាសន៍ក្នុងជំនួបនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់លោកជំទាវ **អេនណា ម៉ាយហាលហ្គាដ** ដែលបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម ឧប-នាយករដ្ឋមន្ត្រី ក៏បានវាយតម្លៃខ្ពស់ចំពោះកម្ពុជាចាប់តាំងពីប្រទេសកម្ពុជាបានរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមពោលគឺនៅក្នុងទសវត្សឆ្នាំ៨០មកម្លេះ។ រដ្ឋមន្ត្រី បានសម្តែងនូវក្តីសង្ឃឹមថាប្រទេសស៊ុយអែតនឹងបន្តជួយប្រទេសកម្ពុជាលើការងារកំណែទម្រង់នេះជាបន្តទៅទៀតនៅ



ជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង និងលោកជំទាវ អេនណា ម៉ាយហាលហ្គាដ



សមាជិកភាគីស៊ុយអែតចូលរួមក្នុងពិធី



សមាជិកភាគីកម្ពុជាចូលរួមក្នុងពិធី

ចំណងមិត្តភាពរវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលនៃប្រទេសស៊ុយអែត ដែលកន្លងមកបានគាំទ្រប្រទេសកម្ពុជាមិនមែនត្រឹមតែក្រោយមានសន្និសញ្ញាទីក្រុងបារីសនោះទេគឺប្រទេសស៊ុយអែតបានគាំទ្រប្រទេសហើយកន្លងមកនេះប្រទេសស៊ុយអែតក៏បានជួយគាំទ្រយ៉ាងសកម្មដល់គោលនយោបាយកែទម្រង់ប្រព័ន្ធវិមជ្ឈការ វិសហមជ្ឈការ និងជាពិសេសការងារអភិបាលកិច្ចល្អនៅកម្ពុជា។ ពាក់ព័ន្ធនឹងបញ្ហានេះ ឯកឧត្តម ឧបនាយកថ្ងៃអនាគត។

ដោយឡែក ពាក់ព័ន្ធអំពីស្ថានភាពនៃការវិវត្តន៍នយោបាយនៅក្នុងប្រទេសកម្ពុជាក្រោយពីមានការជួបចរចាគ្នារវាងគណបក្ស

តទៅទំព័រ ១៤



https://online.fliphtml5.com/vhqfg/gmza/


ShinEx
SENG HONG HENG
IMPORT EXPORT CO.,LTD
ក្រុមហ៊ុនសេង ហុង ហេង
DIAMOND
ផលិតផល ដំបូលត្រាពេជ្រ ជាជម្រើសទី១របស់លោកអ្ន
ហ្វីយ៉ូភ្លឺគូ
ហ្វីយ៉ូភ្លឺគូច
ក្បឿងអាដាម៉ាស
ក្បឿង CT ត្រាពេជ្រ
ហ្វីប្រ៊ូចតុភ្លឺ
ក្រឡេកសមមើលស្អាត...ត្រូវតែ៤ភ្លឺ!


ស៊ីម៉ងត៍ភ្នំ
អច្ឆរិយនៃសំណង់
ស៊ីម៉ងត៍រូបផ្កាឈូក
ប្រើសម្រាប់ : បូក
ស៊ីម៉ងត៍រូបភ្នំ
ប្រើសម្រាប់ : ចាក់បេតុង ចាក់សាប រៀបឥដ្ឋ បិទការ៉ូ...
TIS 15-PART 1-2547
Conformed to ASTM C-150 TYPE I
Mountain
PORTLAND CEMENT
Mountain
Made in Thailand
Net Weight 50 kg.
For Export
TIS 80-2550
Lotus
MIXED CEMENT Green
Made in Thailand
Lotus Green
For Export
Net Weight 50 kg.
មានលក់ចែកចាយគ្រប់ដេប៉ូរាជធានី-ខេត្តទូទាំងប្រទេស
ពត៌មានលំអិតសូមទូរស័ព្ទមកលេខ : 088 870 33 33

# ឯកឧត្តម មៀច សុផាន់ណា អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អញ្ជើញទៅបំពេញទស្សនកិច្ច និង សិក្សាស្វែងយល់ជាមួយស្ថាប័នស៊ើបអង្កេតឯកជនរបស់ជប៉ុន





ឯកឧត្តម មៀច សុផាន់ណា និងគណៈប្រតិភូអញ្ជើញទស្សនកិច្ចនៅភ្នាក់ងារនគរបាលជាតិជប៉ុន

តបតាមការអញ្ជើញរបស់ឯកឧត្តម **កាត់ស៊ូហ៊ីរ៉ូ ស៊ីណូហារ៉ា** អតីតឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា និងជាអនុប្រធានមូលនិធិគាំទ្រការអប់រំកម្ពុជា ហៅកាត់ (CIESF) និងតាមចំណារឯកភាពរបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្មីៗកន្លងមកនេះ ប្រតិភូក្រសួងមហាផ្ទៃដឹកនាំដោយឯកឧត្តម **មៀច សុផាន់ណា** អនុរដ្ឋ-លេខាធិការក្រសួងមហាផ្ទៃ បានអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៣ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

ដំណើរទស្សនកិច្ចនេះក្នុងគោលបំណងសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍



ឯកឧត្តម មៀច សុផាន់ណា និងគណៈប្រតិភូថតរូបអនុស្សាវរីយ៍
ជាមួយថ្នាក់ដឹកនាំភ្នាក់ងារនគរបាលជប៉ុន

ជាមួយស្ថាប័នស៊ើបអង្កេតឯកជនប្រទេសជប៉ុន ដែលភាគីជប៉ុនដឹកនាំដោយឯកឧត្តម **កាត់ស៊ូហ៊ីរ៉ូ ស៊ីណូហារ៉ា** អតីតឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានិងជាអនុប្រធានមូលនិធិគាំទ្រការអប់រំកម្ពុជា (CIESF)។ ខ្លឹមសារនៃជំនួបពិភាក្សានេះ ភាគីទាំងពីរបានពិគ្រោះយោបល់គ្នាទៅលើប្រធានបទសំខាន់ៗ រួមមាន : ការសិក្សាស្វែងយល់ពីក្រុមហ៊ុនស្រាវជ្រាវ និងគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុអាជីវកម្មឯកជនជប៉ុនឈ្មោះ **ថៃកូកុ ដាតាប៊ែង** TEIKOKU DATABANK ,Ltd) ដែលជាក្រុមហ៊ុនចំណាស់មួយ កើតមានតាំងពីឆ្នាំ ១៩០០មកម្ល៉េះ ហើយក្រុមហ៊ុននេះក៏បានធ្វើបទបង្ហាញពីតួនាទីសំខាន់ៗ ក្នុងការជួយទប់ស្កាត់បទល្មើសពាណិជ្ជកម្ម និងការជួយពង្រឹងសុវត្ថិភាពជូនវិនិយោគិនក្នុងនិងក្រៅស្រុក តាមរយៈការផ្តល់សេវាព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសហគ្រាសឯកជនផ្សេងៗ នៅក្នុងទីផ្សារពាណិជ្ជកម្មជប៉ុននិងស្វែងយល់ពីការធ្វើ

តទៅទំព័រ ៣៤

# ពិធីប្រគល់-ទទួលសម្ភារៈ BLO គម្រោង PATROL សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន

នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានរៀបចំពិធីប្រគល់-ទទួលសម្ភារៈសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ពីគម្រោងភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន ហៅថា (PATROL) នៅច្រកទ្វារជ្រៃធំ ចាំយាម ព្រំ ដូង និងប៉ោយប៉ែត ក្រោមអធិបតីភាពឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស វីរិទ្ធិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឯកឧត្តម **ជី អូវានី ប្រូសាដ (GIOVANI BRUSAD)** អ្នកសម្របសម្រួលគម្រោងភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន (PATROL) UNODC អនុតំបន់។




ពិធីចុះហត្ថលេខាក្នុងពិធីប្រគល់-ទទួលសម្ភារៈការិយាល័យទំនាក់ទំនងព្រំដែន BLO





សកម្មភាពប្រគល់-ទទួលសម្ភារៈការិយាល័យទំនាក់ទំនងព្រំដែន BLO

សម្ភារៈសម្រាប់ការិយាល័យ (BLO) ខាងលើរួមមាន : LCD Monitor-HP ម៉ាក Compag ចំនួន១២គ្រឿង Desktop Computer HP ចំនួន១២គ្រឿង អាគុយ Computer ចំនួន១២គ្រឿង កាសស្តាប់ត្រចៀក ចំនួន៨គ្រឿង ម៉ាស៊ីនព្រីនឯកសារម៉ាក HP ចំនួន៤គ្រឿង កាមេរ៉ាថតរូបម៉ាក Sony ចំនួន ៤គ្រឿង ប្រដាប់ថតសំឡេងម៉ាក Sony ចំនួន ៤គ្រឿង ម៉ាស៊ីន Fax ចំនួន៤គ្រឿង និងម៉ូតូ YAMAHA SPARK 115i ចំនួន១២គ្រឿង។

ឯកឧត្តម **ជីអូវានី ប្រូសាដ** បានបញ្ជាក់ថា : ទាក់ទងនឹងការប្រគល់សម្ភារៈជាជំនួយបច្ចេកទេសដែលបានផ្តល់ឱ្យសម្រាប់គម្រោងភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (TCXAP/U59) គឺជាកិច្ចសហការរវាងអង្គការ UNODC និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ឯកឧត្តមក៏បានបញ្ជាក់ទៀតថា : ការជួយឧត្ថម្ភដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺសម្រាប់ប្រើដោយឡែកតែក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ដូចដែលបានកំណត់ក្នុងឯកសារគម្រោងចំណុចទិន្នផល

តទៅទំព័រ ៣៧

# សិក្ខាសាលាស្តីពីការពិនិត្យ ពិភាក្សា កែសម្រួល សេចក្តីព្រាងផែនការយុទ្ធសាស្ត្រ5ឆ្នាំ 2014-2018 របស់អគ្គនាយកដ្ឋានពន្ធនាគារ

សិក្ខាសាលាស្តីពីការពិនិត្យ ពិភាក្សា កែសម្រួលសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៤-២០១៨) របស់អគ្គនាយកដ្ឋានពន្ធនាគារ បានដំណើរការអស់រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រោមអធិបតីភាព ឯកឧត្តម **នុត សាអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកស្រី **វ៉ាន ហ៊ីលី (WAN HEA LEE)** តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ប្រធានមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្តព្រមទាំងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងអង្គការ សមាគមជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍសរុបចំនួន៧៥រូប។



ឯកឧត្តម នុត សាអាន អញ្ជើញជាអធិបតីក្នុងពិធី



លោកស្រី វ៉ាន ហ៊ីលី

នៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ (២០១៤-២០១៨) របស់អគ្គនាយកដ្ឋានពន្ធនាគារបានបញ្ជាក់ថា : ផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៤-២០១៨ ត្រូវបានអនុវត្តបន្តពីផែនការយុទ្ធសាស្ត្រឆ្នាំ២០០៨-២០១៣ ដោយរក្សារចនាសម្ព័ន្ធដើមនៃយុទ្ធសាស្ត្រ និងគ្រាន់តែធ្វើការសម្រិតសម្រាំង និងសម្រួចបន្ថែមនូវអាទិភាពយុទ្ធសាស្ត្រស្របតាមក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ និងសេចក្តីត្រូវការទាំងឡាយនៃការអនុវត្តជាក់ស្តែង។ ក្នុងស្មារតីនេះអគ្គនាយកដ្ឋានពន្ធនាគារកំណត់


ឯកឧត្តម ឧត្តមសេនីយ៍ឯក គុយ ប៊ុនសន

ទស្សនវិស័យនិងបេសកកម្មដូចខាងក្រោម :

-រួមគ្នាដើម្បីសុវត្ថិភាពសង្គម និងកាត់បន្ថយបទល្មើសក្នុងសហគមន៍។


សមាជិក-សមាជិកាចូលរួមក្នុងពិធី


សមាជិក-សមាជិកាចូលរួមក្នុងពិធី

-គ្រប់គ្រងអ្នកទោសតាមជំនាញវិជ្ជាជីវៈ ប្រកបដោយសន្តិសុខ សុវត្ថិភាព និងមនុស្សធម៌ក្នុងបរិយាកាសមានអនាម័យល្អ ព្រមទាំងផ្តល់កម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្មអ្នកទោស។

ដើម្បីសម្រេចឱ្យបានតាមចក្ខុវិស័យ និងបេសកកម្មនេះអគ្គនាយកដ្ឋានពន្ធនាគារកំណត់ទិសដៅយុទ្ធសាស្ត្រសម្រាប់អនុវត្តឆ្នាំ២០១៤-២០១៨ ដូចតទៅ :

**យុទ្ធសាស្ត្រទី១** : គ្រប់គ្រងពន្ធនាគារតាមបទដ្ឋាន ដែលធានាឱ្យមានសន្តិសុខសុវត្ថិភាព និងប្រកបដោយមនុស្សធម៌។

**យុទ្ធសាស្ត្រទី២** : អភិវឌ្ឍជំនាញវិជ្ជាជីវៈ សេវាអប់រំកែប្រែ ដែលគោរពសិទ្ធិរបស់បុគ្គលម្នាក់ៗ។

**យុទ្ធសាស្ត្រទី៣** : អនុវត្តគោលនយោបាយកំណែទម្រង់ពន្ធនាគារ លើកស្ទួយដល់កម្មវិធីស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកទោសចូលទៅសហគមន៍វិញ។

**យុទ្ធសាស្ត្រទី៤** : បង្កើតហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារឱ្យមានបទដ្ឋានសមស្រប សម្រាប់ផ្តល់កន្លែងស្នាក់នៅរបស់អ្នកទោស។

ហើយទិសដៅយុទ្ធសាស្ត្រអាទិភាពនីមួយៗនៃផែនការយុទ្ធសាស្ត្រនេះត្រូវបានបែងចែកជាទិសដៅយុទ្ធសាស្ត្រ និងសូចនាករបំពេញការងារមួយចំនួនដូចខាងក្រោម :

-រៀបចំកែសម្រួលនីតិវិធីប្រតិបត្តិការពន្ធនាគារឱ្យឆ្លើយតបនឹងច្បាប់ថ្មី។

-បង្កើនប្រសិទ្ធភាពសេវាសុខភាពក្នុងពន្ធនាគារក្រោមការគ្របដណ្តប់ពីក្រសួងសុខាភិបាល។

-កែលម្អលក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំ។

-ពង្រឹងការិយាល័យតាមដានមូលដ្ឋានស៊ើបការអប់រំ និងការិយាល័យទិន្នន័យប័ណ្ណសារ ដើម្បីត្រួតពិនិត្យវាយតម្លៃលើការងារគ្រប់គ្រងពន្ធនាគារ។

-រៀបចំកែសម្រួលរចនាសម្ព័ន្ធបន្ថែម។

-បង្កើនសេវាផ្លូវច្បាប់ និងព័ត៌មានពេញលេញដល់ជនជាប់ឃុំ និងក្រុមគ្រួសារ។

-ជំរុញការអនុវត្តការងារគ្រប់គ្រងពន្ធនាគារគំរូ។

លោកស្រី **ខ៊ាន ហ៊ីលី** បានបញ្ជាក់ថា : នេះជាលើកទី១ហើយ ដែលប្រធានពន្ធនាគារ មន្ត្រីរបស់រាជរដ្ឋាភិបាលភ្នាក់ងាររបស់អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយទាំងអស់បានជួបប្រជុំគ្នាក្នុងការពិភាក្សា និងពិនិត្យឡើងវិញលើផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៤-២០១៨) របស់ **GDP** និងជាលើកដំបូងដែលការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាមានឱកាសចូលរួមគាំទ្រ និងលើកកម្ពស់ដល់កិច្ចដំណើរការផែនការណែនាំស្តីពីសិទ្ធិមនុស្ស ដើម្បីជាមូលដ្ឋានដាក់ចូលក្នុងការអភិវឌ្ឍ ផែនការយុទ្ធសាស្ត្រផងដែរ។ លោកស្រីបានបញ្ជាក់ទៀតថា សិទ្ធិមនុស្សគឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការគ្រប់គ្រងពន្ធនាគារ ហើយវាក៏បានជួយសម្រួលដល់ការគោរពសិទ្ធិគ្នាទៅវិញទៅមកនៅក្នុងពន្ធនាគារ ដែលការងារនេះទាមទារនូវការធ្វើទំនាក់ទំនងបច្ចេកទេសដើម្បីផ្សារភ្ជាប់ទៅនឹងកម្រិតស្តង់ដារសិទ្ធិមនុស្សជាសកល។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **គុយ ប៊ុនសន** បានបញ្ជាក់ថា : អង្គសិក្ខាសាលាបានប្រមូលផ្តុំពិនិត្យពិភាក្សាជុំវិញបញ្ហាចម្បងៗជាច្រើនដែលឆ្លងតាមរយៈការពិនិត្យពិភាក្សាយ៉ាងសកម្មផុលផុស ក្រុមពិភាក្សានីមួយៗបានរកឃើញលទ្ធផលវិជ្ជមាននិងអវិជ្ជមានមួយចំនួននៃសេចក្តីព្រាងដើម។ ហើយផ្អែកលើលទ្ធផលនៃកិច្ចពិភាក្សារបស់ក្រុមនីមួយៗ ការពិភាក្សាពេញអង្គក៏បានឯកភាពធ្វើការកែសម្រួល សម្រិតសម្រាំងខ្លឹមសារដើមមួយចំនួនឱ្យស្របតាមសេចក្តីត្រូវការជាក់ស្តែងនៃបច្ចុប្បន្នភាព។ ជាមួយគ្នានេះដែរ អង្គសិក្ខាសាលាក៏បានសម្តែងការស្វាគមន៍ចំពោះភាពសមស្របនៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថ្មី ២០១៤-២០១៨ ដែលកិច្ចពិភាក្សាពេញអង្គបានកែសម្រួល សម្រិតសម្រាំង ដោយផ្អែកលើលទ្ធផលរបស់ក្រុមពិភាក្សានីមួយៗ និងសង្ឃឹមថាសេចក្តីព្រាងនេះនឹងក្លាយជាផែនការយុទ្ធសាស្ត្ររយៈពេលវែងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសកល និងច្បាស់លាស់។

អញ្ជើញមានមតិសំណេះសំណាលក្នុងពេលនោះ ឯកឧត្តម **នុត សាវអាន** បានមានប្រសាសន៍បញ្ជាក់ថា : តាមរយៈកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសមាគមជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍសំខាន់ៗនាពេលកន្លងមកនេះសមិទ្ធផលសំខាន់ៗជាច្រើនត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដែលមានជាអាទិ៍ : ច្បាប់ស្តីពីពន្ធនាគារដែលជាបទដ្ឋានគតិយុត្តយ៉ាងសំខាន់ក្នុងការពង្រឹងការងារគ្រប់គ្រងពន្ធនាគារ ដែលមានលក្ខណៈស្តង់ដារស្របតាមបទដ្ឋានអន្តរជាតិស្តីពីការគ្រប់គ្រងអ្នកទោស និងមាននិន្នាការលើកកម្ពស់លក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំ ស្របតាមបទដ្ឋានសិទ្ធិមនុស្ស ហើយត្រូវបានរាជរដ្ឋាភិបាលកោតសរសើរ និងមជ្ឈដ្ឋានសង្គម ស៊ីវិលភាគច្រើនស្វាគមន៍ និងទទួលយកបាន។ ទន្ទឹមនេះសេចក្តីណែនាំលេខ ០១២ សណន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃស្តីពីការកំណត់លក្ខណៈសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំងរបស់ទណ្ឌិតក្នុងពន្ធនាគារ ដែលជាឯកសារគតិយុត្តថ្មី និងជាមូលដ្ឋានគ្រឹះសម្រាប់ប្រតិបត្តិការគ្រប់គ្រង និងអប់រំកែប្រែដល់ជនជាប់ឃុំក្នុងពន្ធនាគារ **និងជាពិសេសសម្រាប់ពេលនេះគឺសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថ្មី ឆ្នាំ២០១៤-២០១៨ របស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលយើងទើបបានពិនិត្យ និងពិភាក្សាកែសម្រួលនាពេលនេះជាឧទាហរណ៍ស្រាប់**។

ឯកឧត្តម **នុត សាវអាន** បានមានប្រសាសន៍សង្កត់ធ្ងន់ថា : ដើម្បីឱ្យផែនការយុទ្ធសាស្ត្រនេះ បានក្លាយទៅជាសកម្មភាពជាក់ស្តែង និងប្រែក្លាយផែនការទៅជាសមិទ្ធផលជាក់ស្តែង ដូចដែលអគ្គនាយកដ្ឋានពន្ធនាគាររំពឹងចង់បាននោះ **គឺនៅពេលដែលសេចក្តីព្រាងនេះក្លាយជាផែនការយុទ្ធសាស្ត្រផ្លូវការហើយនោះ គ្រប់អង្គភាពចំណុះអគ្គនាយកដ្ឋានពន្ធនាគារត្រូវយកចិត្តទុកដាក់អនុវត្តជំរុញការកសាងផែនការសកម្មភាពរបស់ខ្លួនតាមផ្នែកនីមួយៗ ដោយធ្វើការត្រួតពិនិត្យតាមដានការអនុវត្តនៃផែនការយុទ្ធសាស្ត្រជាប្រចាំតាមការកំណត់ជាក់លាក់** ៕ *លន់*

# បូសថ្លើមមានសញ្ញាអ្វីខ្លះ?




ជម្ងឺបូសថ្លើមដែលបង្កឡើងដោយពពួកមេរោគបាក់តេរីវាជាករណីមួយកម្រខ្លាំងណាស់ ។ នៅក្នុងឆ្នាំ ១៩៣៨ លោក Ochnser បានបង្កើតជាវិធីវះកាត់បង្ហូរខ្ទុះចេញសម្រាប់ជាវិធីព្យាបាល ទោះបីជាការព្យាបាលមួយនេះមានលក្ខណៈប៉ះពាល់ខ្លាំងដល់អ្នកជំងឺក៏ដោយ ក៏អត្រាស្លាប់អាចមានចំនួនពី ៦០ ទៅ៨០ភាគរយដែរ។

**ជម្ងឺបូសថ្លើមត្រូវបានបែកចែកជាបីប្រភេទដោយយោងទៅតាមមូលហេតុរបស់វា៖**

- បូសថ្លើមប្រភេទ Pyogenic ដែលមានបង្កឡើងដោយមេរោគច្រើនក្នុងថ្លើម ហើយជម្ងឺនេះមានចំនួនរហូតដល់ ៨០%នៃករណី។

- បូសថ្លើមប្រភេទ Amebic Abscess ដែលបង្កឡើងដោយពពួកអាមីុប Entamoeba Histolytica ដែលមានចំនួន ១០%នៃករណី ។

- បូសថ្លើមប្រភេទ Fungal ដែលបង្កឡើងដោយពពួកមេរោគផ្សិត Candida ហើយមានចំនួនមកដល់ ១០%នៃករណីផង ។

រោគសញ្ញាដែលកើតមានជាញឹកញាប់បំផុតនៃជម្ងឺបូសថ្លើមមានដូចជា៖ ក្តៅខ្លួន គ្រុនញ៉ាក់ ឈឺពោះផ្នែកខាងលើ និងខាងស្តាំ មិនឃ្លានអាហារ អស់កម្លាំង ក្អក ឈឺចាក់មកស្មាខាងស្តាំ ។

**ការពិនិត្យលើរាងកាយ**

- ការក្តៅខ្លួន និងថ្លើមរីកធំ គឺជាសញ្ញាច្រើនតែកើតមានញឹកញាប់បំផុត

- តឹងនៅតំបន់ចុងដង្ហើមតិចតួច ដែលអាចស្ទាបប៉ះ ឬមិនប៉ះដុំសាច់

- សម្លេងដកដង្ហើមថយចុះនៅបាតសួតខាងស្តាំ

- ស្បែកទៅជាលឿង៕

*ប៉ុក រដ្ឋា*

*ដកស្រង់ពី Health.com.kh*



វេជ្ជបណ្ឌិត ញៀម សុខ
បន្ទប់ពិនិត្យ-ពិគ្រោះនិងព្យាបាលជំងឺ

- ឯកទេសផ្នែកជំងឺទូទៅ និងរូបភាពវេជ្ជសាស្ត្រ
- មានពិនិត្យអេកូសាស្ត្រពណ៌ ផ្នែក :
  - សរីរាង្គក្នុងពោះមាន : ថ្លើម, ប្រមាត់, លំពែង, បំពង់បង្ហូរទឹកប្រមាត់, តម្រងនោម ។
  - សរីរាង្គរោគស្ត្រី : ស្បូន, ដៃស្បូន, និងពិនិត្យផ្ទៃពោ
  - សរីរាង្គក្រពេញទារ៉ូអុីដ : ពកក
- មានបទពិសោធន៍ក្នុងការងារពិនិត្យ និងព្យាបាលជំងឺរយៈពេល២០ឆ្នាំ ។

បញ្ចុះតម្លៃ 10% សម្រាប់មន្ត្រីនគរបា





អាសយដ្ឋានផ្ទះលេខ១៣៨អឺសូន្យ ផ្លូវ២១៥ (នេរុហ៊ី) សង្កាត់វា
ខណ្ឌ៧មករា រាជធានីភ្នំពេញ (ខាងត្បូងស្តុបផ្សារដេប៉ូចម្ងាយ៥០
ទូរស័ព្ទ : 097 2666 215 / 012 848 917

សិប្បកម្មផលិត ទឹកស៊ីអ៊ីវ ទឹកត្រី
សញ្ញាហង្សមាស
-មានគុណភាពល្អ
-មានរស់ជាតិឈ្ងុយឆ្ងាញ់ពិសារ



-ទឹកស៊ីអ៊ីវ ម៉ាហ្ស៊ី OK ផលិតចេញពី សណ្តែកសៀងសុទ្ធ
-ទឹកត្រីរួប មិកចិរ ផលិតតាមលក្ខណៈបច្ចេកទេសទំនើប
-មានលក់ដុំ និងលក់រាយ នៅផ្ទះលេខ 025K ផ្លូវ ៥៩៨ ក្រុមទី ៩ មណ្ឌល ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌ
Tel : (011) 88 29 22 / (011) 70 76 5

-មានច្បាប់អនុញ្ញាត លេខ៩៧៨ឧ.ថឧក សប្រក ចុះថ្ងៃ ទី២៩ ខែសីហា ឆ្នាំ ២០០២ របស់ក្រសួងឧស្សាហ៍កម្មរ៉ែ និង ថាមពល



តមកពីទំព័រ ៤៧

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង : "...**

ពិភាក្សាតាមក្រុមលើប្រធានបទធំៗមួយចំនួន ដោយមានមន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធចូលរួមផ្លាស់ប្តូរយោបល់គ្នាអំពីបទពិសោធន៍ចំណុចខ្លាំង ចំណុចខ្សោយដំណោះស្រាយ ដែលពាក់ព័ន្ធនឹងការងាររៀបចំការបោះឆ្នោតក្នុងគោល

លើសពីនេះទៀត អង្គសន្និបាតបានវាយតម្លៃល្អប្រសើរចំពោះដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ជាមួយគ្នានេះដែរតាមរយៈកិច្ចពិភាក្សារយៈពេលពីរថ្ងៃសន្និបាតបានកត់សម្គាល់នូវការងារមួយចំនួនដែលត្រូវបន្តពង្រឹងការគោរព និងអនុវត្តម៉ឺងម៉ាត់ច្បាប់បោះឆ្នោតបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ការតាមដានត្រួតពិនិត្យ ការងារ

កិច្ចល្អប្រសិទ្ធភាពការងារ និងបង្កើនសមត្ថភាពជំនាញដល់មន្ត្រីរៀបចំការបោះឆ្នោត។

៣-លើកកម្ពស់ការយល់ដឹងរបស់សាធារណជន ពិសេសយុវជន-យុវនារីអំពីការបោះឆ្នោត និងការចូលរួមក្នុងការបោះឆ្នោត។

៤-ពង្រឹងកិច្ចសហការល្អជាមួយគ្រប់ភាគីពាក់ព័ន្ធ។

ឯកឧត្តម **អ៊ឹម សួស្តី** មានប្រសាសន៍




**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង និងឯកឧត្តម អ៊ឹម សួស្តី អញ្ជើញជាអធិបតីក្នុងអង្គពិធី**



**ឯកឧត្តម ទេព នីថា**

បំណងធ្វើការកែតម្រូវ កែលម្អការអនុវត្តន៍ការងារបោះឆ្នោតនៅពេលខាងមុខឱ្យបានកាន់តែល្អប្រសើរត្រឹមត្រូវតាមច្បាប់ និងបទបញ្ជា ព្រមទាំងមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ អង្គសន្និបាតបានដំណើរទៅដោយភាពរលូនល្អ និងដោយមានការចូលរួមយោបល់យ៉ាងផុសផុលពីសំណាក់សមាជិក-សមាជិកាដែលចូលរួម។

បណ្តុះបណ្តាលបង្កើនសមត្ថភាពមន្ត្រីបោះឆ្នោតគ្រប់ជាន់ថ្នាក់ និង ការអប់រំសាធារណជនពិសេសយុវជន-យុវនារីពីការបោះឆ្នោត។

ឯកឧត្តម **ទេព នីថា** បានបញ្ជាក់ឱ្យដឹងទៀតថា : ចំណុចសំខាន់មួយចំនួនដែលត្រូវបន្តអនុវត្តនាពេលខាងមុខមានដូចជា :

១-ផ្តែកលើច្បាប់បោះឆ្នោតដែលនៅជាធរមាន គ.ជ.ប នឹងខិតខំបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ ពិសេសក្នុងការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌអាណត្តិទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ខាងមុខនេះ។

២-ពង្រឹងការគ្រប់គ្រងការងារអភិបាល

បញ្ជាក់ថា : ចាប់តាំងពីឆ្នាំ១៩៩៨មកប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯងដោយមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលហៅកាត់ថា **គ.ជ.ប** មានភារកិច្ចទទួលខុសត្រូវធ្វើផែនការរៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងទូទាំងប្រទេស។ គិតមកដល់នឹងពេលនេះ យើងបានរៀបចំការបោះឆ្នោតទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចំនួន ១១លើករួចមកហើយ ក្នុងនោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានរៀបចំការបោះឆ្នោតសកលចំនួន៧លើក។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ ឆ្នាំ ១៩៩៨ ត្រូវបានអង្គការអន្តរជាតិវាយតម្លៃ

តទៅទំព័រ ១៦

តមកពីទំព័រ ២៨

**ឯកឧត្តម ម៉ៅ សុផាន់ណា អនុរដ្ឋលេខាធិការ...**

បទបង្ហាញរបស់ក្រុមហ៊ុនសាជីវកម្ម **FOVAL CORPORATION** ជាក្រុមហ៊ុនធំជាងគេរបស់អាមេរិក **ដាន់ អេន ប្រេដស្ទ្រី (DAN AND BRADSTREE.,LNC)** ដែលជាក្រុមហ៊ុនផ្តល់ផ្តង់ព័ត៌មានហិរញ្ញវត្ថុពាណិជ្ជកម្មធំឈានមុខគេក្នុងពិភពលោកមានទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាលនៃបណ្តាប្រទេសនៅអឺរ៉ុប និងអាស៊ីយ៉ាងច្រើនដែលជាដៃគូក្នុងការផ្លាស់ប្តូរព័ត៌មានគ្នា ដើម្បីបង្ការទប់ស្កាត់បទល្មើសអន្តរជាតិផ្សេងៗ **រួមមានបទល្មើសលាងលុយកខ្វក់ សហគ្រាសអាជីវកម្មមិនស្របច្បាប់ដែលដឹកនាំដោយជនសង្គមងងឹត និងបញ្ហាភេរវកម្ម ។ល ។** ទន្ទឹមនេះគណៈប្រតិភូបានបន្តធ្វើទស្សនកិច្ចទៅកាន់ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយ និង អគ្គិភ័យរបស់ជប៉ុនផងដែរ ។ ដោយឡែកក្រុមការងារក៏បានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយឯកឧត្តម **តូស៊ីអូ អ៊ូស៊ី** ប្រធានភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយអគ្គិភ័យ និងមន្ត្រីពាក់ព័ន្ធជាច្រើនទៀត ។



ឯកឧត្តម ម៉ៅ សុផាន់ណា និងគណៈប្រតិភូអញ្ជើញទស្សនកិច្ច ក្រុមហ៊ុនថៃកូកុ ងាតាប៉ែង

មិនតែប៉ុណ្ណោះ គណៈប្រប្រតិភូក្រុមការងារក៏បានបន្តបំពេញទស្សនកិច្ចទៅកាន់ទីភ្នាក់ងារនគរបាលជាតិជប៉ុនក្នុងគោលបំណងសិក្សាពីប្រព័ន្ធច្បាប់ផ្សេងៗពាក់ព័ន្ធទៅនឹងការគ្រប់គ្រងស្ថាប័នស៊ើបអង្កេតឯកជនជប៉ុន និងស្តាប់ការបកស្រាយលើបទបង្ហាញរបស់នាយនគរបាលជាតិជាន់ខ្ពស់ជប៉ុនក្នុងការបង្ក្រាបបទល្មើសផ្សេងៗ ការលាងលុយកខ្វក់ ការបំបាត់អំពើពុករលួយតាមរយៈការគ្រប់គ្រងឱ្យមានប្រសិទ្ធភាពក្នុងស្ថាប័នស៊ើបអង្កេតឯកជន និងក្រុមហ៊ុនគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុឯកជន ។ មិនតែប៉ុណ្ណោះ ក្រុមការងារបានបន្តជួបស្វែងយល់ និង ទទួលការពន្យល់លើបទបង្ហាញជុំវិញបទពិសោធន៍របស់ក្រុមហ៊ុនឯកជនមួយទៀត ឈ្មោះ **ថៃតាន់ (TEI TAN)** ដែលក្រុមហ៊ុននេះត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩១៦ និងជាក្រុមហ៊ុនមានបទពិសោធន៍ខ្ពស់ក្នុងការស៊ើបអង្កេតសាវតារបុគ្គល និងបានចូលរួមជាសមាជិកនៃសហគមន៍ស៊ើបអង្កេតពិភពលោក **(WORLD ASSOCIATION OF DETECTIVE)** ហើយក៏ធ្លាប់មានកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ននគរបាលជាតិ និងក្រុមហ៊ុនគ្រប់គ្រងព័ត៌មានឯកជនក្នុងការចែករំលែកព័ត៌មានគ្នា ។ សំខាន់ជាងនេះទៀត ក្រុមហ៊ុនក៏មានបុគ្គលិកភាគច្រើនជាអតីតមន្ត្រីនគរបាលជំនាញចូលនិវត្តន៍របស់ជប៉ុនទៀតផង ។





ឯកឧត្តម ម៉ៅ សុផាន់ណា និងគណៈប្រតិភូក្នុងជំនួបពិភាក្សាការងារ និងថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំក្រុមហ៊ុនថៃកូកុ ងាតាប៉ែង

តាមរយៈនៃជំនួបពិភាក្សាជាបន្តបន្ទាប់ ភាគីទាំងពីរបានយល់ស្របគ្នាទៅលើចំណុចរួមដោយទទួលបាននូវបទពិសោធន៍ថ្មីពាក់ព័ន្ធទៅនឹងប្រព័ន្ធគ្រប់គ្រងស្ថាប័នស៊ើបអង្កេតឯកជន ដែលមានកិច្ចសហការជាមួយស្ថាប័ននគរបាលជាតិ រួមចំណែកក្នុងកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និង ស្ថេរភាពសង្គម ៕ *សុទ្ធី*

តមកពីទំព័រ ២៤

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង...**



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញកាត់ខ្សែបូរសម្ពោធដាក់ឱ្យប្រើប្រាស់មជ្ឈមណ្ឌល




អំណោយសម្ភារៈគ្រឿងយន្តកសិកម្មរបស់ជប៉ុនជូនដល់ប្រទេសកម្ពុជា

កសិករអាចប្រតិបត្តិជាក់ស្តែងបាន។ មិនតែប៉ុណ្ណោះទៅអនាគត អង្គការ **ស៊ី អាយ អ៊ី អែស អែហ្វ** ក៏មានគម្រោងផ្តល់ការគាំទ្របន្តទៀត តាមរយៈសិក្ខាសាលាបណ្តុះបណ្តាលសំដៅពង្រឹងចំណេះដឹងខាងការប្រតិបត្តិម៉ាស៊ីន ក៏ដូចជាការថែទាំម៉ាស៊ីនផងដែរ។

ឯកឧត្តម **យូជី គូម៉ាម៉ារូ** មានប្រសាសន៍បញ្ជាក់ថា : មជ្ឈមណ្ឌលបណ្តុះ និងចែកចាយពូជដំឡូងមី ដែលត្រូវបានសាងសង់ក្រោមជំនួយឧបត្ថម្ភរបស់ជប៉ុន គឺមានគោលដៅកែលម្អផលិតភាពនៃការដាំដុះដំឡូងមីក្នុងខេត្តបាត់ ដំបង តាមរយៈការបណ្តុះ និងចែកចាយពូជដំឡូងមី ដែលគ្មានមេរោគនេះជូនដល់ប្រជាកសិករដើម្បីបង្កើនការដាំដុះ និងអាចទទួលបានប្រភពចំណូលគ្រួសារ។ ទន្ទឹមនេះដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា រាជរដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការស្តារប្រព័ន្ធធារាសាស្ត្រ ក៏ដូចជាការផ្ទេរនូវបច្ចេកទេសធ្វើកសិកម្មជាដើម ដែលជាកត្តាគន្លឹះដើម្បីកាត់បន្ថយនូវភាពក្រីក្រ និងអភិវឌ្ឍជនបទក្នុងប្រទេសកម្ពុជា ដែលរាជរដ្ឋាភិបាលបានសម្រេចយ៉ាងត្រឹមត្រូវក្នុងការផ្តល់អទិភាពខ្ពស់លើវិស័យនេះ។

អញ្ជើញមានប្រសាសន៍ក្នុងពិធីនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រជាជនរាជរដ្ឋាភិបាល និងក្រុមហ៊ុនជប៉ុនដែលតែងតែបានផ្តល់នូវការជួយឧបត្ថម្ភគាំទ្រជាច្រើនមកដល់ប្រទេសកម្ពុជា ជាពិសេសអង្គការ **ស៊ី អាយ អ៊ី អែស អែហ្វ** និងក្រុមហ៊ុនជប៉ុន **ជី អិល ហ្វាយនែន** ដែលបានជួយអភិវឌ្ឍសកលវិទ្យាល័យបាត់ដំបងឱ្យកាន់តែរីកចម្រើនឡើងថែមទៀត រួមចំណែកក្នុងការពង្រឹងគុណភាពសិក្សា ស្រាវជ្រាវ ផ្តល់ឱកាសឱ្យសាស្ត្រាចារ្យ និងនិស្សិតបានអនុវត្តជាក់ស្តែង ព្រមទាំងអាចជួយដោះស្រាយបញ្ហាកសិករកំពុងជួបប្រទះបានមួយកម្រិតថែមទៀត ធ្វើឱ្យទិន្នផលផលិតផល និងប្រាក់ចំណូលរបស់កសិករមានកំណើនកាន់តែប្រសើរឡើង។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីមានប្រសាសន៍បញ្ជាក់បន្តទៀតថា : យុទ្ធសាស្ត្រចតុកោណក្នុងដំណាក់កាលទី៣ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី** នៅតែបន្តយកចិត្តទុកដាក់លើវិស័យអប់រំសិក្សាធិការ។ រាជរដ្ឋាភិបាលបន្តកសាង និងអភិវឌ្ឍធនធានមនុស្សលើគ្រប់ផ្នែក ប្រកបដោយគុណភាព និងគុណធម៌ល្អប្រពៃ ដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ដើម្បីកសាងប្រទេសកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើនជឿនលឿន ដែលផ្អែកលើមូលដ្ឋានចំណេះដឹងលើគ្រប់វិស័យ រួមទាំងខាងវិទ្យាសាស្ត្របច្ចេកទេស និងចំណេះធ្វើ ហើយដើរស្របជាមួយនឹងការរីកចម្រើននៃបណ្តាប្រទេសក្នុងតំបន់ និងសកលលោក។ លើសពីនេះទៀតរាជរដ្ឋាភិបាលក៏បានបន្តអភិវឌ្ឍវិស័យកសិកម្មឱ្យក្លាយជាផ្នែកនាំមុខ ដែលមានប្រៀបខ្លាំងពិតប្រាកដ ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព ធានាសន្តិសុខស្បៀង បង្កើនការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជន ជាពិសេសប្រជាជននៅជនបទ ហើយរួមចំណែកដល់ការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ៕ *សុខគីម*

22/5/23, 10:12 AM

តមកពីទំព័រ ០៦

## ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី...

របស់ក្រសួងមហាផ្ទៃត្រូវបានបង្កើតឡើងក្នុងគោលដៅកែសម្រួលប្រព័ន្ធគ្រប់គ្រងនិងលើកកម្ពស់លក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំឲ្យស្របតាមនិន្នាការតំបន់ ទាំងផ្នែកគ្រប់គ្រងសម្ភារៈ និងបច្ចេកវិទ្យា ពិសេសផ្តោតលើការយកចិត្តទុកដាក់ទៅលើសេវាសុខភាពនិងកម្មវិធីអប់រំស្មារនីតិសម្បទាដល់ជនជាប់ឃុំ។ ក្នុងស្មារតីនេះក្រោមការដឹកនាំផ្ទាល់ពីឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សេវាសុខភាពពន្ធនាគារ និងកម្មវិធីអប់រំស្មារនីតិសម្បទាត្រូវបានមជ្ឈដ្ឋានទូទៅទទួលស្គាល់ថាមានការអភិវឌ្ឍន៍ប្រែប្រួលរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទន្ទឹមនឹងនេះយើងក៏ទទួលស្គាល់ដែរថាកិច្ចសហប្រតិបត្តិការល្អពីបណ្តាអង្គភាពស្ថាប័នពាក់ព័ន្ធអង្គការសហគមន៍ជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍នានាគឺជាកត្តាចាំបាច់មិនអាចខ្វះបានក្នុងការចូលរួមចំណែកកែលម្អសេវាពន្ធនាគារពិសេសគឺសេវាសុខភាពនិងកម្មវិធីអប់រំស្មារនីតិសម្បទា ដើម្បីធ្វើឲ្យសម្រេចបានជោគជ័យតាមគោលការណ៍នៃក្របខ័ណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគាររបស់ក្រសួងមហាផ្ទៃ។

ឯកឧត្តមបានបន្តទៀតថា ៖ សេវាសុខភាពពន្ធនាគារ និងការអប់រំស្មារនីតិសម្បទា គឺជាកិច្ចការចម្បងរបស់អគ្គនាយកដ្ឋានពន្ធនាគារដែលបាននិងកំពុងខិតខំប្រឹងប្រែងយកចិត្តទុកដាក់ខ្ពស់ ក្នុងការប្រឈមមុខដោះស្រាយកែលម្អ និងធ្វើការពង្រឹងគុណភាពជាបន្តបន្ទាប់។ ទន្ទឹមនេះ ដោយយល់ឃើញថាសេវាសុខភាពពន្ធនាគារនិងកម្មវិធីអប់រំស្មារនីតិសម្បទាមានសារៈសំខាន់ និងជាការងារអាទិភាពក្នុងចំណោមការងារចម្បងនានាដែលទាមទារឲ្យមានកិច្ចសហប្រតិបត្តិការពីដៃគូនានា និងដោយបានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានពន្ធនាគារបានសហការជាមួយអង្គការការីតាសកម្ពុជា បន្តគម្រោងគាំទ្រសេវាសុខភាព និងកម្មវិធីអប់រំស្មារនីតិសម្បទា ដោយផ្តោតសំខាន់ទៅលើជំងឺរបេងអេដស៍ និងរបេង-អេដស៍ក្នុងពន្ធនាគារ។




ឯកឧត្តម នុត សាអាន អញ្ជើញមានមតិសំណេះសំណាលក្នុងពិធី

លោក **គឹម រតនា** បានបញ្ជាក់ថា ដោយបានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អង្គការការីតាសបានសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារបន្តអនុវត្តគម្រោងគាំទ្រសេវាសុខភាព និងកម្មវិធីអប់រំស្មារនីតិសម្បទា ជាពិសេសជំងឺរបេង អេដស៍ និងរបេងអេដស៍ក្នុងពន្ធនាគារខេត្តចំនួន៧ គឺ ៖ **ខេត្តសៀមរាប កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី** ដើម្បីបន្តពង្រឹងប៉ុស្តិ៍សុខភាព ដែលមានហេដ្ឋារចនាសម្ព័ន្ធស្របតាមបទដ្ឋានរបស់ក្រសួងសុខាភិបាល។ ហើយការណ៍នេះយើងផ្តោតការយកចិត្តទុកដាក់ជាអាទិ៍ ៖

-ពង្រឹងប្រព័ន្ធការងារសម្របសម្រួ
ការត្រួតពិនិត្យនិងវាយតម្លៃក្នុងភាពជាដៃ
ជាមួយអគ្គនាយដ្ឋានពន្ធនាគារ។

-ពង្រឹងសមត្ថភាពមន្ត្រីប៉ុស្តិ៍សុខភា
និងមន្ត្រីពន្ធនាគារ ដើម្បីឲ្យពួកគេអាចមា
សមត្ថភាពផ្តល់សេវាកម្មសុខភាពបឋមដ
ជនជាប់ឃុំ។

-ផ្តល់ការថែទាំ និងព្យាបាលសុខភា
បឋម ប្រកបដោយប្រសិទ្ធភាព និងមនុស្
ធម៌ដល់ជនជាប់ឃុំ ព្រមទាំងមន្ត្រីពន្ធនាគា
ដែលមានបញ្ហាសុខភាពប្រចាំថ្ងៃ។

-ផ្តល់មធ្យោបាយក្នុងការថែទាំបន្តដើម្
ធានាទទួលបានការព្យាបាលពេញលេ
ក្រោយពេលដោះលែងពីពន្ធនាគារ។

-អប់រំឲ្យមានការផ្លាស់ប្តូរឥរិយាប
លុបបំបាត់ការរើសអើងចំពោះអ្នកជំងឺរបេ
អ្នកផ្ទុកមេរោគអេដស៍ ជំងឺរបេងអេដស៍ និ
អ្នកប្រើប្រាស់គ្រឿងញៀន។

-ផ្តល់ការអប់រំបំណិនជីវិត និងបណ្ដុ
បណ្ដាលវិជ្ជាជីវៈ កាត់ដេរ កាត់សក់ ជំនាញ
កុំព្យូទ័រនិងសិប្បកម្មខ្នាតតូចដល់ជនជាប់ឃុំ

អញ្ជើញមានប្រសាសន៍ក្នុងឱកាស
នោះ ឯកឧត្តម **នុត សាអាន** បានបញ្ជាក់
ថា ៖ ក្រសួងមហាផ្ទៃមានគោលដៅកែសម្រួល
ប្រព័ន្ធគ្រប់គ្រង និង លើកកម្ពស់លក្ខខណ្ឌ
រស់នៅរបស់ជនជាប់ឃុំឲ្យស្របតាមនិន្នាការ
តំបន់ និងឈានជាបណ្តើរទៅតាមនិន្នាការ
ពិភពលោកទាំងផ្នែកគ្រប់គ្រងសម្ភារៈ និង
បច្ចេកវិទ្យា ពិសេសផ្តោតការយកចិត្តទុកដាក់
ទៅលើសេវាសុខភាពរបស់ជនជាប់ឃុំ។
ឯកឧត្តមបានបន្តទៀតថា ៖ កិច្ចសហប្រតិ
បត្តិការល្អពីបណ្តាអង្គភាពស្ថាប័នពាក់ព័ន្ធ
អង្គការសហគមន៍ជាតិ-អន្តរជាតិ និងដៃគូ
អភិវឌ្ឍនានាគឺជាកត្តាមិនអាចខ្វះបានឡើយ
ក្នុងការចូលរួមចំណែកកែលម្អសេវាសុខភាព
ពន្ធនាគារ ពិសេសគឺដើម្បីធ្វើឲ្យសម្រេចបាន
ជោគជ័យតាមគោលការណ៍នៃក្របខណ្ឌ
គោលនយោបាយកំណែទម្រង់ពន្ធនាគារ
របស់ក្រសួងមហាផ្ទៃ ៕ *លន់*



https://online.fliphtml5.com/vhqfg/gmza/

**តមកពីទំព័រ ២០**

**នគរបាលអន្តរជាតិកម្ពុជាធ្វើជាម្ចាស់ផ្ទះ...**

សូត្រពីវិធីសាស្ត្រនៃការបង្ក្រាបនោះផងដែរ។

ទន្ទឹមនេះតាមរយៈការធ្វើបទបង្ហាញពីបណ្តាប្រទេសចូលរួម អង្គប្រជុំទាំងមូលបានសង្កេតឃើញថាទ្រង់ទ្រាយនៃបទឧក្រិដ្ឋដែលមានអង្គការចាត់តាំងមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺប្រភេទនៃបទល្មើស ដែលវាមានលក្ខណៈប្រហាក់ប្រហែលគ្នា ពោលគឺបទឧក្រិដ្ឋដែលមានអង្គការចាត់តាំងភាគច្រើននៅតំបន់អាស៊ី **គឺការជួញដូរគ្រឿងញៀន ការលាងលុយកខ្វក់ ការជួញដូរមនុស្ស និងល្បែងស៊ីសងខុសច្បាប់ជាដើម។**

ពាក់ព័ន្ធចំពោះវិធីសាស្ត្រនៃការបង្ក្រាបបទល្មើសទាំងនោះវិញ អង្គប្រជុំទាំងមូលបានឯកភាពគ្នាថា ៖ ដើម្បីបង្ក្រាបនិងបង្ការបទល្មើសទាំងនោះឲ្យបានជោគជ័យគឺតម្រូវឲ្យមានច្បាប់ ឬសន្ធិសញ្ញាអន្តរជាតិឲ្យបានច្បាស់លាស់ ហើយមានមន្ត្រីជំនាញអនុវត្តច្បាប់ដ៏មានប្រសិទ្ធភាព ដើម្បីផ្តន្ទាទោសដល់ឧក្រិដ្ឋជនទាំងនោះ។ លើសពីនេះទៅទៀត ការសហការជាមួយមជ្ឈដ្ឋានខាងក្រៅដូចជាក្រុមហ៊ុនឯកជន ធនាគារ និងប្រជាពលរដ្ឋ ក្នុងការផ្តល់ព័ត៌មានក៏ជាការរួមចំណែកយ៉ាងសំខាន់ ក្នុងការធ្វើឲ្យការបង្ក្រាបបទល្មើសខាងលើមានប្រសិទ្ធភាពផងដែរ។ ចំណុចសំខាន់មួយទៀតគឺ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក៏មានសារៈសំខាន់ផងដែរ ដោយហេតុថាបណ្តាឧក្រិដ្ឋជនទាំងនោះ មានអង្គការចាត់តាំង និងមានបណ្តាញជាច្រើននៅលើសកលលោក។ ហេតុដូចនេះ ចាំបាច់ត្រូវតែមានការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងប្រទេសជាសមាជិក ដើម្បីទប់ស្កាត់បទឧក្រិដ្ឋទាំងនោះ។

ដោយឡែក មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាននគរបាលអន្តរជាតិ ក៏បានធ្វើបទបង្ហាញស្តីពីគម្រោងថ្មីរបស់ INTERPOL ផងដែរដែលមានឈ្មោះថា Operation SOGA ដែលជាប្រតិបត្តិការប្រឆាំងនឹងការភ្នាល់បាល់ខុសច្បាប់។ ហើយការបង្កើតគម្រោងថ្មីនេះ គឺដោយសារតែនាពេលបច្ចុប្បន្នបទល្មើសថ្មីមួយនេះ កំពុងតែមានការរីកដុះដាលនៅក្នុងសង្គម។ ហេតុដូចនេះហើយ អគ្គលេខាធិការដ្ឋាននគរបាលអន្តរជាតិ **សំណូមពរដល់បណ្តាប្រទេសសមាជិកទាំងអស់ ចូលរួមឲ្យបានសកម្មនៅក្នុងកិច្ចប្រតិបត្តិការមួយនេះ។**

គួរបញ្ជាក់ដែរថា ៖ កិច្ចប្រជុំលើកទី១៣នេះបានធ្វើការវាយតម្លៃថា ៖ ឧក្រិដ្ឋកម្ម ដែលមានអង្គការចាត់តាំងនាពេលបច្ចុប្បន្ន គឺកំពុងគំរាមកំហែង មិនត្រឹមតែអាយុជីវិតនិងសន្តិសុខរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ វាថែមទាំងជះឥទ្ធិពលអាក្រក់ដល់វិស័យសេដ្ឋកិច្ច សង្គម និងសន្តិសុខរបស់ប្រទេសជាតិទាំងមូលផងដែរ។ ហើយស្ថានភាពនៃបទឧក្រិដ្ឋនេះមានទ្រង់ទ្រាយខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ដែលបញ្ហានេះទាមទារឲ្យនគរបាលជាតិនៃប្រទេសនីមួយៗ ត្រូវតែស្វែងយល់អំពីបញ្ហានេះទៅវិញទៅមកឲ្យបានច្បាស់លាស់ **ព្រោះថាឧក្រិដ្ឋកម្មមានអង្គការចាត់តាំង គឺពុំមែនកើតឡើងតែក្នុងដែនដីរបស់ប្រទេសមួយនោះឡើយ ផ្ទុយទៅវិញ ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង គឺជាបញ្ហាប្រឈមមួយសម្រាប់ពិភពលោកទាំងមូល** ៕ *ពុទ្ធារិទ្ធិ*

**តមកពីទំព័រ ២៩**

**ពិធីប្រគល់-ទទួលសម្ភារៈ BLO...**

១.៣ សកម្មភាពទី៤ ថែងអមពីការបំពាក់សម្ភារៈ និងការដាក់ឱ្យដំណើរការក្រោយទិន្នផល ១.៣ សកម្មភាពទី១ និងទី៣រហូតបានបញ្ចប់។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស វីរិទ្ធិ** បានមានប្រសាសន៍ថា : ពិធីប្រគល់-ទទួលសម្ភារៈសម្រាប់ការិយាល័យ **BLO** ចំនួន៥កន្លែងនាពេលនេះ គឺមាន៤ទីតាំងស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និង១ទីតាំងទៀតស្ថិតនៅតាមព្រំដែនកម្ពុជាវៀតណាម ។ ការិយាល័យ **BLO** ទាំង៥កន្លែងនេះនឹងដើរតួនាទីសំខាន់ក្នុងការបង្ការទប់ស្កាត់រាល់បទល្មើសឆ្លងកាត់ព្រំដែនប្រទេស ពិសេសការចែករំលែកព័ត៌មានឱ្យគ្នាទៅវិញទៅមកទាំងភាគីជាតិ និងដៃគូអន្តរជាតិឱ្យបានទាន់ពេលវេលាឈានទៅទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសនានាឱ្យមានប្រសិទ្ធភាពខ្ពស់។ ឯកឧត្តម បានបញ្ជាក់ទៀតថា : រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងទៅនឹងគ្រឿងញៀន និង ការគំរាមកំហែងនានានៅតាមបណ្តោយព្រំដែន ដើម្បីរួមចំណែកធ្វើឱ្យសម្រេចអាស៊ានគ្មានគ្រឿងញៀននៅឆ្នាំ២០១៥ដែលប្រមុខដឹកនាំអាស៊ានបានកំណត់យកជាគោលដៅ។

នៅចុងបញ្ចប់ ឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស វីរិទ្ធិ** ក៏បានសំណូមពរដល់តំណាងគណៈកម្មការត្រួតពិនិត្យគ្រឿងញៀនទាំងអស់ដែលមកទទួលយកសម្ភារៈ **BLO** នៅពេលនេះ សូមប្រើប្រាស់សម្ភារៈទាំងអស់ ដែលគម្រោង **PATROL** របស់អង្គការ **UNODC** បានប្រគល់ជូនសូមប្រើប្រាស់សម្ភារៈទាំងនេះឱ្យស្របតាមគោលបំណងរបស់គម្រោង និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ៕ *លីដា*

# បញ្ជីរាយនាម សមាជិក-សមាជិកាស.ម.ន ដែលបានទទួលមរណៈភាព

បញ្ជីរាយនាមរបស់សមាជិក-សមាជិកាស.ម.ន ដែលបានទទួលមរណៈភាព និងបាត់បង់សមត្ថភាពការងារ ដែ[...] ការិយាល័យនិពន្ធទស្សនាវដ្ដីមិត្តនគរបាលទទួលបានចាប់តាំងពីថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ រហូតដល់ថ្ងៃទី ២២ [...] វិច្ឆិកា ឆ្នាំ ២០១៣ មានចំនួន ៧៩នាក់ និងសរុបថវិកាអស់ចំនួន ៣១៦.០០០.០០០៛ ។

| ល.រ | នាម និងគោត្តនាម | ភេទ | មុខតំណែង | អង្គភាព | ថ្ងៃមរណភា[...] |
|---|---|---|---|---|---|
| ១ | វរសេនីយ៍ត្រី ដែង វុទ្ធី | ប | នាយរងការិយាល័យ | ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង | 27/08/13 |
| ២ | ព្រិន្ទបាលឯក គង់ សំណាង | ប | នាយរងប៉ុស្តិ៍ | ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង | 26/08/13 |
| ៣ | អនុសេនីយ៍ទោ អោម សុផល | ប | នាយរងផ្នែក | ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង | 01/09/13 |
| ៤ | ពលបាលឯក អ៊ុំ ផន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង | 29/08/13 |
| ៥ | អនុសេនីយ៍ទោ សេក ប៊ុនធឿន | ប | នាយផ្នែក | ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង | 17/09/13 |
| ៦ | អនុសេនីយ៍ឯក សោម ពុំ | ប | នាយផ្នែក | ស្នងការដ្ឋាននគរបាលខេត្តក្រចេះ | 02/08/13 |
| ៧ | អនុសេនីយ៍ឯក ផន់ ហុងដា | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ | 27/08/13 |
| ៨ | ពលបាលទោ វ៉ង់ សម្បត្តិ | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ | 25/07/13 |
| ៩ | អនុសេនីយ៍ត្រី ព្រហ្ម សុវណ្ណ | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 16/08/13 |
| ១០ | អនុសេនីយ៍ទោ នួន សុវណ្ណ | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 08/07/13 |
| ១១ | អនុសេនីយ៍ទោ ប៉ែន សម្បត្តិ | ប | នាយផ្នែក | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 19/08/13 |
| ១២ | អនុសេនីយ៍ត្រី សេង សម្ផស្ស | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 26/07/13 |
| ១៣ | ពលបាលឯក ផុន បូរី | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តសៀមរាប | 09/08/13 |
| ១៤ | អនុសេនីយ៍ត្រី មុី ហឿន | ប | នាយរងផ្នែក | ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ | 23/08/13 |
| ១៥ | អនុសេនីយ៍ឯក អ៊ិន សុខា | ប | នាយផ្នែក | សាលាបណ្ឌិតសភានគរបាល | 06/09/13 |
| ១៦ | អនុសេនីយ៍ត្រី ស្រ៊ុន សុខឃីម | ស | មន្ត្រី | នាយកដ្ឋាននគរបាលទេសចរណ៍ | 02/10/13 |
| ១៧ | ព្រិន្ទបាលទោ សោម សឿន | ប | មន្ត្រី | នាយកដ្ឋាននគរបាលការពារ | 18/08/13 |
| ១៨ | អនុសេនីយ៍ត្រី សួស ចំនួនបណ្ឌិត | ប | មន្ត្រី | នាយកដ្ឋាននគរបាលព្រំដែនគោក | 09/09/13 |
| ១៩ | អនុសេនីយ៍ទោ សំ សឿម | ប | មន្ត្រី | នាយកដ្ឋាននគរបាលព្រំដែនគោក | 13/09/13 |
| ២០ | ព្រិន្ទបាលឯក កែវ សុភា | ប | មន្ត្រី | នាយកដ្ឋានសន្តិសុខផ្ទៃក្នុង | 29/09/13 |
| ២១ | អនុសេនីយ៍ឯក ឈឹម សុខា | ប | នាយរងផ្នែក | អគ្គលេខាធិការដ្ឋាន | 14/09/13 |
| ២២ | ព្រិន្ទបាលឯក គីម យឿង | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម | 06/10/13 |
| ២៣ | អនុសេនីយ៍ត្រី ហ៊ុំ ហេង | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ | 28/09/13 |
| ២៤ | អនុសេនីយ៍ឯក កែវ វុទ្ធី | ប | នាយផ្នែក | ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ | 23/09/13 |
| ២៥ | ពលបាលឯក គង់ សំអឿន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ | 02/10/13 |
| ២៦ | ពលបាលឯក សៅ ម៉ុន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ | 25/09/13 |
| ២៧ | ព្រិន្ទបាលឯក មុី បូរី | ប | នាយរងប៉ុស្តិ៍ | ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង | 29/09/13 |
| ២៨ | ព្រិន្ទបាលឯក អយ វុត្ថា | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល | 18/09/13 |
| ២៩ | ពលបាលឯក ជុក ជា | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ | 30/08/13 |
| ៣០ | ព្រិន្ទបាលឯក សំ សារី | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង | 28/09/13 |
| ៣១ | អនុសេនីយ៍ទោ អ៊ុន សារូ | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង | 21/09/13 |
| ៣២ | អនុសេនីយ៍ទោ មុឹក ជឿន | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង | 23/09/13 |
| ៣៣ | អនុសេនីយ៍ទោ ហ៊ុន សារ៉ុម | ប | នាយប៉ុស្តិ៍ | ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង | 20/09/13 |
| ៣៤ | អនុសេនីយ៍ទោ ធិន ឆ្អឹម | ប | នាយប៉ុស្តិ៍ | ស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន | 29/08/13 |
| ៣៥ | វរសេនីយ៍ឯក សុខ សាម៉ន | ប | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានអង្គរក្ស | 07/10/13 |

| | | | | | |
|---|---|---|---|---|---|
| ៣៦ | អនុសេនីយ៍ទោ ហែន ណារ៉ា | ប | មន្ត្រីចូលនិវត្តន៍ | នាយកដ្ឋានបុគ្គលិក | 18/09/13 |
| ៣៧ | ព្រិន្ទបាលទោ កេត ស្រេង | ប | មន្ត្រីចូលនិវត្តន៍ | នាយកដ្ឋាននគរបាលការពារ | 20/10/13 |
| ៣៨ | ព្រិន្ទបាលទោ កែវ រតនា | ប | មន្ត្រី | នាយកដ្ឋាននគរបាលការពារ | 23/10/13 |
| ៣៩ | វរសេនីយ៍ត្រី លី ចំណាន | ប | មន្ត្រីចូលនិវត្តន៍ | អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាលនគរបាល | 19/10/13 |
| ៤០ | អនុសេនីយ៍ត្រី សុខ ពិសិដ្ឋ | ប | មន្ត្រី | អង្គភាពអន្តរាគមន៍ | 23/10/13 |
| ៤១ | អនុសេនីយ៍ត្រី សឹង ឈឹន | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង | 27/09/13 |
| ៤២ | ពលបាលឯក រ៉ែអល ធឿន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង | 17/09/13 |
| ៤៣ | អនុសេនីយ៍ទោ កាយ គុណ | ប | នាយប៉ុស្តិ៍ | ស្នងការដ្ឋាននគរបាលខេតសៀមរាប | 03/10/13 |
| ៤៤ | អនុសេនីយ៍ឯក ភុន ភាន់ | ប | អធិការរង | ស្នងការដ្ឋាននគរបាលខេត្តសៀមរាប | 08/10/13 |
| ៤៥ | អនុសេនីយ៍ទោ ផាន់ ចាន់ថន | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង | 12/10/13 |
| ៤៦ | ពលបាលទោ ខាត់ ឡឹប | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម | 14/10/13 |
| ៤៧ | អនុសេនីយ៍ត្រី ហេង ចាន់ថៃ | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម | 20/10/13 |
| ៤៨ | ព្រិន្ទបាលឯក សួ ឡុញ | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ | 09/10/13 |
| ៤៩ | វរសេនីយ៍ទោ ផេង សុផាត | ប | នាយការិយាល័យ | ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង | 14/09/13 |
| ៥០ | អនុសេនីយ៍ត្រី ខាំមី ខាំផែង | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង | 29/09/13 |
| ៥១ | ពលបាលទោ អាំ គុល | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង | 02/10/13 |
| ៥២ | វរសេនីយ៍ទោ ឌិន សុខា | ប | នាយការិយាល័យ | ស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ | 09/10/13 |
| ៥៣ | ពលបាលឯក សែម ធឿន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តកណ្តាល | 18/10/13 |
| ៥៤ | អនុសេនីយ៍ត្រី អៀ សំអាត | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ | 15/10/13 |
| ៥៥ | វរសេនីយ៍ត្រី ចៅ ផល្លា | ប | នាយរងការិយាល័យ | ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ | 18/10/13 |
| ៥៦ | អនុសេនីយ៍ឯក ហេង គីមណាត | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 28/08/13 |
| ៥៧ | អនុសេនីយ៍ទោ ង៉ែត ចិន្តា | ស | នាយរងផ្នែក | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 30/09/13 |
| ៥៨ | អនុសេនីយ៍ទោ ថ្លាង បុិណ្ណា | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 09/08/13 |
| ៥៩ | អនុសេនីយ៍ឯក កាក់ ប៊ុនថន | ប | នាយរងការិយាល័យ | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 01/10/13 |
| ៦០ | ពលបាលឯក ម៉ុន ថា | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ | 27/09/13 |
| ៦១ | ព្រិន្ទបាលទោ ជិន ជន | ប | មន្ត្រី | សេនាធិការដ្ឋាន | 16/10/13 |
| ៦២ | អនុសេនីយ៍ទោ ប៊ុន ផល្លី | ប | មន្ត្រីចូលនិវត្តន៍ | នាយកដ្ឋានភស្តុភារ និងសម្ភារៈបច្ចេកទេស | 10/11/13 |
| ៦៣ | អនុសេនីយ៍ទោ អៀង អន | ប | មន្ត្រីចូលនិវត្តន៍ | នាយកដ្ឋានអន្តោប្រវេសន៍ | 14/04/13 |
| ៦៤ | អនុសេនីយ៍ឯក ឌឹម វណ្ណៈ | ប | នាយរងផ្នែក | នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ | 18/11/13 |
| ៦៥ | ព្រិន្ទបាលទោ ឈឿ គាន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង | 20/10/13 |
| ៦៦ | ពលបាលឯក ឌី សាយ | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង | 21/10/13 |
| ៦៧ | ពលបាលឯក ចាម សំបូរ | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង | 02/11/13 |
| ៦៨ | ពលបាលឯក ស៊ុម ដារ៉ា | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង | 25/10/13 |
| ៦៩ | វរសេនីយ៍ត្រី សួង ប្រាណ | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តសៀមរាប | 02/11/13 |
| ៧០ | ព្រិន្ទបាលឯក លី វណ្ណារ៉ា | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តសៀមរាប | 19/10/13 |
| ៧១ | ពលបាលទោ ព្រីក សារឿន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តសៀមរាប | 05/11/13 |
| ៧២ | វរសេនីយ៍ត្រី ហុក ស៊ុយថាន់ | ប | នាយរងការិយាល័យ | ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ | 06/10/13 |
| ៧៣ | ព្រិន្ទបាលទោ ចេង ធារិទ្ធ | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ | 18/09/13 |
| ៧៤ | ព្រិន្ទបាលទោ ផន រឿន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ | 24/09/13 |
| ៧៥ | អនុសេនីយ៍ត្រី មាស ពោធិ | ប | នាយរងផ្នែក | ស្នងការដ្ឋាននគរបាលខេត្តកែប | 19/10/13 |
| ៧៦ | អនុសេនីយ៍ឯក ឡាក់ ម៉េង | ប | នាយផ្នែក | ស្នងការដ្ឋាននគរបាលខេត្តកែប | 21/10/13 |
| ៧៧ | អនុសេនីយ៍ត្រី មាស មេរ | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង | 24/10/13 |
| ៧៨ | ព្រិន្ទបាលទោ ស៊ួន សារួន | ប | មន្ត្រី | ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង | 17/11/13 |
| ៧៩ | អនុសេនីយ៍ឯក ជា វុទ្ធី | ប | មន្ត្រីចូលនិវត្តន៍ | ស្នងការដ្ឋាននគរបាលខេត្តកណ្តាល • | 29/10/13 |

**មកធ្វើការអភិវឌ្ឍន៍ជាបណ្តើរៗ ឆ្ពោះទៅរក** ការធ្វើវិមជ្ឈការពេញលេញនាថ្ងៃអនាគត។ ម្យ៉ាងទៀតកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា គឺធ្វើឡើងដោយឈរលើមូលដ្ឋាន **ធ្វើបណ្តើររៀនសូត្របណ្តើរ**។

ឯកឧត្តម **ហ៊ីរ៉ូស៊ី អ៊ីហ្សាគី** ប្រធានអង្គការ **JICA** ប្រចាំនៅកម្ពុជាបានមានប្រសាសន៍បញ្ជាក់ថា : ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដ៏មានសារៈសំខាន់ក្នុងរយៈពេលនេះគឺវាបានផ្តល់ផលវិជ្ជមានដល់ប្រទេសកម្ពុជា ហើយលើសពីនេះទៅទៀតគឺធ្វើឱ្យមានភាពល្អប្រសើរដល់ការធ្វើអភិបាលកិច្ចល្អ ដែលជាផ្នែកមួយជំរុញដល់ការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ឯកឧត្តមបានមានប្រសាសន៍បន្តទៀតថា : រាជរដ្ឋាភិបាលកម្ពុជាបានចាប់ដំណើរការ ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការចាប់តាំងពីមានការអនុម័តលើកម្មវិធីថ្នាក់ជាតិស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ **(SNDD)** នៅក្នុងខែឧសភា ឆ្នាំ២០០៩មកម្ល៉េះ។ ជាងនេះទៅទៀតអង្គការ **JICA** នៅតែបន្តជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីមូលដ្ឋានក្នុងការអនុវត្តច្បាប់ស្តីពីការរៀបចំអង្គការនៅថ្នាក់រាជធានី-ខេត្តចាប់តាំងពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១០ **(PILAC)** និងបន្តគម្រោង **(PILAC2)** តាំងពីខែមីនា ឆ្នាំ២០១០ មកដល់ពេលបច្ចុប្បន្ន។

គួរបញ្ជាក់ដែរថា : រយៈពេលមួយថ្ងៃពេញ សមាជិក-សមាជិកានៃអង្គសិក្ខាសាលាទាំងមូលដែលជាមន្ត្រីជាន់ខ្ពស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានតាមដានស្តាប់ដោយយកចិត្តទុកដាក់នូវរាល់បទបង្ហាញរបស់លោកសាស្ត្រាចារ្យ **អាគីអូ កាមីកូ (AKIO KAMIKO)** នៃប្រទេសជប៉ុន លោកសាស្ត្រាចារ្យ **វូធីសាន ថាន់ឆៃ (WOOTHISARN TANCHAI)** នៃព្រះរាជាណាចក្រថៃ និងលោកបណ្ឌិត **អាឡិចបែលឡូ ប្រ៊ីឡង់តេស្ត (ALEXBELLO BRILLANTES)** នៃប្រទេសហ្វីលីពីន ដែលបានលើកឡើងអំពីការលំបាក ភាពងាយស្រួល បទពិសោធន៍ និងបញ្ហាប្រឈមនានា ដែលកើតឡើងនៅក្នុងដំណើរការកំណែទម្រង់វិមជ្ឈការក្នុងប្រទេសជប៉ុន ព្រះរាជាណាចក្រថៃ និងប្រទេសហ្វីលីពីន ដោយផ្តោតសំខាន់លើការបែងចែកមុខងាររវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អញ្ជើញមានប្រសាសន៍បិទអង្គសិក្ខាសាលានាឱកាសនោះឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** បានមានប្រសាសន៍ថា : រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងជំរុញការដោះស្រាយបញ្ហាប្រឈមនានា ក្នុងកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះក្នុងក្របខណ្ឌនៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងផែនការអនុវត្តកម្មវិធីជាតិ ដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិត្រូវបានប្រគល់មុខងារអំណាច ធនធានបុគ្គលិកចាំបាច់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី មានប្រសាសន៍បញ្ជាក់ទៀតថា : ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនរួមមាន :

**ទី១**-ការបង្កើតនូវកាលានុវត្តភាព និងយន្តការសម្រាប់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិធ្វើការសម្រេចលើអនាគតនៃសហគមន៍របស់ខ្លួន តាមរយៈការពិគ្រោះយោបល់ និងការចូលរួមជាមួយប្រជាពលរដ្ឋរបស់ខ្លួន។

**ទី២**-ទាមទារឱ្យមានសេវាកម្មសាធារណៈ សម្ភារៈ និងមធ្យោបាយព្រមទាំងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានសំខាន់ៗច្រើនជាងមុន ល្អប្រសើរជាងមុន និងមានគុណភាពល្អជាងមុន សម្រាប់ឆ្លើយតបឱ្យបានឆាប់រហ័សទៅនឹងការអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយសមធម៌ ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី មានប្រសាសន៍សង្កត់ធ្ងន់ថា : ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានគោលបំណងបង្កើតនូវបរិយាកាសប្រកបដោយ

ប្រជាធិបតេយ្យដោយមានការចូលរួមពីប្រ
ជន ដែលជាអ្នកផ្តល់ជីវិតដល់ស្ថាប័នជាប់ឆ្
និងស្ថាប័នសាធារណៈទាំងអស់ធ្វើសេចក្តីសម្រ
ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភ
បំផុត ដែលប៉ះពាល់ដល់ជីវភាពរស់នៅរប
ប្រជាពលរដ្ឋ។ ដូច្នេះការអភិវឌ្ឍន៍តាមបែ
ប្រជាធិបតេយ្យគឺជាដំណើរការកំណែទម្រ
មានសក្តានុពលក្នុងការអភិវឌ្ឍអភិបាលកិច្
នៅគ្រប់លំដាប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ដោ
ធ្វើការផ្លាស់ប្តូរនូវរបៀបប្រាស្រ័យទាក់ទង
រវាងប្រជាពលរដ្ឋនិងស្ថាប័ន ដែលជាប់ឆ្នោ
និងស្ថាប័នសាធារណៈនានា។ នេះជាតម្រូវក
នៃជីវភាពសង្គម ដោយមានការផ្លាស់ប្តូរ
រៀងរាល់ថ្ងៃ ដែលតម្រូវឱ្យមន្ត្រីដឹកនាំគ្រ
លំដាប់ថ្នាក់ត្រូវតែរៀនសូត្រជាប្រចាំពីប្រ
ពលរដ្ឋ ពីសហគមន៍ ដែលយើងកំពុងបំពេ
ការងារ។ ទន្ទឹមនេះយើងក៏ត្រូវស្វែងយល់និ
រៀនសូត្រពីការប្រែប្រួលផ្លាស់ប្តូរក្នុងតំប
និងពិភពលោក ដើម្បីកែប្រែរបៀបរបប
សេចក្តីសម្រេចសម្រាប់ឆ្លើយតបនឹងសេច
ត្រូវការរបស់ប្រជាពលរដ្ឋ និងការប្រែប្រួ
សង្គម ដើម្បីតាមឱ្យទាន់នូវចរន្តសកលភាវូប
នីយកម្ម។ **ការរៀនសូត្រនេះត្រូវធ្វើជាប្រច**
**និងគ្មានទីបញ្ចប់ឡើយ សម្រាប់យើងជាមន្រ្**
**ដឹកនាំ**។

ជាមួយនឹងការថ្លែងអំណរគុណចំពោះ
អង្គការ **JICA** ប្រចាំកម្ពុជា ចំពោះអ្នកជំនាញ
នៃគម្រោងភីឡាក់២ **(PILAC2)** និងសាស្ត្រា
ចារ្យប្រកបដោយបទពិសោធន៍មកពីប្រទេស
ជប៉ុន ព្រះរាជាណាចក្រថៃ និងប្រទេសហ្វីលី
ពីន ដែលបានរួមគ្នាផ្តល់បទពិសោធន៍ក្នុងភាព
ជាអ្នកដឹកនាំពាក់ព័ន្ធកំណែទម្រង់វិមជ្ឈការ និង
វិសហមជ្ឈការដល់មន្ត្រីជាន់ខ្ពស់ទាំងនៅថ្នាក់
ជាតិ និងថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រ
កម្ពុជា ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
ក៏បានអំពាវនាវដល់អង្គការ **JICA** ដៃគូអភិ
វឌ្ឍ និង វិទ្យាស្ថាននានាសូមឱ្យបន្តផ្តល់កិច្ច
សហការរៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលា
ជាបន្តបន្ទាប់ទៀតដល់មន្ត្រីដឹកនាំជាន់ខ្ពស់ទាំង
នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅកម្ពុជា ៕

*លីដា*

22/5/23, 10:12 AM






# ប្រាំពីរមករា

## *កំណាព្យពោល (បទពាក្យប្រាំបី)*

១- ប្រាំពីរមករាចារជាប្រវត្តិ ខ្មែរបានកំណត់ហើយកត់ចងចាំ
ជាថ្ងៃខ្មែររស់ផុតពីគុកកម្ម នរកភក់ជ្រាំនៃបានអវិចីយ។

២- ប្រាំពីរមករាបក្សប្រជាជន សង្គ្រោះបានទាន់ខ្មែរទាំងប្រុសស្រី
ជាងបួនលាននាក់រស់រានជាថ្មី ផុតភាពប្រល័យនៃវាលពិឃាត។

៣- ប្រាំពីរមករាភ្លឺថ្លាជាងពេជ្រ ខ្មែរចាំជានិច្ចមិនឱ្យរលៀត
ក្នុងមួយជីវិតពិតមិនឱ្យឃ្លាត ថ្ងៃសង្គ្រោះជាតិសង្គ្រោះប្រជា។

៤- ប្រាំពីរមករាខ្មែរបានរួចរស់ គ្រប់អ្វីទាំងអស់រស់ដូចៗគ្នា
រស់សិទ្ធិសេរីរស់ទាំងជន្មា រស់គ្រប់សាសនាទូទាំងនគរ។

៥- ប្រាំពីរមករាកំណើតទីពីរ ខ្មែរសុំអញ្ជលីដោយចិត្តស្មោះសរ
គុណូបការៈចាំគ្រប់តំណ ជឿជាក់គាំទ្រប្រាំពីរមករា។

៦- ប្រាំពីរមករាជាមហាគុណ បក្សប្រជាជនគុណធ្ងន់ថ្លៃថ្លា
គ្មានគុណអ្វីស្មើប្រាំពីរមករា ទេវតាបាចផ្កាប្រោសព្រំជាតិយើង។

៧- ប្រាំពីរមករាជាម្ដាយឪពុក ខ្មែររួចផុតទុក្ខជាតិបានថ្កុំថ្កើង
ល្បីល្បាញលើលោកវីរត្នឡើង កិត្តិសព្ទរុងរឿងនៅលើលោកា។

៨- ប្រាំពីរមករាស្មារតីអមតៈ ខ្មែរអភិរក្សស្ម័គ្រថែរក្សា
ខ្មែរមានថ្ងៃនេះក៏គឺដោយសារ ប្រាំពីរមករាគុណមានតម្លៃ។

៩- ប្រាំពីរមករាសម្ដេចធម្មពោធិ សម្ដេចតេជោ សម្ដេចចក្រី
សម្ដេចអគ្គមហាទាំងបី ជាទេវតាថ្លៃ នៃជាតិខេមរា។

១០- ប្រាំពីរមករាជាទេវតាពិត ខ្មែរសូមរួមចិត្តជីវិតសង្ខារ
សូមរួមសូមរស់ក្រោមម្លប់ទេវតា ប្រាំពីរមករាសម្ដេចទាំងបី ៕

*គោរពដឹងគុណពីអ្នកនិពន្ធ ធិល ចន្ទា*
*អតីតនិស្សិតសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*



https://online.fliphtml5.com/vhqfg/gmza/

22/5/23, 10:12 AM



# អ្នកមានប្រយោជន៍ដល់បរិស្ថាន

## បទកាកគតិ

-ព្រលឹមស្រាងៗ ដើងដៃសងខាង ស្រវាស្រវា
រុករើរាវរក របស់នានា តាមទីសាធារណ៍
ដើម្បីជីវិត ។

-កូរកាយសំរាម បែកញើសរហាម ពុំហ៊ានទឹកគិត
ថាការទាបថោក ចេញពីគំនិត ព្រោះតែជីវិត
តម្រូវឲ្យធ្វើ ។

-ឆ្អែកគន់រំពៃ រកសព្វអ្វីៗ រើសសព្វសារពើ
របស់សេសសល់ ប្រឹងកាយគាស់រើ កាយក្រោមលើទាញ
សន្សំរបស់ ។

-ប្រមូលជ័រដែក លោហៈបាក់បែក ទាំងថ្មី ឬ ស្រស់
ឲ្យតែលក់បាន ប្រមូលទាំងអស់ ទោះនៅកៀនកោះ
ក៏មិនអាក់ខាន ។

-ពីព្រឹកថ្ងៃត្រង់ ឃ្លានស្មើរពុំចង់ រីចិញ្ចឹមប្រាណ
ខំប្រឹងសន្សំ របស់រកបាន ទោះហាត់ប៉ុន្មាន
មិនដែលត្អូញត្អែរ ។

-មិនដែលចុះចាញ់ ចំណីពុំឆ្ងាញ់ ក៏ស៊ូទ្រាំដែរ
ហូបតែមួយរស់ គ្រាន់កំដរគេ ចង់ល្អឆ្ងាញ់ដែរ
តែពុំហ៊ានពាល់ ។

-ខ្លះមានគំនិត ខ្នះខ្នែងរិះគិត ប្រឹងឈោងឲ្យដល់
មិនខ្លាចឈឺចាប់ ហាត់នឿយមិនខ្វល់ ក្ដីសុខស្កប់ស្កល់
តម្កល់ដោយខ្នែក ។

-ទោះក្ដៅឡើងស្ករ ពុំហ៊ានឈប់ឈរ លំបាកមិនស្រែក
រកបានមួយថ្ងៃ លៃទុកថ្ងៃស្អែក លៃលកបែងចែក
សន្សំលុយកាក់ ។

-មិនអស់សង្ឃឹម នៅតែញញឹម ថានឹងមានប្រាក់
ធ្វើជាដើមទុន សមស្មួនថាន: លេបទៅលែងស្លាក់
នាថ្ងៃខាងមុខ ។

-រីរាល់រូបមនុស្ស មិនថាស្រីប្រុស តែងមានសុខទុក្ខ
ជាគូនឹងគ្នា លំបាកស្រណុក ថ្ងៃនេះថ្ងៃមុខ
ប្រែប្រួលប្រចាំ ។

-ត្រូវមានប្រយោជន៍ កុំឲ្យហីនហោច ដោយសារសាងកម្ម
ឈើវៀរធ្វើកង់ ឈើត្រង់ធ្វើទូក ឈើទ្រង់សាំញាំ
ធ្វើខូសដុតបាន ។

-ប្រយោជន៍ផ្សេងគ្នា ថ្លង់ខ្វាក់គជា រៀងរាល់រូបប្រាណ
ការណ៍មិនសម្រេច ព្រោះមិនក្លាហាន កុំឲ្យខ្លួនប្រាណ
រស់ឥតប្រយោជន៍ ។៕

ដោយការិនិពន្ធ ជាង ស៊ីសុខួន



https://online.fliphtml5.com/vhqfg/gmza/
Page 44 of 53

# ក្លីនិកធ្មេញ លីវ ផេង

# LIV PHENG DENTAL CLINIC

ចាប់តាំងពីឆ្នាំ ១៩៩៧ រហូតដល់បច្ចុប្បន្ននេះ
លោកទន្តបណ្ឌិត **លីវ ផេង** កំពុងស្ថិតនៅក្នុង
ក្របខណ្ឌជាមន្ត្រីនគរបាលជាតិមួយរូបៗ
លោកទន្តបណ្ឌិត **លីវ ផេង**
មានបទពិសោធន៍លើការព្យាបាលជំងឺ
មាត់-ធ្មេញជាង២០ឆ្នាំ ដោយទទួលបាន
សញ្ញាបត្រទន្តបណ្ឌិតនៅសាកល
វិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
មហាវិទ្យាល័យទន្តវេទនសាស្ត្រ។
លោកទន្តបណ្ឌិតបានបញ្ចប់វគ្គបំប៉នបន្ថែម
នៅប្រទេសអូស្ត្រាលី និងប្រទេសថៃ។
លើសពីនេះលោកទន្តបណ្ឌិតបានការពារនិក្ខេបបទ
ថ្នាក់ទន្តបណ្ឌិតដោយទទួលនិទ្ទេស
**"កិត្តិយសដ៏ខ្ពង់ខ្ពស់"** ពីសាកលវិទ្យាល័យ
សុខាភិបាល មហាវិទ្យាល័យទន្តវេទនសាស្ត្រ
នៃព្រះរាជាណាចក្រកម្ពុជា។



លោកទន្តបណ្ឌិត លីវ ផេង







ទន្តបណ្ឌិតប្រកបដោយបទពិសោធន៍



ឧបករណ៍ទំនើបសំបូរបែប



ភ្ញៀវកំពុងរង់ចាំទទួលការពិនិត្យ-ព្យាបាល

អាសយដ្ឋាន : ផ្ទះលេខ១៥៨ ផ្លូវ៦៣០ សង្កាត់ផ្សារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទល់មុខអតីត **រោងភាពយន្តផ្សារអំពៅ**។

ទូរស័ព្ទទំនាក់ទំនង : 012 75 79 79

22/5/23, 10:12 AM

# អគ្គស្នងការដ្ឋាននគរបាលជាតិ កែសម្រួលសមាសភាពថ្នាក់ដឹកនាំគណៈបញ្ជាការស្រាលនគរបាលជាតិប្រចាំ ភូមិភាគទី ៥



ឯកឧត្តម ឧត្តមសេនីយ៍ឯក ហ៊ី សាគុណា
ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន

កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ នៅទីបញ្ជាការស្រាលនគរបាលជាតិប្រចាំភូមិភាគ៥ ខេត្តបន្ទាយមានជ័យ មានប្រារព្ធពិធីប្រកាសកែសម្រួលសមាសភាពថ្នាក់ដឹកនាំមួយចំនួនរបស់គណៈបញ្ជាការស្រាលនគរបា ជាតិប្រចាំភូមិភាគទី៥ ដោយមានការអញ្ជើញចូលរួ សំណាក់ឯកឧត្តម ឧត្តមសេនីយ៍ឯក **ដាំ ខុន្ធី** អគ្គស្ន ការរងនគរបាលជាតិ ព្រមទាំងថ្នាក់ដឹកនាំនាយកដ្ឋា កណ្តាលនគរបាលព្រំដែន នាយកដ្ឋាននគរបាលព្រំដែ គោក នាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន តំណា យោធភូមិភាគទី៥ តំណាងការិយាល័យទំនាក់ទំនងព្រំដែ កម្ពុជា-ថៃ ស្នងការរងនគរបាលខេត្តជាប់ព្រំដែន នា ប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិពាក់ព័ន្ធ និង មេបញ្ ការវរសេនាតូចនគរបាលព្រំដែនគោកទាំង១០ក្នុងទិ ភូមិភាគទី៥ សរុបចំនួន១០២នាក់ ។

នៅក្នុងសេចក្តីសម្រេចលេខ ៥០០ សសរ ចុះថ្ងៃ ០៧-១១-២០១៣ របស់អគ្គស្នងការដ្ឋាននគរបាលជា

តទៅទំព័រ ១៩




https://online.fliphtml5.com/vhqfg/gmza/


... a simpler and more helpful approach to banking
SBC Bank
Reach Out To Us For Your Needs
Head Office : No.68, Samdech Pan St. (St. 214) Phnom Penh
Tel: (855) 23 - 21 12 11 Fax: (855) 23 - 21 21 21
Swift: CSBCKHPP Telex:(51) 9407 1065 BANK G
Kampucheakrom : No.283Eo, Kampucheakrom Blvd, Phnom Penh
Tel: (855) 23 - 99 84 28
Mao Tse Toung : No.294, Mao Tse Toung Blvd, Phnom Penh
Tel: (855) 23 - 42 44 95
Monivong : No.203Eo, Monivong Blvd, Phnom Penh
Tel: (855) 23 - 88 28 78
Nehru : No.168GEo, Nehru Blvd (St. 215), Phnom Penh
Tel: (855) 23 - 88 55 00
Riverside : No.327Eo, Sisowath Quay, Phnom Penh
Tel: (855) 23 - 99 06 88
Sihanouk : No.55Eo, Sihanouk Blvd, Phnom Penh
Tel: (855) 23 - 99 13 88
Sorya I : No.52Eo, St. 63, Phnom Penh
Tel: (855) 23 - 99 17 87
Sorya II : No.80 (Unit 149), St. 51, Phnom Penh
Tel: (855) 23 - 99 26 87
Toul Tumpoung : No.232Eo, St. 271, Phnom Penh
Tel: (855) 23 - 22 02 38
Battambang : No.118, St. 02, Battambang
Tel: (855) 53 - 95 33 39
Kampong Cham : No.34, Monivong Street, Kampong Cham
Tel: (855) 42 - 94 14 08
Poi Pet : Holiday Palace Poipet, Banteay Meanchey
Tel: (855) 54 - 96 75 35
Siem Reap I : No.18A Sivatha Blvd, Siem Reap
Tel: (855) 63 - 96 38 38
Siem Reap II : Inside Lucky Mall, Siem Reap
Tel: (855) 63 - 96 37 37
Sihanouk Ville : No.255, Ekareach Street, Sihanouk Ville
Tel: (855) 34 - 93 42 28
www.sbc-bank.com
If you are looking for better personal banking, business banking, or both; you'll find SBC goes further to make your financial arrangements easy and convenient. Whether you want to open your first account or call in for financial advice, you're never far away from SBC
Website: www.sbc-bank.com
Email: info@sbc-bank.com
WESTERN UNION MONEY TRANSFER
VISA
MasterCard

# វេទិការដ្ឋាភិបាលលើកទី ១០ និងសមាគមស្មាតកាតអាស៊ីប៉ាស៊ីហ្វិក ស្តីពីអត្តសញ្ញាណអេឡិចត្រូនិកជំនាន់ថ

នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើក **វេទិការដ្ឋាភិបាលលើកទី១០ និងសមាគមស្មាតកាតអាស៊ីប៉ាស៊ីហ្វិក** (Asia Pacific Smart Card Associations) **ស្តីពីអត្តសញ្ញាណអេឡិចត្រូនិកជំនាន់ថ្មី** នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។



ទិដ្ឋភាពរួមក្នុងពិធី

វេទិការដ្ឋាភិបាលលើកទី១០នេះ គឺជាវេទិកាដ៏ធំមួយនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមានប្រតិភូអន្តរជាតិមកពី**៤៦ប្រទេស**ចូលរួម ដែលក្នុងនោះរួមមានអ្នកជំនាញការ អ្នកឯកទេស និងសមាគមឧស្សាហកម្ម ផលិតឧបករណ៍សម្ភារៈពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាពលរដ្ឋមកពីបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ វេទិកានេះផ្តោតសំខាន់លើខ្លឹមសារមួយចំនួន ដូចខាងក្រោម :

-ជំរុញការគ្រប់គ្រងរដ្ឋឱ្យមានដំណើរការប្រព្រឹត្តទៅបានល្អ ការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈ




ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង

ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាពលរដ្ឋពិតប្រាកដ និងច្បាស់លាស់ព្រោះវាជាមូលដ្ឋានគ្រឹះ នៃការងារសំខាន់មួយចំនួនដូចជា :

-ការគ្រប់គ្រងរដ្ឋបាលដែនដីដ៏ល្អ

-អភិបាលកិច្ចល្អ

-នីតិរដ្ឋ

-ការងារសន្តិសុខជាតិ និងសុវត្ថិភាពសង្គម។

-សេវាកម្មប្រជាពលរដ្ឋ

តទៅទំព័រ ១៣




ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញធ្វើបទសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញពិនិត្យគំរូអត្តសញ្ញាណអេឡិចត្រ

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ៖ "ប្រជាពលរដ្ឋ និង ពេលវេលាកំពុងរង់ចាំយើង"




ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង អញ្ជើញថ្លែងសុន្ទរកថាក្នុងអង្គពិធី



សមាជិក-សមាជិកាចូលរួមក្នុងពិធី

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រារព្ធធ្វើសន្និបាតបូកសរុបការងាររៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២១-២២ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្រោមអធិបតីភាពឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **អ៊ឹម សួស្ដី** ប្រធាន គ.ជ.ប ព្រមទាំងមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាអនុប្រធាន គ.ជ.ប ប្រធាន-អនុប្រធានលេខាធិការដ្ឋានរាជធានី-ខេត្តរៀបចំការបោះឆ្នោតទាំង២៤ និងតំណាងក្រសួងមហាផ្ទៃ តំណាងគណបក្សនយោបាយ តំណាងអង្គការក្រៅរដ្ឋាភិបាល ហើយនិងតំណាងអ្នកសង្កេតការណ៍ជាតិ-អន្តរជាតិជាច្រើនរូបទៀតក៏បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសនិងជាសមាជិក សមាជិកាក្នុងអង្គសន្និបាតនេះដែរ។

ក្នុងមតិបូកសរុបដែលអានដោយឯកឧត្តម **តេព នីថា** អគ្គលេខាធិការ គ.ជ.ប បានបញ្ជាក់ឱ្យដឹងថា : ដំណើរការរៀបចំការបោះឆ្នោត គឺជាការងារគ្រប់គ្រងរដ្ឋបាលមួយដែលមានការលំបាកនិងមានភាពស្មុគស្មាញច្រើន។ ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ បញ្ហាប្រឈមតែងកើនមានឡើង និងមានការប្រែប្រួលទៅតាមសភាពការណ៍សង្គម សេដ្ឋកិច្ច និងនយោបាយ ដែលទាមទារឱ្យមានការសិក្សាស្វែងយល់អំពីបញ្ហាទាំងនេះ ដើម្បីដោះស្រាយ និងកែលម្អសម្រាប់ការរៀបចំការបោះឆ្នោតនាអាណត្តិក្រោយៗទៀត។ ដូចនេះក្នុងរយៈពេលពីរថ្ងៃសន្និបាតបានរៀបចំឱ្យមានការ

តទៅទំព័រ ៣៣


SNPL
រោងពុម្ពជោគជ័យ
មានទទួលធ្វើធៀបការគ្រប់ប្រភេ
ធៀបការពិសេសៗ ម៉ូតថ្មីៗនិងពេញនិយមរបៀបខ្មែរតាមការកំម៉ង់ និងរបៀបសិ
ឬហុងកុងក៏ធ្វើបានដែរ ហើយយើងខ្ញុំមានគំរូរាប់រយបែបសម្រាប់ជ្រើស
ជ្រើសរើសចំណុចប្រសប់ខាងធ្វើធៀបការ ជាប្រការដ៏ល្អសំរាប់មង្គលការកូនប្រុសស្រីលោកអ្នក ហើយប្រាកដជានាំមកនូវក្តីស្នេហ៍
ស្រស់បវរ សុភមង្គលយឺនយូរ ទ្រព្យធនឆ្អើងថ្កាន ។ អាចរកធៀបការនេះបាននៅរោងពុម្ពជោគជ័យ #749 មហាវិថីព្រះមុនីវ
(ខាងត្បូងស្តុបបូកគោ ចម្ងាយ 50m) ឬតាមរយៈទូរស័ព្ទលេខ : 011 43 87 88 / 012 21 24 90 / 098 68 78


ផែនការអាជីវកម្មរបស់អ្នក នឹងក្លាយជាការពិត ជាមួយ
សេវាកម្មហិរញ្ញវត្ថុ សម្រាប់សហគ្រាសខ្នាតតូច
និងមធ្យម របស់ធនាគារ កាណាឌីយ៉ា
ធនាគារ កាណាឌីយ៉ា ក.អ
加 華 銀 行
CANADIA BANK PLC.
Your Best Partner !
: 023 868 222
: 012 938 588

# ក្រុមហ៊ុន សុខ គង់ អាហរ័ណ នីហរ័ណ

# SOKIMEX SOK KONG IMPORT EXPORT CO.,LTD.



សណ្ឋាគារនិងរមណីយដ្ឋានឆ្នេរសុខា ក្រុងព្រះសីហនុ
Sokha Beach Resort, Sihanouk Ville, Opened in 2004
Tel: +855 34 935 999 Fax: +855 34 935 888



សណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប
Sokha Angkor Resort, Siem Reap, Opened in 2005
Tel: +855 63 969 999 Fax: +855 63 969 998



ប្លង់មេនៃគំរោងអភិវឌ្ឍន៍រមណីយដ្ឋានភ្នំបូកគោ
Bokor Mountain Intergated Development Resort. Under Development



ស្ថានីយប្រេងឥន្ធនៈសូគីម៉ិចថ្មី
New Sokimex Petrol Station



គំរោងសាងសង់បឹងកាឡូលើទឹកនៅឆ្នេរសុខា ក្រុងព្រះសីហនុ
Sokha Beach Resort-Lakeside Chalets. Completion 2010



គំរោងសាងសង់សណ្ឋាគារខ្នាតអន្តរជាតិនៅឆ្នេរអូរឈើទាល ក្រុងព្រះសីហនុ
O'Chheuteal Beach Resort, Sihanouk Ville. Opening 2012



គំរោងសាងសង់សណ្ឋាគារខ្នាតអន្តរជាតិនៅជ្រោយចង្វារ ភ្នំពេញ
Sokha Hotel & Convention Centre, Phnom Penh. Opening 2011



គំរោងសាងសង់សណ្ឋាគារខ្នាតអន្តរជាតិនៅលើភ្នំបូកគោ
Bokor Mountain Resort & Casino. Opening 2011

**Sokimex Office**: Villa Nº 22 Kramuonsar St. Phsar Thmei 2 Daun Penh, Phnom Penh, Cambodia
Phone: 855-23 724134, Fax: 85-23 427207
E-mail: sokimex@bigpond.com.kh, http: // www.sokimex.8k.com

# មិត្តនគរបាល

POLICE FRIENDSHIP MAGAZINE

ទស្សនាវដ្តី

លេខ ៥៤ ឆ្នាំទី ១២ - ២០១៣




www.interior.gov.kh

## រាជរដ្ឋាភិបាល បង្កើតខណ្ឌថ្មីចំនួន៣ ៖ ខណ្ឌជ្រោយចង្វារ ខណ្ឌច្បារអំពៅ និង ខណ្ឌព្រែកព្នៅ

(ពេលនេះទូទាំងរាជធានីមានខណ្ឌសរុបចំនួន១២)